អេស៊ីលីដា
BUSINESS INSTITUTE



# កាតាឡុក

២០២០-២០២១

# មាតិកា


១. ប្រវត្តិវិទ្យាស្ថាន ពាណិជ្ជសាស្ត្រ អេស៊ីលីដា ធនធានសិក្សា និងធនធានរូបវន្ត .....១

២. គតិពេចន៍ ចក្ខុវិស័យ បេសកកម្ម គោលដៅ និង គុណតម្លៃ និងទស្សនវិជ្ជា ........៥

៣. របាយការណ៍ក្រុមប្រឹក្សាភិបាល ................................................................៨

៤. រចនាសម្ព័ន្ធ ................................................................................១៤

៥. ការទទួលស្គាល់គុណភាពអប់រំ ......................................................១៦

៦. កិច្ចព្រមព្រៀង/សហប្រតិបត្តិការ ...................................................១៨

៧. ការចុះឈ្មោះចូលសិក្សា .............................................................២១

៨. ហិរញ្ញវត្ថុ ...................................................................................២៦

៩. សេវានិស្សិត ................................................................................៣៣

១០. កិច្ចការសិក្សា .............................................................................៤២

# ប្រវត្តិវិទ្យាស្ថាន ពាណិជ្ជសាស្ត្រ អេស៊ីលីដា
# ធនធានសិក្សា និងធនធានរូបវន្ត

## ប្រវត្តិវិទ្យាស្ថាន ពាណិជ្ជសាស្ត្រ អេស៊ីលីដា

**ចាប់ពីឆ្នាំ១៩៩៣ រហូតដល់ឆ្នាំ១៩៩៧** ធនាគារ អេស៊ីលីដា ត្រូវបានធ្វើការរៀបចំបង្កើតឡើងក្នុងនាមជា អង្គការ សមាគមក្នុងស្រុកដែលមានឈ្មោះថា " សមាគមទីភ្នាក់ងារអភិវឌ្ឍន៍សេដ្ឋកិច្ចកម្ពុជាអេស៊ីលីដា " ក្រោមការ គាំទ្រ និងជួយឧបត្ថម្ភមូលនិធិពីកម្មវិធីអភិវឌ្ឍន៍អង្គការសហប្រជាជាតិ UNDP និងអង្គការពលកម្មអន្តជាតិ ILO ដើម្បីរួមចំណែកកាត់បន្ថយភាពក្រីក្ររបស់ប្រជាជនគ្រប់មជ្ឈដ្ឋានក្នុងប្រទេសកម្ពុជាក៏ដូចជាក្រុមគោលដៅ នៃអង្គការ ដូចជា ៖ កងទ័ពរំសាយ ជនពិការ ជនភៀសខ្លួន ជនបន្លាស់ទីលំនៅ ឬគ្មានទីជម្រក ស្ត្រីមេម៉ាយ ឬពោះម៉ាយ និងជនដែលរងនូវឥទ្ធិពលពីសង្គ្រាម។ ដើម្បីជំរុញដល់ប្រតិបត្តិការរបស់អង្គការឱ្យមានដំណើរការ និងសម្រេច បានតាមគោលដៅរបស់ខ្លួន ម្ចាស់មូលនិធិ និងអង្គការជាដៃគូបានបង្កើតនាយកដ្ឋានប្រឹក្សា និងការហ្វឹកហ្វឺន នៅឆ្នាំ១៩៩៧ ដែលមានលោក **ម៉ែន សារ័ន្ត** ជានាយកនាយកដ្ឋានប្រឹក្សា និងការហ្វឹកហ្វឺន ដោយទទួលខុសត្រូវក្នុងការរៀបចំបណ្តុះបណ្តាល និងហ្វឹកហ្វឺនដល់មន្ត្រីជំនាញក៏ដូចថ្នាក់ដឹកនាំ អង្គការអេស៊ីលីដា ប្រកប ដោយ ចំណេះ ជំនាញ និងក្លាយជាគ្រូបង្គោលក្នុងវិស័យជំនួញខ្នាតតូច និងតូចបំផុត។ វគ្គហ្វឹកហ្វឺនត្រូវបានរៀបចំ និងផ្តល់ជូនដល់កម្មករនិយោជិតក៏ដូចជា អតិថិជនគោលដៅលើការគ្រប់គ្រងជំនួញ ខ្នាតតូច និងតូចបំផុតជាបន្តបន្ទាប់ ក្រោយពីថ្នាក់ដឹកនាំក៏ដូចមន្ត្រីជំនាញបានទទួលការហ្វឹកហ្វឺនរួចមក។

**ចាប់ពីឆ្នាំ១៩៩៨ រហូតដល់ឆ្នាំ២០០៦** នាយកដ្ឋានប្រឹក្សា និងការហ្វឹកហ្វឺន ត្រូវបានធ្វើការផ្លាស់ប្តូរ ឈ្មោះមកជា "មជ្ឈមណ្ឌលហ្វឹកហ្វឺន" ដែលមានលោក **ម៉ែន សុផល** ជានាយកមជ្ឈមណ្ឌលហ្វឹកហ្វឺន ដោយមានតម្រូវការលើការទទួលខុសត្រូវច្បាស់លាស់ និងសមត្ថភាពពេញលេញ លើកិច្ចការហ្វឹកហ្វឺន។ ផ្នែកហ្វឹកហ្វឺន ត្រូវបានបង្កើតឡើងនៅថ្ងៃទី១ ខែមករា ឆ្នាំ២០០១ ក្នុងនាមជាផ្នែកមួយ នៅក្នុងនាយកដ្ឋានឥណទាន។ រហូតមកដល់ថ្ងៃទី៦ ខែមិថុនា ឆ្នាំ២០០២ នាយកដ្ឋានធនធានមនុស្ស ត្រូវបានបង្កើតឡើងហើយផ្នែកនេះ ក៏ត្រូវបានផ្ទេរមកស្ថិតនៅក្រោមការគ្រប់គ្រងរបស់នាយកដ្ឋានធនធានមនុស្ស។ នៅថ្ងៃទី១ ខែសីហា ឆ្នាំ២០០៤ ផ្នែកហ្វឹកហ្វឺនត្រូវបានផ្លាស់ប្តូរមកជាក្រុមហ្វឹកហ្វឺន និងក្លាយជាមជ្ឈមណ្ឌលហ្វឹកហ្វឺននៅថ្ងៃទី១៥ ខែសីហា ឆ្នាំ២០០៦ នៃនាយកដ្ឋានធនធានមនុស្ស។

**ចាប់ពីឆ្នាំ២០០៨ រហូតដល់ឆ្នាំ២០១០** ក្រោមកិច្ចសហប្រតិបត្តិការ រវាងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា និងសាធារណរដ្ឋសហព័ន្ធអាល្លឺម៉ង់ តាមរយៈខេ.អេហ្វ.ដាប់បិលយូ (KfW) លើជំនួយហិរញ្ញប្បទាន ឥតសំណងនៅថ្ងៃទី១៩ ខែធ្នូ ឆ្នាំ២០០៨ ធនាគារ អេស៊ីលីដា ភីអិលស៊ី ត្រូវបានជ្រើសរើសជាភ្នាក់ងារប្រតិបត្តិ គម្រោងសម្រាប់គាំទ្រមជ្ឈមណ្ឌលបណ្តុះបណ្តាលមីក្រូហិរញ្ញវត្ថុអាស៊ាន ដោយទទួលបាននូវហិរញ្ញប្បទានឥតសំណងចំនួន ៦១០.០០០អឺរ៉ូ ពីសាធារណរដ្ឋសហព័ន្ធអាល្លឺម៉ង់ តាមរយៈ ខេ.អេហ្វ.ដាប់បិលយូ (KfW)។

**នៅថ្ងៃទី១ ខែមករា ឆ្នាំ២០០៩** ការិយាល័យបណ្តុះបណ្តាលមីក្រូហិរញ្ញវត្ថុអេស៊ីលីដា-អាស៊ាន ត្រូវបាន បង្កើតឡើងដោយស្ថិតក្រោមការគ្រប់គ្រងរបស់មជ្ឈមណ្ឌលហ្វឹកហ្វឺនដែលមានលោក **ថោង ចាន់តារា** ជានាយកមជ្ឈមណ្ឌលហ្វឹកហ្វឺន ដែលជាការិយាល័យមួយទទួលបន្ទុកកិច្ចការបណ្តុះបណ្តាល និងចែករំលែកបទពិសោធន៍ ចំណេះដឹង ជំនាញផ្នែកវិស័យមីក្រូហិរញ្ញវត្ថុរបស់អេស៊ីលីដា ជូនដល់ ប្រតិបត្តិករ និងអ្នកបង្កើតគោលការណ៍ក្នុងតំបន់អាស៊ាន។ ដោយដំណើររីកចម្រើនរបស់ធនាគារ អេស៊ីលីដា ភីអិលស៊ី មានភាពរលូន និងរីកចម្រើនជាលំដាប់ មជ្ឈមណ្ឌលហ្វឹកហ្វឺន ត្រូវបានកម្លាយខ្លួនជានាយកដ្ឋានហ្វឹកហ្វឺន នៅថ្ងៃទី១ ខែកក្កដា ឆ្នាំ២០០៩ ដោយមានការិយាល័យចំនួនពីរស្ថិតក្រោមការគ្រប់គ្រងគឺ ការិយាល័យបណ្តុះបណ្តាលមីក្រូហិរញ្ញវត្ថុអេស៊ីលីដា-អាស៊ាន និងការិយាល័យសិក្សា។ រហូតដល់ថ្ងៃទី១២ ខែមេសា ឆ្នាំ២០១០ ការិយាល័យបណ្តុះបណ្តាលមីក្រូហិរញ្ញវត្ថុអេស៊ីលីដា-អាស៊ាន ត្រូវបានផ្លាស់ប្តូរឈ្មោះមកជា "មជ្ឈមណ្ឌលបណ្តុះ បណ្តាលមីក្រូហិរញ្ញវត្ថុអេស៊ីលីដា-អាស៊ាន" និងត្រូវធ្វើប្រតិបត្តិការដាច់ដោយឡែកពីធនាគារ អេស៊ីលីដា ភីអិលស៊ី ដោយស្ថិតក្រោមការគ្រប់គ្រងផ្ទាល់ពីអនុប្រធាននាយកប្រតិបត្តិ និងជាប្រធាននាយកប្រតិបត្តិអភិបាលកិច្ច និង មាននាយកប្រតិបត្តិហ្វឹកហ្វឺន ជាអ្នកជួយផ្តល់យោបល់ និងមើលការខុសត្រូវដោយផ្ទាល់ជំនួសអនុប្រធាននាយកប្រតិបត្តិ និងជាប្រធាននាយកប្រតិបត្តិអភិបាលកិច្ច។

ដោយទំហំប្រតិបត្តិការលើសេវាកម្មហ្វឹកហ្វឺនខាងក្រៅនៅមានកម្រិត នៅថ្ងៃទី១៥ ខែសីហា ឆ្នាំ២០១០ មជ្ឈមណ្ឌលបណ្តុះបណ្តាលមីក្រូហិរញ្ញវត្ថុ អេស៊ីលីដា-អាស៊ាន ត្រូវបានផ្ទេរឱ្យស្ថិតនៅក្រោមការគ្រប់គ្រងរបស់ នាយកដ្ឋានហ្វឹកហ្វឺនវិញ។ រហូតមកដល់ថ្ងៃទី១ ខែធ្នូ ឆ្នាំ២០១០ ដើម្បីរៀបចំទៅតាមការរីកចម្រើនរបស់ធនាគារ អេស៊ីលីដា ស្របតាមផែនការអាជីវកម្មរបស់ខ្លួន មជ្ឈមណ្ឌល

បណ្តុះបណ្តាលមីក្រូហិរញ្ញវត្ថុ អេស៊ីលីដា-អាស៊ាន ត្រូវបានអនុញ្ញាតឱ្យធ្វើប្រតិបត្តិការដាច់ដោយឡែកជាថ្មីម្តងទៀតពី ធនាគារ អេស៊ីលីដា ភីអិលស៊ី។

**ចាប់ពីឆ្នាំ២០១១ រហូតដល់ឆ្នាំ២០១៥** ដើម្បីឱ្យមជ្ឈមណ្ឌលបណ្តុះបណ្តាលមីក្រូហិរញ្ញវត្ថុអេស៊ីលីដា-អាស៊ាន ទទួលខុសត្រូវពេញលេញលើកិច្ចការបណ្តុះបណ្តាលទាំងបុគ្គលិកផ្ទៃក្នុងរបស់ធនាគារ និងសិក្ខាកាមខាងក្រៅទាំងក្នុង-ក្រៅប្រទេស នាយកដ្ឋានហ្វឹកហ្វឺន ត្រូវបានផ្ទេរ និងដាក់បញ្ចូលឱ្យស្ថិតនៅក្រោមការគ្រប់គ្រង របស់មជ្ឈមណ្ឌលបណ្តុះបណ្តាលមីក្រូហិរញ្ញវត្ថុ អេស៊ីលីដា-អាស៊ាន នៅថ្ងៃទី១ ខែសីហា ឆ្នាំ២០១១។ ដើម្បីក្លាយខ្លួនជាក្រុមហ៊ុនពាណិជ្ជកម្មឯកជនមួយជាបុត្រសម្ព័ន្ធ នៃធនាគារ អេស៊ីលីដា ភីអិលស៊ី មជ្ឈមណ្ឌលបណ្តុះបណ្តាលមីក្រូហិរញ្ញវត្ថុ អេស៊ីលីដា-អាស៊ាន ត្រូវបានរៀបចំចុះឈ្មោះក្នុងបញ្ជិកាពាណិជ្ជកម្មនៅក្រសួងពាណិជ្ជកម្ម នៃព្រះរាជាណាចក្រកម្ពុជា ក្នុងរូបភាពជាសហគ្រាសឯកបុគ្គលទទួលខុសត្រូវមានកម្រិត ដែលមាននាមករណ៍ របស់ក្រុមហ៊ុនជាភាសាខ្មែរថា "អេស៊ីលីដា ត្រេននីង សេនធ័រ" និងជាភាសាបរទេស "ACLEDA Training Center Limited." ដែលមានលោក **ឆន ពន្លឺ** ជាអគ្គនាយក។

អេស៊ីលីដា ត្រេននីង សេនធ័រ ត្រូវបានទទួលស្គាល់ជានីតិបុគ្គលពេញលក្ខណៈច្បាប់នៅថ្ងៃទី៨ ខែមិថុនា ឆ្នាំ២០១១ ក្រោមអត្តលេខចុះបញ្ជីពាណិជ្ជកម្មលេខ: Co. ១៣៣២KH/២០១១ ដែលមានដើមទុនសរុបចំនួន ២០,០០០,០០០ (ម្ភៃលានរៀល) ដែលមាននាម អាសយដ្ឋាន និងកម្មសិទ្ធិនៃភាគទុនិកគឺ ធនាគារ អេស៊ីលីដា ភីអិលស៊ី ដែលជាក្រុមហ៊ុនមហាជនទទួលខុសត្រូវមានកម្រិត និងមានតំណាងស្របច្បាប់។

**ចាប់ពីឆ្នាំ២០១៦ រហូតដល់បច្ចុប្បន្ន** ដើម្បីកម្លាយខ្លួនជាគ្រឹះស្ថានឧត្តមសិក្សា អេស៊ីលីដា ត្រេនីង សេនធ័រ បានស្នើសុំអាជ្ញាប័ណ្ណពីរាជរដ្ឋាភិបាលកម្ពុជាដែលមានឈ្មោះថា "**វិទ្យាស្ថាន ពាណិជ្ជសាស្ត្រ អេស៊ីលីដា**"។ នៅថ្ងៃទី២៥ ខែមករា ឆ្នាំ២០១៦ វិទ្យាស្ថាន ពាណិជ្ជស្ត្រ អេស៊ីលីដា ត្រូវបានទទួលស្គាល់ជាផ្លូវការពី រាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា តាមរយៈអនុក្រឹត្យលេខ: ១៣ អនក្រ.បក។ ក្រោមការគ្រប់គ្រង និងដឹកនាំរបស់ **បណ្ឌិត ផុន ណារិន** ដែលជានាយកវិទ្យាស្ថាន ចាប់ពី២០១៨ រហូតដល់ពេលបច្ចុប្បន្ន វិទ្យាស្ថាន បណ្តុះបណ្តាល កម្រិតឧត្តមសិក្សាថ្នាក់បរិញ្ញាបត្ររង ថ្នាក់បរិញ្ញាបត្រ និងថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់ លើដេប៉ាតឺម៉ង់គ្រប់គ្រងពាណិជ្ជកម្ម និងដេប៉ាតឺម៉ង់បច្ចេកវិទ្យា និងវិទ្យាសាស្ត្រ ក្រោមការទទួលស្គាល់តាមរយៈប្រកាសរបស់ក្រសួងអប់រំ យុវជន និងកីឡា លេខ: ២១៧៥ អយក.ប្រក ចុះថ្ងៃទី២៦ ខែធ្នូ ឆ្នាំ២០១៨ និងប្រកាសលេខ:១៨៥២ អយក.ប្រក ចុះថ្ងៃទី២៨ ខែសីហា ឆ្នាំ២០១៩។

## ធនធានសិក្សា

ធនធានសិក្សា គឺជាចំណែកមួយដ៏សំខាន់ក្នុងការគាំទ្រសេវាអប់រំរបស់គ្រឹះស្ថានសិក្សាមួយ ដែលជាកត្តាជំរុញលើកទឹកចិត្តគ្រូបង្រៀន និស្សិត និងកម្មករនិយោជិត ឱ្យមានការចូលរួម និងចូលចិត្តការសិក្សា និងការបង្រៀនរបស់ខ្លួន។ វិទ្យាស្ថានបានរៀបចំធនធានសិក្សាដោយបានសាងសង់បណ្ណាល័យដែលមានទំហំធំទូលាយ មានក្រឡាផ្ទៃសរុបចំនួន ២.៣៨៨ ម៉ែត្រក្រឡា បំពាក់ឧបករណ៍ សម្ភារ បរិក្ខាគ្រប់គ្រាន់យ៉ាងសម្បូរបែប ដូចជាសៀវភៅ ម៉ាស៊ីនខ្ចី-សងស្វ័យប្រវត្តិ កុំព្យូទ័រ ប្រព័ន្ធអ៊ីនធឺណិត ប្រព័ន្ធបណ្ណាល័យអេឡិចត្រូនិក (E-Library) ម៉ាស៊ីនថតចម្លង។ល។ និងបានរៀបចំតាមបន្ទប់សិក្សា បន្ទប់អនុវត្តកុំព្យូទ័រ ដែលបំពាក់នូវធនធានបច្ចេកវិទ្យា សម្ភារឧបទ្ទេសគ្រប់គ្រាន់ មានដូចជាប្រព័ន្ធ អ៊ីនធឺណិតល្បឿនលឿន LCD Projector កុំព្យូទ័រ។ល។ ដើម្បីផ្តល់ឱកាស និងសម្រួលដល់គ្រូបង្រៀន និស្សិត និងកម្មករនិយោជិតរបស់ខ្លួនឱ្យទទួលបានភាពងាយស្រួលក្នុងការសិក្សាស្រាវជ្រាវឯកសារ និងទិន្នន័យផ្សេងៗ ដើម្បីគាំទ្រការបង្រៀន ការសិក្សា និងការងារឱ្យទទួលបានជោគជ័យប្រកបដោយគុណភាព។

## ធនធានរូបវន្ត

វិទ្យាស្ថាន ពាណិជ្ជសាស្ត្រ អេស៊ីលីដា មានអគាររដ្ឋបាល អគារសិក្សា បណ្ណាល័យ បន្ទប់ប្រជុំ សាលសហសិក្សា ដែលមានទីតាំងធំទូលាយ មានបរិស្ថានសិក្សាល្អអំណោយផលម្រាប់ការសិក្សា និងសកម្មភាពផ្សេងៗ។

វិទ្យាស្ថាន ពាណិជ្ជសាស្ត្រ អេស៊ីលីដា មានអាសយដ្ឋានស្ថិតនៅអគារលេខ១៣៩៧ មហាវិថីមិត្តភាព ភ្នំពេញ-ហាណូយ ភូមិអន្លង់ក្ងាន សង្កាត់ឃ្មួញ ខណ្ឌសែនសុខ រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា ដែលជាទីតាំងប្រកបដោយបរិស្ថានល្អ អំណោយផលដល់ការបង្រៀន និងការសិក្សា និងមានទីធ្លាធំទូលាយ។ វិទ្យាស្ថានមានអគារសិក្សា បន្ទប់សិក្សា ការិយាល័យ

បន្ទប់ប្រជុំ សាលសហសិក្សា បណ្ណាល័យ បន្ទប់ថតរូប បន្ទប់ថតចម្លង បន្ទប់គិលានុបដ្ឋាយិកា បន្ទប់ពិគ្រោះជាមួយនិស្សិត បន្ទប់បម្រើអតិថិជន បន្ទប់វិសោធនកម្ម បន្ទប់សមាគមន៍និស្សិត អាហារដ្ឋាន កន្លែងលក់ទំនិញ សម្ភារសិក្សា បេឡា ទីកន្លែងបម្រើសេវាធនាគារអេឡិចត្រូនិច បន្ទប់ត្រួតពិនិត្យកាមេរ៉ា(CCTV) និងការផ្គត់ផ្គង់អគ្គិសនី និងទឹកគ្រប់គ្រាន់ហើយមានការគ្រប់គ្រងប្រកបដោយប្រសិទ្ធភាព។

វិទ្យាស្ថាន ពាណិជ្ជសាស្ត្រ អេស៊ីលីដា មានផ្ទៃដីទំហំសរុប ៧៥.៧៥០ ម៉ែ ដែលមានអគារសិក្សាចំនួន ២អគារ កម្ពស់ ៥ជាន់ (ទំហំសរុប ១១.៩៨០,៨០ ម២) អគាររដ្ឋបាល មានចំនួន១អគារ កម្ពស់៣ជាន់(ទំហំសរុប ៦.៣៧៧,២៤ ម២) អគារអន្តេវាសិកដ្ឋាន មានចំនួន១អគារ កម្ពស់៤ជាន់ (ទំហំសរុប ១.៧៦៤ ម២) អគារបណ្ណាល័យ មានចំនួន១អគារ កម្ពស់៣ជាន់ (ទំហំសរុប ២.៣៨៨ ម២)។

ក្រោមការវិនិយោគដែលមានទំហំទឹកប្រាក់ប្រមាណ ៣៧លានដុល្លារសហរដ្ឋអាមេរិក វិទ្យាស្ថាន ពាណិជ្ជសាស្ត្រ អេស៊ីលីដា បានសាងសង់អគារថ្មីទំហំ ៧៥.៧៥០ ម៉ែត្រក្រឡា ដែលមានទីតាំងនៅ ភូមិអន្លង់ក្ងាន សង្កាត់ឃ្មួញ ខណ្ឌសែនសុខ រាជធានីភ្នំពេញ ដែលមានអគារសិក្សាចំនួន២អគារ កម្ពស់៥ជាន់ (បន្ទប់សិក្សារបស់និស្សិត Class Room ចំនួន២៩ បន្ទប់ប្រជុំចំនួន៧ សាលសហសិក្សា (Theather Room) ចំនួន១០ បន្ទប់កុំព្យូទ័រចំនួន៧ បន្ទប់សម្រាប់និស្សិតសិក្សាម្នាក់ឯង/សិក្សាជាក្រុម /Seminar Room ចំនួន៣៤ បណ្ណាល័យចំនួន១អគារ កម្ពស់៣ជាន់ បរិវេណទីធ្លាសម្រាប់កីឡាបាល់ទាត់ទំហំ ៦៤មx១០០ម បាល់ទះ ទំហំ ២១មx៣៤ម បាល់បោះទំហំ ២១មx៣៤ម បន្ទប់សិល្បៈ ទិវាវប្បធម៌ និងសកម្មភាពផ្សេងៗទំហំ ៥មx២៥ម អន្តេវាសិកដ្ឋានចំនួន៤៧បន្ទប់ អាចឱ្យនិស្សិតស្នាក់នៅចំនួន១៣៧នាក់ និងអគារសម្រាប់បុគ្គលិករដ្ឋបាលចំនួន១អគារ កម្ពស់ ៣ជាន់ ដែលអាចឱ្យបុគ្គលិកបំពេញការងារប្រហែល២៥០កន្លែង។

បន្ទប់សិក្សានៅវិទ្យាស្ថានមានលក្ខណៈទូលាយ និងបានបង្កបរិយាកាសរៀនសូត្រយ៉ាងប្រសើរ ទៅតាមភាពបត់បែននៃវិធីសាស្ត្របង្រៀន ដោយរក្សាបាននូវភាពស្ងប់ស្ងាត់ ពន្លឺ និងខ្យល់អាកាសចេញ-ចូលគ្រប់គ្រាន់ ព្រមទាំងបានបំពាក់នូវអ៊ីនធឺណិត ពាក្យស្លោកអប់រំ រូបភាពនានា និងសម្ភារឧបទ្ទេសន៍សម្រាប់ដំណើរការបង្រៀន និងសិក្សា។

ក្រៅពីសិក្សាក្នុងថ្នាក់ និស្សិតក៏អាចមកសិក្សារៀនសូត្របន្ថែមនៅក្នុងបណ្ណាល័យ ដែលមានបំពាក់ឧបករណ៍ អេឡិចត្រូនិច រួមមាន៖ កុំព្យូទ័រ ឧបករណ៍ស្តាប់សម្លេង និងសេវាអ៊ីនធឺណិត។ល។ វិទ្យាស្ថានបានរៀបចំបន្ទប់សម្រាប់សាស្ត្រាចារ្យដែលសម្រួលដល់ការត្រៀមរៀបចំជាមុននូវកិច្ចការបង្រៀន ការស្រាវជ្រាវ ឯកសារ កំណែកិច្ចការនិស្សិត ផែនការមេរៀន និងការសម្រាកជាដើម។ លើសពីនេះ វិទ្យាស្ថានក៏មាននូវបន្ទប់សាលសហសិក្សាចំនួន ៣៤បន្ទប់ សម្រាប់ជាទីកន្លែងសិក្សា រៀបចំសិក្ខាសាលា ការធ្វើបទបង្ហាញដែលទាក់ទងទៅនឹងចំណេះដឹងសង្គម និងវិទ្យាសាស្ត្រ ដើម្បីចែករំលែកចំណេះដឹង បទពិសោធន៍ និងលើកទឹកចិត្តដល់ការចូលរួមក្នុងសកម្មភាពសិក្សារបស់និស្សិត ដែលអាចផ្ទុកសិស្ស-និស្សិត ពី៤៥-២១៨នាក់។



អគារវិទ្យាស្ថាន ពាណិជ្ជសាស្ត្រ អេស៊ីលីដា

# គតិពេចន៍ ចក្ខុវិស័យ បេសកកម្ម គោលដៅ និង គុណតម្លៃ និងទស្សនវិជ្ជា

## គតិពេចន៍

គតិពេចន៍

ថ្នាលអប់រំដើម្បីភាពជោគជ័យក្នុងអាជីព។

## ចក្ខុវិស័យ

ចក្ខុវិស័យ

វិទ្យាស្ថាន ពាណិជ្ជសាស្រ្ត អេស៊ីលីដា ជាថ្នាលអប់រំធុរកិច្ចប្រកបដោយគុណភាពឈានមុខ រួមចំណែកអភិវឌ្ឍសេដ្ឋកិច្ចកម្ពុជា និងតំបន់។

## បេសកកម្ម

បេសកកម្ម

បេសកកម្មរបស់ វិទ្យាស្ថាន ពាណិជ្ជសាស្រ្ត អេស៊ីលីដា គឺផ្តល់នូវសេវាកម្មអប់រំ តាមរយៈការសិក្សាផ្ទាល់ជាមួយវិទ្យាស្ថាន និងកម្មវិធីសិក្សាបែបឌីជីថលសម្រាប់ការអភិវឌ្ឍ ចំណេះដឹង ជំនាញវិជ្ជាជីវៈ ការបង្កើតថ្មី និងនវានុវត្តបទពិសោធន៍ អភិសមាចារ បណ្តាញទំនាក់ទំនង ដើម្បីជោគជ័យក្នុង អាជីពរបស់អ្នកសិក្សា ដោយប្រកាន់ខ្ជាប់ជានិច្ចនូវគោលការណ៍ សីលធម៌ វិជ្ជាជីវៈ សង្គម វប្បធម៌ចម្រុះ ច្បាប់ និងបរិស្ថាន ប្រកបដោយកម្រិតខ្ពស់បំផុត។

## គោលដៅ

គោលដៅ

ធ្វើឱ្យនិស្សិតដែលបានបញ្ចប់ការសិក្សា មានសក្តានុពលការងារខ្ពស់។

# គុណតម្លៃ និង ទស្សនវិជ្ជា

**គុណភាព** គណៈគ្រប់គ្រងនិងសាស្ត្រាចារ្យមានសមត្ថភាពខ្ពស់ទាន់សម័យ,សេវាកម្មទាន់ចិត្ត ប្រកបដោយគុណភាព, វិធីសាស្ត្របង្រៀនមានប្រសិទ្ធភាព, សិក្ខូបករណ៍ទំនើបទាន់សម័យ នាំឱ្យនិស្សិតមានគុណភាពឈានមុខ។

**ក្រមសីលធម៌** និស្សិតប្រតិបត្តិឥតខ្ចោះក្នុងជីវិត និងការងារ ស្របតាមច្បាប់ គោលការណ៍ សីលធម៌ ប្រពៃណីក្នុងសង្គម និងមានក្រមសីលធម៌ធុរកិច្ចខ្ពស់បំផុត។

**ការងារ** និស្សិតមានសមត្ថភាព លទ្ធភាព ទទួលបាននូវការងារព្រមទាំងបង្កើត បង្កើន និងរក្សាបាននូវនិរន្តរភាពការងារ។

**វិជ្ជាជីវៈ** និស្សិតមានសមត្ថភាពក្នុងវិជ្ជាជីវៈ ច្បាស់លាស់ ប្រកបដោយតម្លៃនៃគុណធម៌សិក្សា ស្របតាមបទដ្ឋានជាខ្នាតគំរូទាន់សម័យ។



ថ្នាក់ដឹកនាំជាន់ខ្ពស់នៃ វិទ្យាស្ថាន ពាណិជ្ជសាស្ត្រ អេស៊ីលីដា

# របាយការណ៍ក្រុមប្រឹក្សាភិបាល

ក្រុមប្រឹក្សាភិបាលបានជួបប្រជុំគ្នាផ្ទាល់ចំនួន ៤លើក ក្នុងឆ្នាំ២០២០ និង ជួបជុំគ្នាចំនួន ៣លើក ក្នុងឆ្នាំ២០២១ ក្នុងខែមីនា ខែតុលា ខែមិថុនា ខែកញ្ញា និងខែធ្នូ នៅក្នុងរាជធានីភ្នំពេញ។ លើសពីនេះទៅទៀត គិតត្រឹមខែតុលា ឆ្នាំ២០២១ សេចក្តីសម្រេចជាច្រើនត្រូវបានអនុម័តតាមរយៈអ៊ីមែល។ កិច្ចប្រជុំនីមួយៗជាធម្មតាមានរយៈពេល១ថ្ងៃ រួមបញ្ចូលទាំងប្រជុំគណៈកម្មាធិការផងដែរ។

សមាសភាព៖

| | |
|---|---|
| ១. លោក លី ថៃ | ប្រធានក្រុមប្រឹក្សាភិបាល |
| ២. លោក ព្រំ វិសុទ្ធ | អភិបាល |
| ៣.បណ្ឌិត Pieter Kooi | អភិបាល |
| ៤. បណ្ឌិត ផុន ណារិន | អភិបាល |

សកម្មភាពចម្បងចាប់ពីខែវិច្ឆិកា ឆ្នាំ២០២០ រហូតដល់ខែតុលា ឆ្នាំ២០២១

ពិនិត្យឡើងវិញ និងអនុម័តនូវគោលនយោបាយរបស់ក្រុមប្រឹក្សាភិបាល

- ពិនិត្យឡើងវិញ និងអនុម័ត តួនាទី និងភារកិច្ចរបស់គណៈកម្មាធិការនៃក្រុមប្រឹក្សាភិបាល
- ពិនិត្យ និងអនុម័ត ជ្រើសតាំងសវនករឯករាជ្យ សម្រាប់ឆ្នាំសារពើពន្ធ ២០២១ ប្រចាំវិទ្យាស្ថាន
- អនុម័ត និងផ្តល់អនុសាសន៍ ដល់ភាគទុនិក លើការផ្លាស់ប្តូរនូវនិមិត្តសញ្ញា និងត្រា របស់វិទ្យាស្ថាន
- អនុម័ត និងផ្តល់អនុសាសន៍ ដល់ភាគទុនិក ធ្វើវិសោធនកម្មនៃអនុស្សរណៈ និងលក្ខន្តិកៈ របស់វិទ្យាស្ថាន
- អនុម័ត និងផ្តល់អនុសាសន៍ ដល់ភាគទុនិក បញ្ចប់ការវិនិយោគ ចំនួន ០,០១% ស្មើនឹង ២.០១៤ ភាគហ៊ុន នៅអេស៊ីលីដា មីក្រូហិរញ្ញវត្ថុ មីយ៉ាន់ម៉ា ដោយលក់ភាគហ៊ុន ទៅឲ្យធនាគារ អេស៊ីលីដា ភីអិលស៊ី
- អនុម័ត និងផ្តល់អនុសាសន៍ ដល់ភាគទុនិក លើការវិនិយោគរបស់ អេស៊ីលីដា ហ្វាយណាន់ហ្សល់ ត្រាស់ (ការទិញភាគហ៊ុន) របស់វិទ្យាស្ថាន ពាណិជ្ជសាស្ត្រ អេស៊ីលីដា ក្នុងចំនួនទឹកប្រាក់ US$ ១០.០០០.០០០ (ដប់លានដុល្លារអាមេរិកគត់) និងធ្វើវិសោធនកម្ម ប្រការ៨ ប្រការ៩ និងប្រការ១០ នៃអនុស្សរណៈ និងលក្ខន្តិកៈ កិច្ចព្រមព្រៀងម្ចាស់ភាគហ៊ុន រវាង វិទ្យាស្ថាន ពាណិជ្ជសាស្ត្រ អេស៊ីលីដា ធនាគារ អេស៊ីលីដា ភីអិលស៊ី និងអេស៊ីលីដា ហ្វាយណាន់ហ្សល់ ត្រាស់
- អនុម័ត និងផ្តល់អនុសាសន៍ ដល់ភាគទុនិក ដើម្បីអនុម័តក្នុងការរៀបចំរចនាសម្ព័ន្ធក្រុមប្រឹក្សាភិបាល នៃ វិទ្យាស្ថាន
- អនុម័ត និងផ្តល់អនុសាសន៍ ដល់ភាគទុនិក លើការអនុម័តលក្ខណៈវិនិច្ឆ័យរបស់ក្រុមប្រឹក្សាភិបាល
- អនុម័ត និងផ្តល់អនុសាសន៍ ដល់ភាគទុនិក តែងតាំងលោកបណ្ឌិត ផុន ណារិន នាយកវិទ្យាស្ថាន ជាសមាជិកក្រុមប្រឹក្សាភិបាលសម្រាប់អាណត្តិ ០៣ ឆ្នាំ ចាប់ពីខែមេសា ឆ្នាំ២០២១ ដល់ ខែមេសា ឆ្នាំ២០២៤
- អនុម័ត និងផ្តល់អនុសាសន៍ ដល់ភាគទុនិក អនុម័តលើរបាយការណ៍ហិរញ្ញវត្ថុប្រចាំឆ្នាំសារពើពន្ធ ២០២០ របស់វិទ្យាស្ថាន
- អនុម័ត និងផ្តល់អនុសាសន៍ ដល់ភាគទុនិក អនុម័តលើអត្រាអតិផរណា ២,៩% សម្រាប់ឆ្នាំ២០២១ ប្រសិទ្ធភាពចាប់ពីថ្ងៃទី០១ ខែមេសា ២០២១ ដល់ ថ្ងៃទី៣១ ខែមីនា ឆ្នាំ២០២២
- ពិនិត្យ និងអនុម័ត ផែនការចិការសម្រាប់ឆ្នាំ២០២២-២០២៦ (សម្រាប់ដំណាក់កាលទី១ និងទី២) របស់វិទ្យាស្ថាន
- អនុម័ត និងផ្តល់អនុសាសន៍ ដល់ភាគទុនិក អនុម័តចំពោះ លោក Ian Samuel Lydall លាលែងពីតួនាទីពីសមាជិកក្រុមប្រឹក្សាភិបាលនៃវិទ្យាស្ថាន
- ពិនិត្យឡើងវិញ និងអនុម័ត គតិពេចន៍ ចក្ខុវិស័យ បេសកកម្ម គោលដៅ និងគុណតម្លៃ និងទស្សនវិជ្ជា របស់វិទ្យាស្ថាន

- អនុម័ត ស្តីពីការតែងតាំងបណ្ឌិត Pieter Kooi ជាប្រធានគណៈកម្មាធិការសវនកម្ម សីលធម៌ និងសម្របសម្រួលកិច្ចការច្បាប់នៃក្រុមប្រឹក្សាភិបាលស្តីទី ជំនួសលោក Ian Samuel Lydall
- អនុម័ត និងផ្តល់អនុសាសន៍ ដល់ភាគទុនិក លើការតំឡើងថ្លៃនៃការចូលរួមកិច្ចប្រជុំរបស់ក្រុមប្រឹក្សាភិបាល និងសមាជិកគណៈកម្មាធិការនៃក្រុមប្រឹក្សាភិបាលក្នុងអត្រា២,៩%
- អនុម័ត លើការរំលាយគណៈកម្មាធិការផែនការយុទ្ធសាស្ត្រនៃក្រុមប្រឹក្សាភិបាល (SPC)
- អនុម័ត លើទស្សនាវដ្តី E-Magazine របស់វិទ្យាស្ថាន

របាយការណ៍គណៈកម្មាធិការនៃក្រុមប្រឹក្សាភិបាល

- គណៈកម្មាធិការសិក្សាធិការនៃក្រុមប្រឹក្សាភិបាល
- គណៈកម្មាធិការផែនការយុទ្ធសាស្ត្រនៃក្រុមប្រឹក្សាភិបាល
- គណៈកម្មាការធិការសវនកម្ម សីលធម៌ និងសម្របសម្រួលកិច្ចការច្បាប់នៃក្រុមប្រឹក្សាភិបាល

## គណៈកម្មាធិការសិក្សាធិការនៃក្រុមប្រឹក្សាភិបាល

### វិសាលភាព និងគោលបំណង

គណៈកម្មាធិការសិក្សាធិការ ត្រូវបានបង្កើតឡើងដោយ ក្រុមប្រឹក្សាភិបាលនៃវិទ្យាស្ថាន ពាណិជ្ជសាស្ត្រ អេស៊ីលីដា ដើម្បីផ្តល់ការគាំទ្រផ្នែកបច្ចេកទេស និងផ្តល់អនុសាសន៍ដល់ក្រុមប្រឹក្សាភិបាលសម្រាប់កិច្ចការសិក្សាធិការ លើការបង្រៀន ការរៀន និងការកំណត់ចក្ខុវិស័យលើគុណភាពនៃការអប់រំ រួមទាំងការអភិវឌ្ឍសមត្ថភាព និងរៀបចំកម្មវិធីសិក្សាផងដែរ។

សមាសភាព

- បណ្ឌិត ឌី សមស៊ីដេត ប្រធាន
- បណ្ឌិត Pieter Kooi សមាជិក
- លោក សូ សុវណ្ណរ៉េត សមាជិក(តំណាងសាស្ត្រាចារ្យ)

កិច្ចប្រជុំគណៈកម្មាធិការសិក្សាធិការ បានធ្វើកិច្ចប្រជុំ ចំនួន ៤ដង មានដូចជាក្នុងខែ ធ្នូ ឆ្នាំ២០២០ និងខែមីនា ខែមិថុនា និងខែកញ្ញា ឆ្នាំ២០២១។

បញ្ហាចម្បង និងសកម្មភាពចាប់ពីខែវិច្ឆិកា ឆ្នាំ២០២០ ដល់ ខែតុលា ឆ្នាំ២០២១

- ធ្វើការណែនាំការសិក្សាអំពីយុទ្ធសាស្ត្រ PhD ដើម្បីវិនិយោគរយៈពេលវែង និងការឲ្យឈ្មោះចំពោះកម្មវិធីកម្រិតបរិញ្ញាបត្រជាន់ខ្ពស់ "ASIAN Terminology"
- ផ្តល់អនុសាសន៍ ក្នុងការរឹតបន្តឹងចំណងភាពជាដៃគូសហការជាមួយ វិទ្យាស្ថានបច្ចេកវិទ្យាគិរីរម្យ ដើម្បីសហប្រតិបត្តិការ និងការងារក្នុងភាពជាដៃគូរវាងស្ថានប័នទាំងពីរ
- ផ្តល់អនុសាសន៍ ដល់ក្រុមការងារអាហារូបករណ៍ ឲ្យមើលពីភាពចម្រុះលើសពីអាហារូបករណ៍ផ្តល់ឱ្យនិស្សិត ប៉ុន្តែសម្រាប់ដល់អ្នកស្រាវជ្រាវ និងសាស្ត្រាចារ្យផងដែរ
- ផ្តល់អនុសាសន៍ លើការតាមដាននិស្សិតដែលបានបញ្ចប់ការសិក្សា លើការងារ មុខតំណែង និងប្រាក់បៀវត្ស
- ផ្តល់អនុសាសន៍ ក្នុងការរៀបចំរបាយការណ៍ នៃការឆ្លើយតបរបស់និយោជក ដែលទទួលនិស្សិតវិទ្យាស្ថានធ្វើការជាមួយ
- ផ្តល់អនុសាសន៍ ក្នុងការរៀបចំគណៈកម្មការផ្តល់រង្វាន់ដល់គ្រូឆ្នើម

- ផ្តល់អនុសាសន៍ ក្នុងការសួរទៅកាន់នាយកដ្ឋានឧត្តមសិក្សា សម្រាប់ការកសាងសមត្ថភាព ដែលឧបត្ថម្ភដោយ Hong Kong University ក្នុងករណីដែលវិទ្យាស្ថាន អាចស្នើសុំ
- ផ្តល់អនុសាសន៍ ក្នុងការសិក្សាស្វែងយល់ពីសកលវិទ្យាល័យនានាដែលសិក្សាតាមប្រព័ន្ធអនឡាញ
- ស្នើសុំឲ្យមានកម្មវិធី(App) ដើម្បីឲ្យអតីតនិស្សិតវិទ្យាស្ថាន អាចទំនាក់ទំនងគ្នា សម្រាប់ចែករំលែក ការងាររបស់ពួកគេបាន
- ណែនាំស្តីពីការរៀបចំ និងរចនាទម្រង់បែបបទ ដើម្បីឲ្យនិស្សិតដែលបានបញ្ចប់ការសិក្សាក្នុងការផ្តល់មតិយោបល់ ដើម្បីកែលំអរ លើប្រតិបត្តិការ និងការផ្តល់សេវាឲ្យនិស្សិតមានភាពល្អប្រសើរឡើង
- ធ្វើការណែនាំក្នុងការធ្វើបច្ចុប្បន្នភាពទម្រង់របាយការណ៍និស្សិតបញ្ចប់ការសិក្សា ដោយធ្វើការបែងចែកតាមរយៈ មុខវិជ្ជាសិក្សា និស្សិតកំពុងសិក្សា និងបានបញ្ចប់ការសិក្សា ដើម្បីរកឲ្យឃើញនូវគម្លាតនៃប្រាក់បៀវត្ស
- ស្នើសុំក្នុងការផ្តល់ព័ត៌មានអំពីចំនួន មុខវិជ្ជាសិក្សា និងលទ្ធផលនៃការសិក្សារបស់និស្សិតបានបញ្ចប់ការសិក្សា ដែលកំពុងស្វែងរកការងារធ្វើ
- ណែនាំ និងរៀបចំតារាងកិត្តិយសសម្រាប់និស្សិតដែលទទួលបានកម្រិតប្រាក់បៀវត្សខ្ពស់
- ស្នើសុំឲ្យមានការធ្វើបច្ចុប្បន្នកម្ម លើកម្មវិធីសិក្សា
- ធ្វើការរាយការណ៍នូវលទ្ធផលនៃសាស្ត្រាចារ្យឆ្នើមដែលទទួលបានពានរង្វាន់
- អនុម័ត កម្មវិធីសិក្សាវិទ្យាសាស្ត្រ និងវិស្វកម្មកុំព្យូទ័រ

## គណៈកម្មាធិការផែនការយុទ្ធសាស្ត្រនៃក្រុមប្រឹក្សាភិបាល

### វិសាលភាព និងគោលបំណង

គណៈកម្មាធិការផែនការយុទ្ធសាស្ត្រនៃក្រុមប្រឹក្សាភិបាល ត្រូវបានបង្កើតឡើងដោយ ក្រុមប្រឹក្សាភិបាលនៃវិទ្យាស្ថានពាណិជ្ជសាស្ត្រ អេស៊ីលីដា ក្នុងការគាំទ្រ និងផ្តល់អនុសាសន៍ លើផែនការយុទ្ធសាស្ត្រ ដើម្បីឈានទៅដល់ការសម្រេចបាននូវចក្ខុវិស័យរបស់ខ្លួន គឺជាថ្នាលអប់រំធុរកិច្ចប្រកបដោយគុណភាពឈានមុខ រួមចំណែកអភិវឌ្ឍសេដ្ឋកិច្ចកម្ពុជា និងតំបន់។

គណៈកម្មាធិការផែនការយុទ្ធសាស្ត្រ ត្រូវបានរំលាយដោយសេចក្តីសម្រេចរបស់ក្រុមប្រឹក្សាភិបាល នៅថ្ងៃទី១០ ខែកញ្ញា ឆ្នាំ២០២១

សមាសភាព

| | |
|---|---|
| - បណ្ឌិត Pieter Kooi | ប្រធាន |
| - បណ្ឌិត ឌី សមស៊ីដេត | សមាជិក |
| - បណ្ឌិត John Branch | សមាជិក |
| - បណ្ឌិត Gerhardus J.A Hummels | សមាជិក |
| - បណ្ឌិត Teo Khee Hwee | សមាជិក |

កិច្ចប្រជុំគណៈកម្មាធិការផែនការយុទ្ធសាស្ត្រនៃក្រុមប្រឹក្សាភិបាល បានធ្វើកិច្ចប្រជុំតាមរយៈ Videos conference-call ចំនួន ១ដង ក្នុងខែធ្នូ ឆ្នាំ២០២០ និង១ដង ក្នុងខែមិថុនា ឆ្នាំ២០២១។

បញ្ហាចម្បង និងសកម្មភាពចាប់ពីខែធ្នូ ឆ្នាំ២០២០ ដល់ ខែមិថុនា ឆ្នាំ២០២១

- ផ្តល់អនុសាសន៍លើការសិក្សាពី European Credit Transfer System (ECTS)
- ផ្តល់អនុសាសន៍អំពីការបន្តក្នុងការធ្វើផែនការយុទ្ធសាស្ត្រសម្រាប់ការទំនាក់ទំនង បង្កើតវេទិកាសម្រាប់ E-Magazine អតីតនិស្សិត និងនិយោជក
- សិក្សាពីស្ថាប័ន ដែលមានលក្ខណៈប្រកួតប្រជែងជាមួយ វិទ្យាស្ថាន

- ធ្វើការអភិវឌ្ឍផែនការលំអិតក្នុងការប្រើប្រាស់បច្ចេកវិទ្យាដើម្បីធ្វើស្វ័យប្រវត្តិកម្ម លើកកម្ពស់ប្រសិទ្ធភាពនៃការអប់រំ
- ផ្តល់អនុសាសន៍ ឲ្យសិក្សាពីស្ថាប័នដែលមានបច្ចេកទេសក្នុងការបណ្តុះបណ្តាលធនាគារិក នៅ ម៉ាឡេស៊ី ឬសិង្ហបុរី (ICLIF) ដើម្បីជាមូលដ្ឋានសម្រាប់វិទ្យាស្ថាន ក្នុងការគ្រប់គ្រងបណ្តុះបណ្តាលបុគ្គលិក ក្នុងវិស័យហិរញ្ញវត្ថុនៅក្នុងប្រទេសកម្ពុជា
- បង្កើតយុទ្ធសាស្ត្រ អំពីការបង្កើត និងក្លាយទៅជាមជ្ឈមណ្ឌលសម្រាប់សហគ្រិនភាព និង ពាណិជ្ជកម្មឈានមុខ
- សម្រេច និងយល់ព្រម ប្រើប្រាស់តួនាទី និងភារកិច្ចរបស់គណៈកម្មាធិការផែនការយុទ្ធសាស្ត្រ និងផ្តល់ជូនក្រុមប្រឹក្សាភិបាលដើម្បីអនុម័តចុងក្រោយ
- ផ្តល់អនុសាសន៍ អំពីស្ថានភាព វិទ្យាស្ថាន នៅក្នុងវិស័យអប់រំនៅកម្ពុជា
- ពិនិត្យឡើងវិញ និងអនុម័ត គតិពេចន៍ ចក្ខុវិស័យ បេសកកម្ម គោលដៅ និងគុណតម្លៃ និងទស្សនវិជ្ជា របស់វិទ្យាស្ថាន និងផ្តល់ជូនក្រុមប្រឹក្សាភិបាលដើម្បីអនុម័តចុងក្រោយ។

## គណៈកម្មាធិការសវនកម្ម សីលធម៌ និងសម្របសម្រួលកិច្ចការច្បាប់នៃក្រុមប្រឹក្សាភិបាល

### វិសាលភាព និងគោលបំណង

គណៈកម្មាធិការសវនកម្ម សីលធម៌ និងសម្របសម្រួលកិច្ចការច្បាប់នៃក្រុមប្រឹក្សាភិបាល ត្រូវបានបង្កើតឡើងដោយក្រុមប្រឹក្សាភិបាលនៃវិទ្យាស្ថាន ពាណិជ្ជសាស្ត្រ អេស៊ីលីដា ដើម្បីតាមដាន និង ត្រួតពិនិត្យភាពត្រឹមត្រូវនៃរបាយការណ៍ហិរញ្ញវត្ថុ ប្រព័ន្ធគ្រប់គ្រងហិរញ្ញវត្ថុផ្ទៃក្នុង សវនកម្មផ្ទៃក្នុង និងការផ្តល់សេវារបស់សវនករខាងក្រៅ។ ក្រៅពីនេះ ដើម្បីធានាការអនុលោមស្របទៅនឹងច្បាប់ និងបទប្បញ្ញត្តិនានា ដែលសមស្របទៅនឹងគោលនយោបាយ ដើម្បីផ្តល់នូវស្តង់ដារកម្រិតខ្ពស់បំផុតនៃអភិបាលកិច្ចសាជីវកម្ម និងប្រតិបត្តិដោយក្រមសីលធម៌។

សមាសភាព

- បណ្ឌិត Pieter Kooi ប្រធាន
- លោក ព្រំ វិសុទ្ធ សមាជិក

កិច្ចប្រជុំគណៈកម្មាធិការសវនកម្ម សីលធម៌ និងសម្របសម្រួលកិច្ចការច្បាប់នៃក្រុមប្រឹក្សាភិបាល បានបើកិច្ចប្រជុំ ផ្ទាល់ ៤ លើកក្នុងឆ្នាំ២០២០ និងចំនួន ៣លើក ក្នុងឆ្នាំ២០២១ ដោយផ្ទាល់ និងតាម Video Conference ។

បញ្ហាចម្បង និងសកម្មភាពចាប់ពីខែវិច្ឆិកា ឆ្នាំ២០២០ ដល់ ខែតុលា ឆ្នាំ២០២១

- ត្រួតពិនិត្យ និងអនុម័តទិដ្ឋភាពនៃកិច្ចការសាធារណៈ ដើម្បីធានាថាការអនុវត្តគោលការណ៍ស្របទៅនឹងសុជីវធម៌ សីលធម៌ និងអាកប្បកិរិយាល្អបំផុត (ឧ. "ការផ្សព្វផ្សាយការពិត")
- ធ្វើការត្រួតពិនិត្យលើគោលនយោបាយនៃក្រុមប្រឹក្សាភិបាល
- ធានាឲ្យបាននូវភាពត្រឹមត្រូវនៃប្រតិបត្តិការរបស់វិទ្យាស្ថាន ស្របទៅនឹងច្បាប់ និងបទបញ្ញត្តិ
- ធ្វើការតាមដាន និងត្រួតពិនិត្យនៃដំណើការរបស់ស្ថាប័ន ស្របទៅតាមគោលនយោបាយ គោលការណ៍ប្រតិបត្តិ និង នីតិវិធី ដែលបានអនុម័តដោយក្រុមប្រឹក្សាភិបាល ឬគណៈកម្មាធិការប្រតិបត្តិវិទ្យាស្ថាន
- ពង្រឹងទំនាក់ទំនងភាពជាដៃគូរ ជាមួយអាជ្ញាធរ និងដៃគូរពាក់ព័ន្ធ ដើម្បីធានាឲ្យវិទ្យាស្ថាន អនុលោមទៅតាមបច្ចុប្បន្នកម្មនៃបទបញ្ញត្តិដែលមានផលប៉ះពាល់ដល់ប្រតិបត្តិការវិទ្យាស្ថាន
- តាមដានរាល់ហានិភ័យនៃការមិនប្រតិបត្តិតាមបទបញ្ញត្តិ ដែលអាចកើតមានឡើងនៅពេលអនាគត

- ត្រួតពិនិត្យ និងផ្តល់យោបល់លើចំណុចខ្លាំង និងខ្សោយ នៃរបាយការណ៍ស្វ័យវាយតម្លៃ ដើម្បីធ្វើឲ្យគុណភាពអប់រំត្រូវបានទទួលស្គាល់ដោយ គណៈកម្មាធិការទទួលស្គាល់គុណភាពអប់រំនៃកម្ពុជា(ACC) ឬស្ថាប័នពាក់ព័ន្ធផ្សេងទៀត។
- ពិនិត្យលើការអនុវត្តន៍គោលនយោបាយកំណាពារនិវេទនជន និងការឆ្លើយតបរបស់ថ្នាក់គ្រប់គ្រង
- ពិនិត្យ និងឆ្លើយតបទៅលើការស្នើសុំនានារបស់ក្រុមប្រឹក្សាភិបាល
- ពិភាក្សា និងពិនិត្យទៅលើលិខិតសវនករខាងក្រៅ (Management Letter) និងការឆ្លើយតបរបស់ថ្នាក់គ្រប់គ្រង
- ធ្វើការវាយតម្លៃនៃនីតិវិធីនៃការត្រួតពិនិត្យផ្ទៃក្នុង ជាពិសេសក្នុងការវាស់ស្ទង់ និងការគ្រប់គ្រងហានិភ័យឲ្យមានភាពសមស្របគ្នា
- ត្រួតពិនិត្យ គុណភាពនៃប្រព័ន្ធគ្រប់គ្រងហិរញ្ញវត្ថុផ្ទៃក្នុងរបស់វិទ្យាស្ថាន និងធ្វើការរាយការណ៍ជូនក្រុមប្រឹក្សាភិបាលប្រចាំឆ្នាំ
- អនុម័ត ផែនការសវនកម្មផ្ទៃក្នុង ២០២១ (វិសោធនកម្មទៅតាមតម្រូវការចាំបាច់)
- ត្រួតពិនិត្យ និងអនុម័ត និងបានដាក់ជូនក្រុមប្រឹក្សាភិបាល ដើម្បីធ្វើការអនុម័តចុងក្រោយនៃរបាយការណ៍សវនកម្មហិរញ្ញវត្ថុ សម្រាប់ឆ្នាំ២០២០
- ត្រួតពិនិត្យ និងការដាក់ដំណើការគ្រប់គ្រងនៃការអនុវត្ត និងអភិវឌ្ឍន៍ IFRS
- ពិនិត្យ និងអនុម័តលើតួនាទី ភារកិច្ច នៃគណៈកម្មាធិការសវនកម្ម សីលធម៌ និងសម្របសម្រួលកិច្ចការច្បាប់នៃក្រុមប្រឹក្សាភិបាល និងសុំយោបល់ពីក្រុមប្រឹក្សាភិបាល ដើម្បីសម្រេចចុងក្រោយ
- ពិភាក្សា និងធ្វើការជ្រើសរើសក្រុមហ៊ុនសវនករឯករាជ្យខាងក្រៅប្រចាំវិទ្យាស្ថាន សម្រាប់ឆ្នាំសារពើពន្ធ២០២២



ការប្រជុំគណៈកម្មាធិការប្រតិបត្តិ វិទ្យាស្ថាន ពាណិជ្ជសាស្ត្រ អេស៊ីលីដា

# រចនាសម្ព័ន្ធ

# រចនាសម្ព័ន្ធគ្រប់គ្រង វិទ្យាស្ថាន ពាណិជ្ជសាស្ត្រ អេស៊ីលីដា ( វ ព អ )



# ការទទួលស្គាល់គុណភាពអប់រំ

ដើម្បីដឹកនាំ និងធានាឱ្យទទួលបាននូវគុណភាពអប់រំតាមកម្រិតស្តង់ដា និងនិរន្តរភាពនៃការអប់រំឧត្តមសិក្សា វិទ្យាស្ថាន ពាណិជ្ជសាស្ត្រ អេស៊ីលីដា បានបង្កើតគណៈកម្មការធ្វើស្វ័យវាយតម្លៃ (SAR Commission) ដែលស្ថិតក្រោមការគ្រប់គ្រងរបស់គណៈកម្មាធិការធានាគុណភាពអប់រំផ្ទៃក្នុង (IQA Committee) ដែលសមាសភាពទាំងអស់ ត្រូវបានចូលរួមអនុវត្តពីគ្រប់ការិយាល័យ ដេប៉ាតឺម៉ង់ មជ្ឈមណ្ឌល និងផ្នែកជំនាញពាក់ព័ន្ធ ដើម្បីកំណត់គោលនយោបាយក្នុងការធានាគុណភាពអប់រំ ការត្រួតពិនិត្យតាមដាន ការវាយតម្លៃជាក់ស្តែងតាមរយៈការវិភាគព័ត៌មាន-ទិន្នន័យនូវឯកសារតម្រូវពាក់ព័ន្ធ ការសន្និដ្ឋានប្រកបដោយភាពត្រឹមត្រូវ ការផ្តល់អនុសាសន៍សម្រាប់លើកកម្ពស់គុណភាពអប់រំនៃការបណ្តុះបណ្តាល ការរៀបចំរបាយការណ៍ស្វ័យវាយតម្លៃសម្រាប់ដាក់ជូនថ្នាក់មានសមត្ថកិច្ចត្រួតពិនិត្យ ផ្តល់អនុសាសន៍ និងវាយតម្លៃ និងការអនុវត្តផ្សេងៗទៀត ក្នុងន័យទទួលបានលទ្ធផលជោគជ័យទៅតាមការកំណត់នូវចក្ខុវិស័យ បេសកកម្ម និងគោលដៅរបស់វិទ្យាស្ថាន។ ទិសដៅសំខាន់របស់វិទ្យាស្ថាន គឺការទទួលបានការទទួលស្គាល់គុណភាពអប់រំដ៏ប្រសើរបំផុតទាំងថ្នាក់ជាតិ ថ្នាក់តំបន់ និងថ្នាក់ពិភពលោក ដើម្បីបង្ហាញដល់សាធារណៈជន មាតាបិតា ឬអាណាព្យាបាល ក្រុមហ៊ុន សហគ្រាស សហគមន៍ផ្តល់ជំនួយ អង្គការនានា ជាពិសេសសម្រាប់រាជរដ្ឋាភិបាល និងប្រទេសជាតិទាំងមូលថា វិទ្យាស្ថាន ពាណិជ្ជសាស្ត្រ អេស៊ីលីដា មានគណនេយ្យភាពចំពោះការអប់រំ មានជំនឿទុកចិត្តចំពោះការផ្តល់សេវាអប់រំ និងបានឆ្លើយតបយ៉ាងត្រឹមត្រូវទៅនឹងតម្រូវការទីផ្សារការងាររបស់និស្សិត និងសង្គមជាតិ។

ជាក់ស្តែងវិទ្យាស្ថាន ពាណិជ្ជសាស្ត្រ អេស៊ីលីដា បានរៀបចំប្រព័ន្ធធានាគុណភាពផ្ទៃក្នុងច្បាស់លាស់ ដើម្បីទទួលខុសត្រូវលើការធានាគុណភាពអប់រំ និងការវាយតម្លៃគុណភាពផ្ទៃក្នុង ដោយវិទ្យាស្ថានបានប្រើប្រាស់ឧបករណ៍វាយតម្លៃរបស់គណៈកម្មាធិការទទួលស្គាល់គុណភាពអប់រំនៃកម្ពុជា (គ.ទ.ក) និងឧបករណ៍វាយតម្លៃរបស់គ្រឹះស្ថានមួយចំនួនទៀត សម្រាប់ធ្វើស្វ័យវាយតម្លៃលើប្រព័ន្ធអភិបាលកិច្ច និងដំណើរការបណ្តុះបណ្តាលគ្រប់កម្រិតរបស់វិទ្យាស្ថាន។

នៅថ្ងៃពុធ ១កើត ខែអាសាឍ ឆ្នាំខាល ចត្វាស័ក ព.ស. ២៥៦៦ ត្រូវនឹងថ្ងៃទី២៩ ខែមិថុនា ឆ្នាំ២០២២ គណៈកម្មាធិការទទួលស្គាល់គុណភាពអប់រំនៃកម្ពុជា (គ.ទ.ក) បានផ្តល់ការទទួលស្គាល់គុណភាពអប់រំពេញសិទ្ធិដល់វិទ្យាស្ថាន ពាណិជ្ជសាស្ត្រ អេស៊ីលីដា ដែលបានបំពេញស្របតាមលក្ខខណ្ឌតម្រូវនៃស្តង់ដាជាតិ សម្រាប់រយៈពេល ៥ឆ្នាំ ចាប់ពីឆ្នាំ២០២១ ដល់ឆ្នាំ២០២៥ និងជាមួយគ្នានោះដែរ វិទ្យាស្ថានក៏បានរៀបចំរបាយការណ៍ធានាគុណភាពផ្ទៃក្នុងរបស់វិទ្យាស្ថាន ជូនទៅនាយកដ្ឋានឧត្តមសិក្សានៃក្រសួងអប់រំ យុវជន និងកីឡាផងដែរ។

សម្រាប់ការទទួលស្គាល់នូវគុណភាពអប់រំក្នុងកម្រិតណាមួយទាំងថ្នាក់ជាតិ ថ្នាក់តំបន់ និងថ្នាក់ពិភពលោក វិទ្យាស្ថាននឹងស្នើសុំវាយតម្លៃគុណភាពអប់រំពីស្ថាប័នមានសមត្ថកិច្ច ទៅតាមផែនការយុទ្ធសាស្ត្ររបស់វិទ្យាស្ថាន។



គណៈប្រតិភូជាន់ខ្ពស់នៃក្រសួងអប់រំ យុវជន និងកីឡា ចុះវាយតម្លៃគុណភាពអប់រំនៅ វិទ្យាស្ថាន ពាណិជ្ជសាស្ត្រ អេស៊ីលីដា

# កិច្ចព្រមព្រៀង/សហប្រតិបត្តិការ

| No. | Name of Organizations |
| --- | --- |
| 1 | AMK Microfinance Institution Plc. |
| 2 | Microfinance Institution "Amret" |
| 3 | Sovann Phoum Organization |
| 4 | First Finance Plc. |
| 5 | Mohanokor Organization |
| 6 | CRED Institution |
| 7 | Maxima Mikroheranhvatho Plc. |
| 8 | Samrithisak Microfinance Limited |
| 9 | Vision Fund Cambodia |
| 10 | Ly Hour Microfinance Institution |
| 11 | Career Development of Family (CDF) |
| 12 | Rith Sokha Organization |
| 13 | Human Resource Active Financial Organization |
| 14 | KK Fund Leasing Plc. |
| 15 | Mega Leasing Plc. |
| 16 | SAHAKRINPHEAP ST Microfinance PLC |
| 17 | Kasekor Mean Mean Plc. |
| 18 | Cambodia Post Bank Plc. (CP Bank) |
| 19 | Smile Finance Plc. |
| 20 | KREDIT Microfinance Institution Plc. |
| 21 | PRIME MF Microfinance Institution Ltd. |
| 22 | Phillip Bank |
| 23 | Chamroeun Microfinance Limited |
| 24 | Rights Smart Finance |
| 25 | TOYOTA (Cambodia) Co., Ltd. |
| 26 | Credit Mutuel Kampuchea (CMK) |
| 27 | ACTIVE PEOPLE's Microfinance Institution Plc. |
| 28 | BORRIBO Microfinance Institution Plc. |
| 29 | Capital Rong Roeung Plc. |
| 30 | Intean Poalroath Rongroeurng Ltd. |
| 31 | Y.C.P Micro Finance |
| 32 | Pracheacheat Finance |
| 33 | Labors and Family Economic Development |
| 34 | Cambodian Volunteers for Community Development |
| 35 | Samic Plc. |
| 36 | Community Capital Development Agency Organization |
| 37 | Cathay United Bank (Cambodia) Corporation Limited |
| 38 | SEILANITHIH LIMITED |
| 39 | KIM SAN Supported Farmer Living Rural Credit Operator |
| 40 | Key Micro Finance Institution Plc. |
| 41 | ORO Financecorp Plc. |
| 42 | BAYTANG CREDIT ORGANIZATION |

| | |
|---|---|
| 43 | Cambodian Economic Network (CEN) |
| 44 | ASIA PACIFIC FINANCE PLC. |
| 45 | URBAN ARCHITECTURE |
| 46 | BANG EK CREDIT OPERATOR |
| 47 | BAYON CREDIT MICROFINANCE INSTITUTION |
| 48 | Hattha Kaksekar Limited |
| 49 | SAHAKA Microfinance Institution Plc. |
| 50 | CITY MICROFINANCE INSTITUTION PLC. |
| 51 | TOYOTA TSUSHO FINANCE (CAMBODIA) PLC |
| 52 | DHL Cambodia |
| 53 | PROAHSITH CREDIT OPERATOR |
| 54 | Ly Hour Pay Pro PLC |
| 55 | Prudential (Cambodia) |
| 56 | HRinc. Cambodia |
| 57 | Century 21 |
| 58 | RHMS Pawn Shop Plc. |
| 59 | Serey Oudom Microfinance Plc. |
| 60 | InBizNest |
| 61 | Prince Bank Plc. |
| 62 | Woori Finance Cambodia Plc. |
| 63 | THF & B |
| 64 | PIS Trading |
| 65 | NongHyup Finance (Cambodia) Plc. |
| 66 | Modernity Holding |
| 67 | Integrated Logistics Services Co., Ltd. |
| 68 | The Securities and Exchange Regulator of Cambodia |
| 69 | Panha Chiet University |
| 70 | Asia Euro Univerisity |
| 71 | Western University |
| 72 | National University of Management |
| 73 | Kampuchea Institute of Certified Public Accountants and Auditors |
| 74 | Kirirom Institute of Technology |
| 75 | Help University Sdn Bhs ( 84963-D ) |
| 76 | NTC Group |
| 77 | Modern International School |
| 78 | Cambodia Association of The Church of Jesus |
| 79 | Central Prark School of Cambodia |
| 80 | SIS International School |
| 81 | Happy Chandara Neary Prek Thmey School of "TOUTES A L'ECOLE" NGO |
| 82 | Toun Fa II |
| 83 | Leep Khoun |
| 84 | WEG |
| 85 | Grand Mount |

# ការចុះឈ្មោះចូលសិក្សា

## ១- តម្រូវការក្នុងការចុះឈ្មោះចូលសិក្សា

នីតិវិធីទទួលចុះឈ្មោះសិស្ស-និស្សិតឱ្យចូលសិក្សា មានដូចខាងក្រោម៖

### ១.១ ថ្នាក់បរិញ្ញាបត្ររង

សិស្ស-និស្សិតដែលមានបំណងចុះឈ្មោះចូលសិក្សានៅវិទ្យាស្ថាន ត្រូវបំពេញទៅតាមតម្រូវការ ដូចខាងក្រោម៖

- កម្រិតវប្បធម៌ទូទៅ
- ចំណេះដឹងភាសាអង់គ្លេស
- ចំណេះដឹងគណិតវិទ្យា
- ចំណេះដឹងកុំព្យូទ័រទាន់សម័យ MS Word and Excel (មានលិខិតបញ្ជាក់)

### ១.២ ថ្នាក់បរិញ្ញាបត្រ

សិស្ស-និស្សិតដែលមានបំណងចុះឈ្មោះចូលសិក្សានៅវិទ្យាស្ថាន ត្រូវបំពេញទៅតាមតម្រូវការ ដូចខាងក្រោម៖

- កម្រិតវប្បធម៌ (សញ្ញាបត្រមធ្យមសិក្សាទុតិយភូមិ ឬសញ្ញាបត្រសមមូលដែលមានតម្លៃស្មើ)
- ចំណេះដឹងភាសាអង់គ្លេស
- ចំណេះដឹងគណិតវិទ្យា
- ចំណេះដឹងកុំព្យូទ័រទាន់សម័យ MS Word and Excel (មានលិខិតបញ្ជាក់)

## ២- គុណវុឌ្ឍិ

វិទ្យាស្ថានទទួលឱ្យចូលសិក្សាចំពោះសិស្សដែលមានគុណវុឌ្ឍិគ្រប់គ្រាន់ ដូចខាងក្រោម៖

### ២.១ ថ្នាក់បរិញ្ញាបត្ររង

**<u>កម្រិតវប្បធម៌ទូទៅ</u>**

- ធ្លាក់ ឬជាប់មធ្យមសិក្សាទុតិយភូមិ ឬ
- ធ្លាក់ ឬជាប់សញ្ញាបត្របច្ចេកទេស និងវិជ្ជាជីវៈ៣ ពីសាលាអប់រំ និងបណ្តុះបណ្តាលបច្ចេក-ទេសវិជ្ជាជីវៈ (Level 3 from TVET) ហើយត្រូវនឹងជំនាញស្នើសុំសិក្សា ឬ
- មានសញ្ញាបត្រ ឬលិខិតបញ្ជាក់សមមូល ដែលបញ្ជាក់ដោយស្ថាប័នមានសមត្ថកិច្ច

**<u>ចំណេះដឹងភាសាអង់គ្លេស</u>**

- មានសញ្ញាបត្រ ឬលិខិតបញ្ជាក់បានបញ្ចប់ថ្នាក់កម្រិតទូទៅ លើចំណេះដឹងភាសាអង់គ្លេស (General English) ក្នុងគ្រឹះស្ថានដែលមានកម្មវិធីសិក្សាជាភាសាអង់គ្លេសមិនលើសពី ០១ឆ្នាំ ក្រោយពីចេញសញ្ញាបត្រ ឬ
- មានពិន្ទុ IELT ចាប់ពី ៣,៥ ឬ TOEFL ចាប់ពី ៣៥០ (Paper Based) មិនលើសពី ០២ឆ្នាំ ក្រោយពីចេញលិខិតបញ្ជាក់
- ជាគ្រូបង្រៀនភាសាអង់គ្លេសកម្រិតមធ្យមសិក្សាទុតិយភូមិ នៅសាលាមធ្យមសិក្សារដ្ឋ ឬ ឯកជន (ក្នុងករណីសញ្ញាបត្រលើសរយៈពេល០២ឆ្នាំ)។

**<u>ចំណេះដឹងគណិតវិទ្យា</u>**

- បានប្រឡងជាប់មធ្យមសិក្សាទុតិយភូមិ (មិនលើសពី ០៣ឆ្នាំ) ដោយទទួលបាន និទ្ទេស (A-C) ឬ

- មានលិខិតបញ្ជាក់ជាគ្រូបង្រៀនគណិតវិទ្យាកម្រិតមធ្យមសិក្សាទុតិយភូមិ នៅសាលាមធ្យមសិក្សារដ្ឋ ឬ ឯកជន (ក្នុងករណីសញ្ញាបត្រលើសរយៈពេល០៣ឆ្នាំ)។

**<u>ចំណេះដឹងកុំព្យូទ័រ</u>**

- មានចំណេះដឹងកុំព្យូទ័រទាន់សម័យ MS Word and Excel (មិនលើស ០១ឆ្នាំ ក្រោយកាលបរិច្ឆេទចេញលិខិតបញ្ជាក់)។

### ២.២ ថ្នាក់បរិញ្ញាបត្រ

**<u>កម្រិតវប្បធម៌ទូទៅ</u>**

- មានសញ្ញាបត្រមធ្យមសិក្សាទុតិយភូមិ ឬ
- សញ្ញាបត្របច្ចេកទេស និងវិជ្ជាជីវៈ ៣ (កម្រិត៤) ឬ
- មានសញ្ញាបត្រ ឬលិខិតបញ្ជាក់សមមូល ដែលបញ្ជាក់ដោយស្ថាប័នមានសមត្ថកិច្ច

**<u>ចំណេះដឹងភាសាអង់គ្លេស</u>**

- មានសញ្ញាបត្រ ឬលិខិតបញ្ជាក់បានបញ្ចប់ថ្នាក់កម្រិតទូទៅ លើចំណេះដឹងភាសាអង់គ្លេស (General English) ក្នុងគ្រឹះស្ថានដែលមានកម្មវិធីសិក្សាជាភាសាអង់គ្លេសមិនលើសពី ០១ឆ្នាំ ក្រោយកាលបរិច្ឆេទចេញសញ្ញាបត្រ ឬ
- មានលិខិតបញ្ជាក់ការប្រឡងដោយមានពិន្ទុ IELTS ចាប់ពី ៣,៥០ ឬ TOEFL ចាប់ពី ៣៥០ (Paper Based) មិនលើសពី ២ឆ្នាំ ក្រោយពីចេញសញ្ញាបត្រ ឬ
- មានលិខិតបញ្ជាក់ជាគ្រូបង្រៀនភាសាអង់គ្លេសកម្រិតមធ្យមសិក្សាទុតិយភូមិ នៅសាលាមធ្យមសិក្សារដ្ឋ ឬ ឯកជន (ក្នុងករណីសញ្ញាបត្រលើសរយៈពេល០៣ឆ្នាំ)។

**<u>ចំណេះដឹងផ្នែកគណិតវិទ្យា</u>**

- មានសញ្ញាបត្រមធ្យមសិក្សាទុតិយភូមិ និងទទួលបាននិទ្ទេសរួម A-C លើមុខវិជ្ជា (មិនលើស ០៣ឆ្នាំ ក្រោយកាលបរិច្ឆេទចេញសញ្ញាបត្រ) ឬ
- មានលិខិតបញ្ជាក់ជាគ្រូបង្រៀនគណិតវិទ្យាកម្រិតមធ្យមសិក្សាទុតិយភូមិ នៅសាលាមធ្យមសិក្សារដ្ឋ ឬ ឯកជន (ក្នុងករណីសញ្ញាបត្រលើសរយៈពេល០៣ឆ្នាំ)។

**<u>ចំណេះដឹងកុំព្យូទ័រ</u>**

- មានសញ្ញាបត្រកុំព្យូទ័រទាន់សម័យ MS Word and Excel (មិនលើស ០១ឆ្នាំ ក្រោយកាលបរិច្ឆេទចេញលិខិតបញ្ជាក់)។

## ៣- ការទទួលឱ្យចូលសិក្សា

**<u>ការទទួលឱ្យចូលសិក្សា ដោយមិនឆ្លងកាត់ការធ្វើវិសោធនកម្ម</u>**

សិស្ស-និស្សិតដែលបំពេញបានគ្រប់គ្រាន់ និងគ្រប់ចំណុចទៅតាមគុណវុឌ្ឍិដូចបានរៀបរាប់នៅចំណុច ២.១ និងចំណុច២.២ ខាងលើ នឹងទទួលឱ្យចូលសិក្សាថ្នាក់បរិញ្ញាបត្ររង និងបរិញ្ញាបត្រ នៅវិទ្យាស្ថាន ដោយមិនឆ្លងកាត់វិសោធនកម្ម។

- **<u>ការទទួលឱ្យចូលសិក្សា ដោយការធ្វើវិសោធនកម្ម</u>**
  ករណីមិនបំពេញបានទៅនឹងគុណវុឌ្ឍិចំណេះដឹងភាសាអង់គ្លេស វិទ្យាស្ថានតម្រូវឱ្យបេក្ខជន-បេក្ខនារី ធ្វើវិសោធនកម្មលើចំណេះដឹងភាសាអង់គ្លេស។

- **<u>ការទទួលឱ្យចូលសិក្សា ដោយឆ្លងកាត់ថ្នាក់បំប៉ន</u>**
  ករណីមិនបំពេញបានទៅនឹងគុណវុឌ្ឍិណាមួយ នៃគុណវុឌ្ឍិដូចបានរៀបរាប់នៅចំណុច២.១ និងចំណុច២.២ ខាងលើ វិទ្យាស្ថានតម្រូវឱ្យបេក្ខជន-បេក្ខនារី ចូលសិក្សាថ្នាក់បំប៉ន ទៅតាមគុណវុឌ្ឍិដែលមិនបានបំពេញនោះ។

## ៤- នីតិវិធីដាក់ពាក្យសុំចូលសិក្សា

- **<u>ការសុំពាក្យសុំចូលសិក្សា</u>**
  សិស្ស-និស្សិត ដែលមានបំណងចុះឈ្មោះចូលសិក្សានៅវិទ្យាស្ថាន ត្រូវមកទំនាក់ទំនងជាមួយផ្នែកចុះ ឈ្មោះ និង បញ្ជិកា នៃការិយាល័យសិក្សា និងកិច្ចការនិស្សិត ដើម្បីសុំ ពាក្យសុំចូលសិក្សា នៅរៀងរាល់ម៉ោងធ្វើការ។
- **<u>ឯកសារសំណុំបែបបទ</u>**
  សិស្ស-និស្សិតត្រូវភ្ជាប់មកជាមួយនូវសំណុំឯកសារដូចខាងក្រោម៖

១. ពាក្យសុំ ចុះឈ្មោះចូលសិក្សា ០១ច្បាប់ ដោយមានបិតរូបថតបច្ចុប្បន្ន 4x6

២. រូបថតបច្ចុប្បន្ន 4x6 ចំនួន ០៥សន្លឹក

៣. ច្បាប់ថតចម្លងសញ្ញាបត្រ ទុតិយភូមិ ឬលិខិតបញ្ជាក់សញ្ញាបត្របច្ចេកទេស និងវិជ្ជាជីវៈ ៣ (កម្រិត៤) ដែលបញ្ជាក់ដោយសាលារាជធានីភ្នំពេញ ឬសាលាខណ្ឌ ចំនួន០២ច្បាប់ ។

៤. ច្បាប់ថតចម្លងសញ្ញាបត្រ ឬលិខិតបញ្ជាក់ចំណេះភាសាអង់គ្លេស ដែលមានពិន្ទុ IELTS ចាប់ពី ៣.៥ ឬ TEOFL ចាប់ពី៣៥០ (Paper based) មិនលើសពី ០២ឆ្នាំ ក្រោយពីចេញសញ្ញាបត្រ ឬលិខិតបញ្ជាក់ជាគ្រូបង្រៀនភាសាអង់គ្លេសចំនួន ០១ច្បាប់។

៤. សញ្ញាបត្រកុំព្យូទ័រ MS Word Excel ចំនួន០១ច្បាប់។

- **<u>ការដាក់ពាក្យចូលសិក្សា</u>**
  - សិស្ស-និស្សិត ត្រូវមកទំនាក់ទំនងជាមួយផ្នែកចុះឈ្មោះ និងបញ្ជិកា នៃការិយាល័យសិក្សា និង កិច្ចការនិស្សិត ដើម្បីដាក់ពាក្យសុំចូលសិក្សានៅរៀងរាល់ម៉ោងធ្វើការ។
  - សិស្ស-និស្សិត ត្រូវយកមកជាមួយនូវឯកសារច្បាប់ដើម ដើម្បីបញ្ជាក់ថារាល់ឯកសារថតចម្លងដែល បានប្រគល់ឱ្យវិទ្យាស្ថាន ជាឯកសារត្រឹមត្រូវ និងស្របច្បាប់ ដោយមិនមានការក្លែងបន្លំ។
  - សិស្ស-និស្សិតត្រូវចុះហត្ថលេខាទទួលខុសត្រូវចំពោះមុខច្បាប់លើឯកសារដែលបានប្រគល់ ឱ្យមកវិទ្យាស្ថានជាឯកសារត្រឹមត្រូវមិនក្លែងបន្លំ។
  - ផ្នែកចុះឈ្មោះ និងបញ្ជិកា នៃការិយាល័យសិក្សា និងកិច្ចការនិស្សិត មានភារកិច្ចត្រួតពិនិត្យសំណុំ ឯកសារដាក់ពាក្យសុំចូលសិក្សារបស់សិស្ស-និស្សិត ឱ្យបានត្រឹមត្រូវច្បាស់លាស់ គ្រប់គ្រាន់តាម លក្ខខណ្ឌតម្រូវ និងស្របច្បាប់ ដោយធ្វើការផ្ទៀងផ្ទាត់ជាមួយនឹងឯកសារច្បាប់ដើម ព្រមទាំងចុះហត្ថលេខាបញ្ជាក់លើសន្លឹកឯកសារថតចម្លងនោះថា **"បានពិនិត្យផ្ទៀងផ្ទាត់ត្រឹមត្រូវតាមច្បាប់ដើម"**។
  - វិទ្យាស្ថាននឹងធ្វើការបញ្ជូនច្បាប់ថតចម្លងនៃសញ្ញាបត្រទុតិយភូមិ ឬលិខិតបញ្ជាក់ ទៅអាជ្ញាធរពាក់ព័ន្ធដើម្បីត្រួតពិនិត្យ និងបញ្ជាក់ពីភាពស្របច្បាប់។

## ៥- ការផ្ទេរការសិក្សា

### ៥.១ ការផ្ទេរចេញពីវិទ្យាស្ថាន

- និស្សិតដែលមានបំណងផ្ទេរចេញពីវិទ្យាស្ថាន ត្រូវធ្វើសំណើសុំមកនាយកវិទ្យាស្ថាន ដើម្បីអនុមតិ
- ការិយាល័យសិក្សា និងកិច្ចការនិស្សិត មានភារកិច្ចសម្របសម្រួលចេញព្រឹត្តិបត្រពិន្ទុដល់និស្សិត ដោយបញ្ជាក់ឱ្យបានច្បាស់លាស់នូវមុខវិជ្ជាដែលនិស្សិតបានសិក្សា ចំនួនក្រេឌីត និងពិន្ទុនៃមុខវិជ្ជា នីមួយៗ ព្រមទាំងសេចក្តីពន្យល់លម្អិតដែលពាក់ព័ន្ធទៅនឹងការផ្តល់ពិន្ទុ និងនិទ្ទេសតាមសំណើសុំរបស់និស្សិត។

### ៥.២ ការផ្ទេរចូលមកវិទ្យាស្ថាន

និស្សិតដែលមានបំណងផ្ទេរចូលមកសិក្សានៅវិទ្យាស្ថាន នឹងត្រូវបានធ្វើការត្រួតពិនិត្យ និងសម្រេចដោយគណៈកម្មាការគ្រប់គ្រងកិច្ចការនិស្សិត របស់វិទ្យាស្ថាន ដោយពឹងផ្អែកទៅលើការកំណត់ ដូចខាងក្រោម៖

- កម្មវិធីសិក្សារបស់គ្រឹះស្ថានចាស់ ត្រូវប្រហាក់ប្រហែលជាមួយនឹងកម្មវិធីសិក្សារបស់វិទ្យាស្ថាន។
- និស្សិតត្រូវមានពិន្ទុនិទ្ទេសចាប់ពី ២,០០ ឡើងទៅគ្រប់មុខវិជ្ជា ករណីមុខវិជ្ជាណាមួយតូចជាង ២,០០ ត្រូវសិក្សាបំពេញក្រេឌីតលើមុខវិជ្ជានោះ ជាមួយវិទ្យាស្ថាន។
- ពិន្ទុនិទ្ទេសសម្រាប់មុខវិជ្ជាជំនាញនីមួយៗ ដែលនិស្សិតទទួលបាននៅគ្រឹះស្ថានចាស់ ត្រូវតែមាន តម្លៃស្មើ ឬប្រហាក់ប្រហែលជាមួយនឹងតម្លៃក្រេឌីត ដែលកំណត់ដោយវិទ្យាស្ថាន។
- សមាជិក សមាជិកា គណៈកម្មការដែលមានសមាសភាពចូលរួមពីគ្រប់ដេប៉ាតឺម៉ង់ មជ្ឈមណ្ឌល ការិយាល័យ និងផ្នែកដែលពាក់ព័ន្ធ សិក្សាពិន្ទុនិទ្ទេសលើមុខវិជ្ជាជំនាញនីមួយៗ ដើម្បីវាយតម្លៃ ថាពិតជាមានសមត្ថភាពអាចសិក្សាតាមកម្មវិធីសិក្សារបស់វិទ្យាស្ថានបាន និងប្រគល់ មកគណៈកម្មការ ដើម្បីប្រជុំសម្រេច។
- គណៈកម្មការធ្វើការប្រជុំទៅលើការអនុញ្ញាតឱ្យផ្ទេរចូល មកសិក្សានៅវិទ្យាស្ថាន ទៅតាមលទ្ធផលនៃការវាយតម្លៃរបស់ដេប៉ាតឺម៉ង់ជំនាញនីមួយៗ និង លក្ខខណ្ឌផ្សេងៗ របស់វិទ្យាស្ថាន។

## ៦- ការដកឈ្មោះចេញពីការសិក្សា និងចុះឈ្មោះសាជាថ្មី

### ៦.១ ការដកឈ្មោះចេញពីការសិក្សា

វិទ្យាស្ថាននឹងចាត់ទុកថា និស្សិតបានបោះបង់ចោលការសិក្សាក្នុងករណីនិស្សិត (ចាស់និងថ្មី) មិនមាន វត្តមានចូលសិក្សារយៈពេល១៥ថ្ងៃ (នៃថ្ងៃធ្វើការ) ជាប់គ្នាដោយគ្មានការជូនដំណឹង។

### ៦.២ ការចុះឈ្មោះសាជាថ្មី

និស្សិតដែលបានស្នើសុំព្យួរការសិក្សា វិទ្យាស្ថានបានផ្តល់សិទ្ធិត្រឡប់វិញ រយៈពេល ២ឆមាស បន្ទាប់ ពីការព្យួរការសិក្សា ប៉ុន្តែនិស្សិតតម្រូវឱ្យធ្វើការស្នើសុំចុះឈ្មោះជាថ្មីម្តងទៀត ទៅតាមនីតិវិធី របស់ ការិយាល័យសិក្សា និងកិច្ចការនិស្សិត ដើម្បីជូនដំណឹងថាបានត្រឡប់មកសិក្សាវិញ។

# ហិរញ្ញវត្ថុ

## ១. ថ្លៃសិក្សា

សម្រាប់ឆ្នាំសិក្សា ២០២០-២០២១ ថ្លៃសិក្សាត្រូវបានកំណត់ ដូចខាងក្រោម៖

### ១.១. ថ្នាក់បំប៉ន

| មុខវិជ្ជា | តម្លៃ | |
|---|---|---|
| | តម្លៃសិក្សា | តម្លៃសៀវភៅ |
| ភាសាអង់គ្លេស | ៨៥ ដុល្លារ | ១៤,៥០ ដុល្លារ |
| គណិតវិទ្យា | ៤៥ ដុល្លារ | ៧ ដុល្លារ |
| កុំព្យូទ័រ | ៤៥ ដុល្លារ | ១០ ដុល្លារ |

### ១.២. តម្លៃសិក្សាសម្រាប់និស្សិតដែលចុះឈ្មោះសិក្សាថ្នាក់បរិញ្ញាបត្ររងឯកទេស ចាប់ពីឆ្នាំសិក្សា ២០១៦-២០១៧ ដល់ឆ្នាំសិក្សា ២០២០-២០២១

| វេនសិក្សា | បង់ប្រចាំឆ្នាំ (ដុល្លារ) | បង់០២ដងក្នុង០១ឆ្នាំ (ដុល្លារ) | | បង់០៤ដងក្នុង០១ឆ្នាំ (ដុល្លារ) | | | |
|---|---|---|---|---|---|---|---|
| | | លើកទី១ | លើកទី២ | លើកទី១ | លើកទី២ | លើកទី៣ | លើកទី៤ |
| ថ្នាក់បរិញ្ញាបត្ររងឯកទេស គ្រប់មុខជំនាញ | | | | | | | |
| វេនព្រឹក | ៩៥០ | ៥៧៥ | ៣៧៥ | ៣៩៥ | ១៨៥ | ១៨៥ | ១៨៥ |
| វេនរសៀល | ៨៥០ | ៤៧៥ | ៣៧៥ | ២៩៥ | ១៨៥ | ១៨៥ | ១៨៥ |
| វេនល្ងាច | ៨៥០ | ៤៧៥ | ៣៧៥ | ២៩៥ | ១៨៥ | ១៨៥ | ១៨៥ |
| ថ្ងៃចុងសប្តាហ៍ | ៨៥០ | ៤៧៥ | ៣៧៥ | ២៩៥ | ១៨៥ | ១៨៥ | ១៨៥ |

ថ្នាក់បរិញ្ញាបត្ររងឯកទេស គ្រប់មុខជំនាញដែលបន្តទៅថ្នាក់បរិញ្ញាបត្រ

| វេនសិក្សា | បង់ប្រចាំឆមាស (ដុល្លារ) | បង់០២ដង ក្នុង០១ឆមាស (ដុល្លារ) | |
|---|---|---|---|
| | | លើកទី១ | លើកទី២ |
| វេនព្រឹក | ៦០០ | ៣៥០ | ២៥០ |
| វេនរសៀល | ៥៥០ | ៣០០ | ២៥០ |
| វេនល្ងាច | ៥៥០ | ៣០០ | ២៥០ |
| ថ្ងៃចុងសប្តាហ៍ | ៥៥០ | ៣០០ | ២៥០ |

### ១.៣. តម្លៃសិក្សាសម្រាប់និស្សិតដែលចុះឈ្មោះសិក្សាថ្នាក់បរិញ្ញាបត្រ ចាប់ពីឆ្នាំសិក្សា ២០១៦-២០១៧ ដល់ឆ្នាំសិក្សា ២០២០-២០២១

| វេនសិក្សា | បង់ប្រចាំឆ្នាំ (ដុល្លារ) | បង់០២ដងក្នុង០១ឆ្នាំ (ដុល្លារ) | | បង់០៤ដងក្នុង០១ឆ្នាំ (ដុល្លារ) | | | |
|---|---|---|---|---|---|---|---|
| | | លើកទី១ | លើកទី២ | លើកទី១ | លើកទី២ | លើកទី៣ | លើកទី៤ |
| **ថ្នាក់បរិញ្ញាបត្រ គ្រប់មុខជំនាញ លើកលែងមុខជំនាញបច្ចេកវិទ្យាហិរញ្ញវត្ថុ និងបច្ចេកវិទ្យាព័ត៌មានធុរកិច្ច** | | | | | | | |
| វេនព្រឹក | ១.២០០ | ៧០០ | ៥០០ | ៤៥០ | ២៥០ | ២៥០ | ២៥០ |
| វេនរសៀល | ១.១០០ | ៦០០ | ៥០០ | ៣៥០ | ២៥០ | ២៥០ | ២៥០ |
| វេនល្ងាច | ១.១០០ | ៦០០ | ៥០០ | ៣៥០ | ២៥០ | ២៥០ | ២៥០ |
| ថ្ងៃចុងសប្តាហ៍ | ១.១០០ | ៦០០ | ៥០០ | ៣៥០ | ២៥០ | ២៥០ | ២៥០ |
| **ថ្នាក់បរិញ្ញាបត្រ បច្ចេកវិទ្យាហិរញ្ញវត្ថុ(Fintech) និងបច្ចេកវិទ្យាព័ត៌មានធុរកិច្ច(Business IT)** | | | | | | | |
| វេនព្រឹក | ១.២០០ | ៧០០ | ៥០០ | ៤៥០ | ២៥០ | ២៥០ | ២៥០ |
| វេនរសៀល | ១.២០០ | ៧០០ | ៥០០ | ៤៥០ | ២៥០ | ២៥០ | ២៥០ |
| វេនល្ងាច | ១.២០០ | ៧០០ | ៥០០ | ៤៥០ | ២៥០ | ២៥០ | ២៥០ |
| ថ្ងៃចុងសប្តាហ៍ | ១.២០០ | ៧០០ | ៥០០ | ៤៥០ | ២៥០ | ២៥០ | ២៥០ |

### ១.៤. តម្លៃសិក្សាថ្នាក់បរិញ្ញាបត្ររងឯកទេស ថ្នាក់បរិញ្ញាបត្រ ចាប់ពីឆ្នាំសិក្សា ២០២១-២០២២តទៅ

| វេនសិក្សា | បង់ប្រចាំឆ្នាំ (ដុល្លារ) | បង់០២ដងក្នុង០១ឆ្នាំ (ដុល្លារ) | | បង់០៤ដងក្នុង០១ឆ្នាំ (ដុល្លារ) | | | |
|---|---|---|---|---|---|---|---|
| | | លើកទី១ | លើកទី២ | លើកទី១ | លើកទី២ | លើកទី៣ | លើកទី៤ |
| **ថ្នាក់បរិញ្ញាបត្ររងឯកទេស គ្រប់មុខជំនាញ** | | | | | | | |
| គ្រប់វេនសិក្សា | ៩៥០ | ៤៧៥ | ៤៧៥ | ២៣៧,៥០ | ២៣៧,៥០ | ២៣៧,៥០ | ២៣៧,៥០ |
| **ថ្នាក់បរិញ្ញាបត្រ គ្រប់មុខជំនាញ** | | | | | | | |
| គ្រប់វេនសិក្សា | ១.២០០ | ៦០០ | ៦០០ | ៣០០ | ៣០០ | ៣០០ | ៣០០ |

### ១.៥. តម្លៃសម្រាប់ ការប្រឡងសង (Re-exam) ការរៀនសង (Repeat-Course) និង ការរៀនត្រួតថ្នាក់-(Repeat-Classes) ថ្នាក់បរិញ្ញាបត្ររងឯកទេស និងថ្នាក់បរិញ្ញាបត្រ

- បង់ប្រាក់ចំនួន**១៥**ដុល្លារអាមេរិកសម្រាប់ការប្រឡងសងក្នុងមួយមុខវិជ្ជា
- បង់ប្រាក់ចំនួន**៦០**ដុល្លារអាមេរិកសម្រាប់ការរៀនសងក្នុងមួយមុខវិជ្ជា(៥០% នៃ១មុខវិជ្ជា)០
- បង់ប្រាក់ចំនួន**៦០**ដុល្លារអាមេរិកសម្រាប់ការរៀនត្រួតថ្នាក់ក្នុងមួយមុខវិជ្ជា(៥០% នៃ១មុខវិជ្ជា)

### ១.៦. តម្លៃសិក្សាថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់គ្រប់មុខជំនាញ

| វេនសិក្សា | បង់ប្រចាំឆ្នាំ (ដុល្លារ) | បង់០២ដងក្នុង០១ឆ្នាំ (ដុល្លារ) | | បង់០៤ដងក្នុង០១ឆ្នាំ (ដុល្លារ) | | | |
|---|---|---|---|---|---|---|---|
| | | លើកទី១ | លើកទី២ | លើកទី១ | លើកទី២ | លើកទី៣ | លើកទី៤ |
| **ថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់គ្រប់មុខជំនាញ** | | | | | | | |
| គ្រប់វេនសិក្សា | ២.២០០ | ១.១០០ | ១.១០០ | ៥៥០ | ៥៥០ | ៥៥០ | ៥៥០ |

### ១.៧. តម្លៃសក្សាសម្រាប់ ថ្នាក់បំប៉ន ការប្រឡងសង (Re-exam) ការរៀនសង (Repeat-Course) និង ការរៀនត្រួតថ្នាក់-(Repeat-Classes) ថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់

- បង់ថ្លៃសិក្សាចំនួន**៥០**ដុល្លារអាមេរិកសម្រាប់ថ្នាក់បំប៉នបរិញ្ញាបត្រជាន់ខ្ពស់ដែលត្រូវរៀនរយៈពេល**៣០**ម៉ោង
- បង់ថ្លៃសិក្សាចំនួន**៧០**ដុល្លារអាមេរិកសម្រាប់ថ្នាក់បំប៉នបរិញ្ញាបត្រជាន់ខ្ពស់ដែលត្រូវរៀនរយៈពេល**៤៥**ម៉ោង
- បង់ប្រាក់ចំនួន**៣០**ដុល្លារអាមេរិកសម្រាប់ការប្រឡងសងក្នុងមួយមុខវិជ្ជា
- បង់ប្រាក់ចំនួន**១១០**ដុល្លារអាមេរិកសម្រាប់ការរៀនសងក្នុងមួយមុខវិជ្ជា(៥០% នៃ១មុខវិជ្ជា)
- បង់ប្រាក់ចំនួន**២២០**ដុល្លារអាមេរិកសម្រាប់ការរៀនត្រួតថ្នាក់ក្នុងមួយមុខវិជ្ជា

**សំគាល់៖**

វិទ្យាស្ថាន ពាណិជ្ជសាស្ត្រ អេស៊ីលីដា ផ្តល់ជូន slide មេរៀន(soft and hard copy) ដល់និស្សិតដោយឥតគិតថ្លៃ សម្រាប់ថ្នាក់បំប៉នបរិញ្ញាបត្រជាន់ខ្ពស់។

## ២. គោលការណ៍ និងនីតិវិធីបង់ថ្លៃសិក្សា

ផ្នែកគណនេយ្យ និងប្រតិបត្តិការ នៃការិយាល័យផែនការ និងហិរញ្ញវត្ថុ ទទួលការបង់ថ្លៃសិក្សា របស់ សិស្ស-និស្សិត ដោយផ្អែកលើតារាងតម្លៃដែលបានកំណត់ដោយគណៈកម្មាធិការកំណត់ថ្លៃរបស់វិទ្យាស្ថាន។

### ២.១ ការបង់ថ្លៃសិក្សា

- **លក្ខខណ្ឌបង់ថ្លៃសិក្សា**

**និស្សិតថ្មី**

និស្សិត ត្រូវធ្វើការបង់ថ្លៃសិក្សា ឱ្យបានមុនកាលបរិច្ឆេទចូលសិក្សា និង/ឬថ្លៃសេវារដ្ឋបាលផ្សេងៗទៀត យោងទៅតាមការកំណត់របស់វិទ្យាស្ថាន រៀងរាល់ម៉ោងធ្វើការ។

**និស្សិតចាស់**

- និស្សិត អាចធ្វើការបង់ថ្លៃសិក្សា និង/ឬថ្លៃសេវាផ្សេងៗទៀត (សម្រាប់ឆមាសថ្មី) ចាប់ពីថ្ងៃប្រកាសលទ្ធផលឆមាសចាស់ រហូតដល់១៥ថ្ងៃ (រាប់បញ្ចូលទាំងថ្ងៃឈប់សម្រាក) ក្រោយឆមាសថ្មីចាប់ផ្តើម រៀងរាល់ម៉ោងធ្វើការ។
- និស្សិត ត្រូវបង់ថ្លៃប្រលងសងចំនួន US$ ១៥ (ដប់ប្រាំដុល្លារសហរដ្ឋអាមេរិកគត់) សម្រាប់ការប្រលងសងលើមុខវិជ្ជានីមួយៗ។
- សម្រាប់មុខវិជ្ជាដែលត្រូវសិក្សាឡើងវិញ និស្សិត ត្រូវបង់ថ្លៃសិក្សាលើមុខវិជ្ជា នីមួយៗ ចំនួន ៥០% ចាប់ពីថ្ងៃប្រកាស លទ្ធផលឆមាសចាស់ រហូតដល់ ១៥ថ្ងៃ (រាប់បញ្ចូលទាំងថ្ងៃឈប់សម្រាក) ក្រោយឆមាសថ្មីចាប់ផ្តើមនៅរៀងរាល់ម៉ោងធ្វើការ។

- **ការស្នើសុំពន្យារពេលបង់ថ្លៃសិក្សា**
  - ករណីនិស្សិតមិនមានលទ្ធភាពបង់ថ្លៃសិក្សា និង/ឬថ្លៃសេវាផ្សេងៗទៀត តាមកាលកំណត់ ដូចមានចែងនៅក្នុងលក្ខខណ្ឌបង់ថ្លៃសិក្សាខាងលើ និស្សិតអាចមកទំនាក់ទំនងជាមួយការិយាល័យផែនការ និងហិរញ្ញវត្ថុ ដើម្បីស្នើសុំពន្យារពេលបង់ថ្លៃ សិក្សា **(PFOF-PPP-01)** ឱ្យបានមុនកាលបរិច្ឆេទកំណត់។
  - ប្រធានការិយាល័យផែនការ និងហិរញ្ញវត្ថុ មានសិទ្ធិអនុម័តលើ សំណើសុំពន្យារពេលបង់ថ្លៃសិក្សា រួចចម្លងជូនការិយាល័យសិក្សា និងកិច្ចការនិស្សិត ០១ច្បាប់ ដើម្បីរក្សាទុកជាព័ត៌មាន។

**សំគាល់៖**

សុពលភាពនៃការស្នើសុំពន្យារពេលបង់ថ្លៃសិក្សា មានរយៈពេល **១៥ថ្ងៃ** (រាប់បញ្ចូលទាំងថ្ងៃឈប់សម្រាក) បន្តទៀត។

## ២.២ ជំរើសនៃការបង់ថ្លៃសិក្សា

និស្សិត អាចជ្រើសរើសបង់ថ្លៃសិក្សា និង/ឬថ្លៃសេវាផ្សេងៗ ដែលវិទ្យាស្ថានបានកំណត់ដូចខាងក្រោម៖

- **ការបង់ថ្លៃសិក្សាពេញមួយឆ្នាំសិក្សា (Full Payment)**
  ជាការបង់ថ្លៃសិក្សា និង/ឬថ្លៃសេវាផ្សេងៗ ពេញមួយឆ្នាំសិក្សា ។
- **ការបង់ថ្លៃសិក្សាមួយឆមាស (Semester Payment)**
  ជាការបង់ថ្លៃសិក្សា និង/ឬថ្លៃសេវាផ្សេងៗ ទៅតាមឆមាសសិក្សា(មួយឆ្នាំបង់ពីរដង) ។
- **ការបង់ថ្លៃសិក្សាតាមដំណាក់កាល (Installment Payment)**
  ជាការបង់ថ្លៃសិក្សា និង/ឬថ្លៃសេវាផ្សេងៗតាមបណ្តាក់ ៤ដងក្នុងមួយឆ្នាំ (២ឆមាស) ដូចខាងក្រោម៖

**<u>លើកទី១</u>** : ឆមាសទី១ បង់ ៣១% នៃថ្លៃសិក្សាមួយឆ្នាំ មុនកាលបរិច្ឆេទសិក្សា។

**<u>លើកទី២</u>** : ឆមាសទី១ បង់ ២៣% នៃថ្លៃសិក្សាមួយឆ្នាំ ៦០ថ្ងៃ បន្ទាប់ពីបរិច្ឆេទសិក្សា។

**<u>លើកទី៣</u>** : ឆមាសទី២ បង់ ២៣% នៃថ្លៃសិក្សាមួយឆ្នាំ មុនកាលបរិច្ឆេទសិក្សា។

**<u>លើកទី៤</u>** : ឆមាសទី២ បង់ ២៣% នៃថ្លៃសិក្សាមួយឆ្នាំ ៦០ថ្ងៃ បន្ទាប់ពីបរិច្ឆេទសិក្សា។

## ២.៣ ការពិន័យ

ករណីនិស្សិតយឺតយ៉ាវក្នុងការបង់ថ្លៃសិក្សា និង/ឬថ្លៃសេវាផ្សេងៗ តាមកាលកំណត់ ដូចមានចែងក្នុង**ចំណុច៤.១** ខាងលើ និស្សិតរូបនោះនឹង ត្រូវទទួលរងការពិន័យ US$ **០,៤០** (សូន្យដុល្លារសហរដ្ឋអាមេរិកនិងសែសិបសេន) ក្នុងមួយថ្ងៃ សម្រាប់រយៈពេលអតិបរមា **១៥ថ្ងៃ** ឬ US$ **៦** (ប្រាំមួយដុល្លារសហរដ្ឋអាមេរិកគត់) ដោយគិតចាប់ពីកាលបរិច្ឆេទកំណត់ដូចមានចែងក្នុង **ចំណុច២.១ និង/ឬ ចំណុច ២.២**។

ការយឺតយ៉ាវលើសរយៈពេលកំណត់ដូចមានចែងក្នុង**ចំណុច២.១** និស្សិតត្រូវមកទំនាក់ទំនងជាមួយ ការិយាល័យសិក្សា និងកិច្ចការនិស្សិត ដើម្បីធ្វើសំណើសុំព្យួរការសិក្សាជាកំហិត។

## ២.៤ ការព្យួរ/រក្សាថ្លៃសិក្សា

វិទ្យាស្ថាន អនុញ្ញាតឱ្យនិស្សិត ដែលបានបង់ថ្លៃសិក្សា និង/ឬថ្លៃសេវាផ្សេងៗរួច (ទាំងនិស្សិត ចាស់ និងថ្មី) ស្នើសុំព្យួរ/រក្សាថ្លៃសិក្សាបាន ដោយយោងលើការអនុមតិរបស់ការិយាល័យសិក្សា និងកិច្ចការនិស្សិត លើសំណើសុំឈប់សិក្សា/ព្យួរការសិក្សា ដូចមានចែងក្នុង**គោលការណ៍ការសិក្សាថ្នាក់បរិញ្ញាបត្ររង និងបរិញ្ញាបត្រ**។

**<u>សម្គាល់៖</u>**
វិទ្យាស្ថានព្យួរ/រក្សាថ្លៃសិក្សា ជូននិស្សិតវិញ ត្រឹមរយៈពេលអតិបរមា ២វគ្គសិក្សា ប៉ុណ្ណោះ ។ ក្នុងករណីនិស្សិត មិនត្រឡប់មកសិក្សាវិញ វិទ្យាស្ថាន នឹងកាត់ថ្លៃសិក្សា ១០០% ដោយមិនអនុញ្ញាតឱ្យស្នើសុំដកថ្លៃសិក្សា ដែលនៅសល់វិញឡើយ ទោះក្នុងលក្ខខណ្ឌណាក៏ដោយ។

## ២.៥ ការប្រគល់ថ្លៃសិក្សាត្រឡប់វិញ

វិទ្យាស្ថាន នឹងប្រគល់ថ្លៃសិក្សា និង/ឬថ្លៃសេវាផ្សេងៗ ដែលបានបង់រួច ឬថ្លៃសិក្សាដែលនៅសល់ត្រឡប់ជូននិស្សិតវិញ ក្នុងករណីដូចខាងក្រោម ៖

- វិទ្យាស្ថាន មិនអាចបើកវគ្គសិក្សាជូនដល់និស្សិតតាមកាលកំណត់ ដោយសារមូលហេតុផ្ទាល់ខ្លួន និស្សិតអាចស្នើសុំដកថ្លៃសិក្សា និង/ឬថ្លៃសម្ភារសិក្សាវិញ ១០០% ប្រសិនបើមិនមានបំណងរង់ចាំសិក្សាជាមួយវិទ្យាស្ថាន ដោយភ្ជាប់មកជាមួយនូវសំណើសុំលុបចោលវគ្គហ្វឹកហ្វឺន ដែលចេញដោយការិយាល័យសាមីពាក់ព័ន្ធ រួមជាមួយនិងវិក្កយបត្រដែលនិស្សិតបានបង់រួច។
- និស្សិតដែលបានបង់ថ្លៃសិក្សាមុនកាលបរិច្ឆេទកំណត់ចូលសិក្សា ក្រោយមកនិស្សិតបានប្រលងជាប់ជាបុគ្គលិកធនាគារ អេស៊ីលីដា ភីអិលស៊ី មុនកាលបរិច្ឆេទកំណត់ចូលសិក្សា វិទ្យាស្ថាន នឹងបង្វែរសាច់ប្រាក់ដែលបានបង់ថ្លៃសិក្សារួចជូនទៅនិស្សិតវិញ ដោយផ្អែកទៅតាមអាត្រាបញ្ចុះតម្លៃសិក្សាសម្រាប់បុគ្គលិកធនាគារ អេស៊ីលីដា ភីអិលស៊ី ដោយភ្ជាប់មកជាមួយនូវសេចក្ដីសម្រេច ស្ដីពីការតែងតាំងមុខងារកម្មករនិយោជិកចូលបម្រើការងារ អត្តសញ្ញាណប័ណ្ណការងារ រួមជាមួយ និងវិក្កយបត្រ ដែលនិស្សិតបានបង់រួច។
- និសិ្សតដែលបានបង់ថ្លៃសិក្សាមុនកាលបរិច្ឆេទកំណត់ចូលសិក្សា ក្រោយមកនិសិ្សតមានសាច់-ញាតិ ឬសហព័ន្ធជាបុគ្គលិកធនាគារ អេស៊ីលីដា ភីអិលស៊ី មុនកាលបរិច្ឆេទកំណត់ចូលសិក្សា វិទ្យាស្ថាន នឹងបង្វែរសាច់ប្រាក់ដែលបានបង់ថ្លៃសិក្សារួច ជូនទៅនិស្សិតវិញ ដោយផ្អែកទៅតាមអត្រាបញ្ចុះតម្លៃសិក្សា សម្រាប់សាច់ញាតិ ឬសហព័ន្ធជាបុគ្គលិកធនាគារ អេស៊ីលីដា ភីអិលស៊ី ដោយភ្ជាប់មកជាមួយនូវ សេចក្ដីប្រកាសសាច់ញាតិ អត្តសញ្ញាណប័ណ្ណការងាររបស់សាច់ញាតិ រួមជាមួយនិងវិក្កយបត្រ ដែលនិស្សិតបានបង់រួច។
- និសិ្សតដែលបានបង់ថ្លៃសិក្សាមុនកាលបរិច្ឆេទកំណត់ចូលសិក្សា ក្រោយមកនិសិ្សតបានប្រលងជាប់អាហា-រូបករណ៍នៅវិទ្យាស្ថាន ពាណិជ្ជសាស្ត្រ អេស៊ីលីដា វិទ្យាស្ថាន នឹងបង្វែរសាច់ប្រាក់ដែលបានបង់ថ្លៃសិក្សារួចជូនទៅនិសិ្សតវិញ ដោយផ្អែកទៅលើលទ្ធផលប្រលងអាហារូបករណ៍ និងភ្ជាប់មកជាមួយនូវលទ្ធផលប្រលងអាហារូបករណ៍របស់និស្សិត រួមជាមួយនិងវិក្កយបត្រដែលនិស្សិតបានបង់រួច។
- និសិ្សត ដែលបានបង់ថ្លៃសិក្សាមុនកាលបរិច្ឆេទកំណត់ចូលសិក្សា ក្រោយមកនិសិ្សត បានបាត់បង់សមត្ថភាពសិក្សា មុនកាលបរិច្ឆេទកំណត់ចូលសិក្សា វិទ្យាស្ថាន នឹងបង្វែរសាច់ប្រាក់ដែលបានបង់ថ្លៃសិក្សារួច ជូនទៅនិសិត្សវិញ ដោយភ្ជាប់មកជាមួយនូវ វិជ្ជបញ្ជាពីមន្ទីពេទ្យ សំណើសុំដកសាច់ប្រាក់ពីអាណាព្យាបាល ឬពីសាច់ញាតិរបស់និស្សិត រួមជាមួយនិងវិក្កយបត្រដែលនិស្សិតបានបង់រួច។

ការិយាល័យសិក្សា និងកិច្ចការនិសិ្សតមានតួនាទីរៀបចំសំណើសុំបង្វែរសាច់ប្រាក់ថ្លៃសិក្សា និង/ឬថ្លៃសម្ភារសិក្សាជូននិស្សិតវិញ (សំណើសុំការអនុញ្ញាតលុបចោលវគ្គសិក្សា/ពន្យារកាលបរិច្ឆេទចូលសិក្សា និង/ឬ បង្វែរសាច់ប្រាក់ជូនសិស្ស-និសិ្សត ឬសាធារណជន) និងបញ្ជូនមក ការិយាល័យផែនការ និងហិរញ្ញវត្ថុ។

## ២.៦ ការស្នើសុំលិខិតបញ្ជាក់ផ្សេងៗ

ករណីនិស្សិតមានតម្រូវការស្នើសុំធ្វើលិខិតបញ្ជាក់ផ្សេងៗ លើសពីចំនួនកំណត់ និស្សិតត្រូវធ្វើការទូទាត់តាមការកំណត់តម្លៃរបស់វិទ្យាស្ថាន។

## ២.៧ ការមិនអាចប្រគល់ថ្លៃសិក្សា និង/ឬថ្លៃសម្ភារសិក្សាត្រឡប់វិញ

វិទ្យាស្ថាន មិនអាចប្រ គល់ថ្លៃសិក្សា និង/ឬថ្លៃសម្ភារសិក្សាដែលបានបង់រួចត្រឡប់ ជូនសិស្ស-និស្សិតវិញក្នុងករណីដូចខាងក្រោម៖

- សិស្ស-និស្សិតដែលបានបង់ថ្លៃសិក្សារួចហើយ មិនអាចដកប្រាក់វិញបានទេ ក្នុងករណីមិនមានចែងនៅក្នុងចំណុច ៣.៥ និង ចំណុច ៤.៥។

សម្រាប់ព័ត៌មានបន្ថែម សិស្ស-និស្សិត ត្រូវមកទំនាក់ទំនងជាមួយផ្នែកគណនេយ្យ និងប្រតិបត្តិការ នៃការិយាល័យផែនការ និងហិរញ្ញវត្ថុ អំពីការមិនអាចប្រគល់ថ្លៃសិក្សា និង/ឬថ្លៃសម្ភារសិក្សាត្រឡប់វិញ។

## ២.៨ វិធីសាស្ត្របង់ប្រាក់

និស្សិត អាចបង់ថ្លៃសិក្សា និងឬ/ថ្លៃសម្ភារសិក្សា បានតាមរយៈ៖

- Scan QR codeចូលគណនីរបស់វិទ្យាស្ថាន
- ផ្ទេរតាមទូរសព្ទ(ACLEDA Mobile App)ចូលគណនីរបស់វិទ្យាស្ថាន
- បង់តាមបញ្ជរធនាគារ អេស៊ីលីដា ភីអិលស៊ីគ្រប់សាខាខេត្តក្រុងដែលនៅជិតបំផុត
- បង់ជាសាច់ប្រាក់ផ្ទាល់
- ម៉ាស៊ីនឆូតកាត និង
- ប្រព័ន្ធសេវាផ្សេងៗរបស់ធនាគារ អេស៊ីលីដា ភីអិលស៊ី ដែលមាននៅផ្នែកគណនេយ្យ និងប្រតិបត្តិការ នៃការិយាល័យផែនការ និងហិរញ្ញវត្ថុ ឬតាមរយៈគណនីរបស់វិទ្យាស្ថាន ដែលមាននៅធនាគារ អេស៊ីលីដា ភីអិលស៊ី រៀងរាល់ម៉ោងធ្វើការ។




និស្សិតវិទ្យាស្ថាន ពាណិជ្ជសាស្ត្រ អេស៊ីលីដា ទស្សនកិច្ចសិក្សា នៅក្រុមហ៊ុន Integrated Logistics Service Co., Ltd.

# សេវានិស្សិត

## ១. ព័ត៌មានស្តីពីសេវានិស្សិត

### ១.១ ការប្រឹក្សានិស្សិត

**ការប្រឹក្សា** មានន័យថា ជាពេលវេលាមួយដែលនិស្សិតស្វែងរកការជួបប្រាស្រ័យដោយផ្ទាល់ ជាមួយសាស្ត្រាចារ្យ ដើម្បីលើកឡើងអំពីបញ្ហានានា ដែលពួកគេមាននៅក្នុងអំឡុងពេលសិក្សាលើមុខវិជ្ជានីមួយៗ។

### ១.២ ប្រភេទនៃបញ្ហាដែលអាចប្រឹក្សា

វិទ្យាស្ថាន បានកំណត់បញ្ហាដែលអាចប្រឹក្សាជាពីរប្រភេទ៖

**ក. បញ្ហាការសិក្សា**

បញ្ហាការសិក្សា និស្សិតអាចធ្វើការពិភាក្សាជាមួយគ្រូបង្ហាត់ផ្ទាល់ ឬបុគ្គលិកសិក្សាពាក់ព័ន្ធដទៃទៀត ដែលត្រូវបានចាត់តាំងដោយវិទ្យាស្ថាន បញ្ហាទាំងនោះរួមមាន៖

- កាលវិភាគសិក្សា
- ការជ្រើសរើសមុខវិជ្ជាសិក្សា
- ការសុំជំនួយគ្រូបង្ហាត់ផ្ទាល់
- ការរីកចម្រើនលើការសិក្សា
- អន្តរកម្មជាមួយសាស្ត្រាចារ្យ
- បណ្តឹងជំទាស់លើការវាយតម្លៃការសិក្សា។ល។

**ខ. បញ្ហាសុខុមាលភាពនិស្សិត**

និស្សិតដែលមានបំណងស្នើសុំការប្រឹក្សាលើសុខុមាលភាព ត្រូវមកទំនាក់ទំនងជាមួយផ្នែកគាំទ្រការសិក្សា និងប្រឹក្សាអាជីពនិស្សិត នៃការិយាល័យសិក្សា និងកិច្ចការនិស្សិត។ បញ្ហាទាំងនោះរួមមា ៖

- សុខភាពផ្លូវកាយ
- សុខភាពផ្លូវចិត្ត
- សុខភាពផ្លូវអារម្មណ៍
- ប្រឹក្សាផ្លូវច្បាប់
- ហិរញ្ញវត្ថុ ឬ
- សាសនា

រាល់ការណាត់ជួបត្រូវបានធ្វើឡើងដោយសម្ងាត់ និងមិនគិតកម្រៃ។ ប្រសិនបើនិស្សិតមានតម្រូវការជំនួយបន្ថែម និស្សិតនឹងត្រូវបានផ្តល់យោបល់ឱ្យទៅជួបអ្នកជំនាញវិជ្ជាជីវៈខាងក្រៅ ដើម្បីជួយដោះស្រាយ។

### ១.៣ ការចុះហាត់ការ

និស្សិតគ្រប់ជំនាញគ្រប់កម្រិត របស់វិទ្យាស្ថានត្រូវបានកំណត់ឱ្យចុះហាត់ការទៅតាមកម្មវិធីដែលវិទ្យាស្ថានបានរៀបចំ។ ជារួមការចុះហាត់ការ គឺជាការផ្តល់ឱកាសដល់និស្សិតក្នុងការទទួលយកនូវ បទពិសោធន៍ និងវប្បធម៌ការងារដ៏មានតម្លៃពីធនាគារទាក់ទងនឹងចំណេះជំនាញ ដែលពួកគេបានសិក្សារយៈពេលកន្លងមក។

### ក. មុខវិជ្ជាជំនាញជ្រើសរើស

ក្រោយពីបានសិក្សាមុខវិជ្ជាជំនាញរួចហើយ វិទ្យាស្ថានតម្រូវឱ្យនិស្សិត **(បរិញ្ញាបត្ររង និងបរិញ្ញាបត្រ)** ជ្រើសរើសមុខជំនាញដែលបានសិក្សារួច ដើម្បីធ្វើការចុះហាត់ការ ទៅតាមឆមាសដូចខាងក្រោម៖

- កម្រិតបរិញ្ញាបត្ររង
  - ឆ្នាំទី២ ឆមាសទី២ : ជំនាញទីផ្សារ/ឥណទាន/ប្រតិបត្តិការ
- កម្រិតបរិញ្ញាបត្រ
  - ឆ្នាំទី៣ ឆមាសទី២ : ជំនាញទីផ្សារ/ឥណទាន/ប្រតិបត្តិការ

### ខ. មុខវិជ្ជាជំនាញជម្រើសសម្រាប់ចុះហាត់ការ

- កម្រិតបរិញ្ញាបត្ររង ត្រូវចុះហាត់ការនៅឆ្នាំទី២ ឆមាសទី២
- កម្រិតបរិញ្ញាបត្រ ត្រូវចុះហាត់ការនៅឆ្នាំទី៤ ឆមាសទី១

**សម្គាល់៖** មុខវិជ្ជាសម្រាប់សិក្សាខាងលើ សម្រាប់និស្សិតជំនាញហិរញ្ញវត្ថុ និងធនាគារ។ ជំនាញ និងកម្រិតថ្នាក់ដទៃទៀតក្រៅពីនេះ នឹងត្រូវបានអនុវត្តទៅតាមកម្មវិធីសិក្សាជាក់ស្តែងតាមការស្នើសុំរបស់វិទ្យាស្ថាន។

### គ. រយៈពេលនៃការចុះហាត់ការ

ការចុះហាត់ការនៅធនាគារ អេស៊ីលីដា ភីអិលស៊ី ត្រូវបានកំណត់រយៈពេល ដូចខាងក្រោម៖

- រយៈពេលអតិបរមា ៣សប្តាហ៍ (១២០ម៉ោង)
- ចុះហាត់ការ ៨ម៉ោង ក្នុងមួយថ្ងៃ និង ៥ថ្ងៃ ក្នុងមួយសប្តាហ៍ពីថ្ងៃចន្ទដល់ថ្ងៃសុក្រ

### ឃ. ចំនួនក្រេឌីតនៃការចុះហាត់ការ

- និស្សិតដែលចុះហាត់ការទទួលបានពិន្ទុចំនួន ៤ក្រេឌីត

### ង. ពេលវេលាចុះហាត់ការ

ពេលវេលានៃការចុះហាត់ការត្រូវបានរៀបចំ ដូចខាងក្រោម ៖

- ពេលព្រឹក : ចាប់ពីម៉ោង ០៧ : ៣០ ដល់ម៉ោង ១២ : ០០ និង
- ពេលរសៀល : ចាប់ពីម៉ោង ១៣ : ០០ ដល់ម៉ោង ១៦ : ៣០

## ១.៤ សេវាបន្ទប់កុំព្យូទ័រ និងបច្ចេកវិទ្យាផ្សេងៗ

វិទ្យាស្ថានបានបំពាក់ប្រព័ន្ធ Internet ល្បឿនលឿន ដើម្បីគាំទ្រប្រតិបត្តិការការងារប្រចាំថ្ងៃ និងការស្រាវជ្រាវរបស់គ្រូបង្រៀន និងនិស្សិតឱ្យប្រព្រឹត្តទៅដោយរលូន។ ជាក់ស្តែងវិទ្យាស្ថានបានបំពាក់នូវ Internet/WIFI តាមថ្នាក់រៀន, បន្ទប់កុំព្យូទ័រ, បន្ទប់គ្រូបង្រៀនពេញម៉ោង, បណ្ណាល័យ, Canteen និងនៅតាមទីបរិវេណសម្រាប់និស្សិតអង្គុយសិក្សាម្នាក់ឯង និងជាក្រុម។

### ការប្រើប្រាស់កុំព្យូទ័ររបស់បណ្ណាល័យ

សិស្ស/និស្សិត អាចស្នើសុំប្រើប្រាស់កុំព្យូទ័ររបស់បណ្ណាល័យ ដោយកំណត់រយៈពេល **៣ម៉ោង** សម្រាប់ ការស្នើសុំ១លើក។ ការប្រើប្រាស់កុំព្យូទ័ររបស់បណ្ណាល័យ គឺដើម្បីធ្វើការសិក្សាស្រាវជ្រាវ ឬការវាយអត្ថបទផ្សេងៗ តែប៉ុណ្ណោះ ករណីការប្រើប្រាស់កុំព្យូទ័រខុសពីការកំណត់បណ្ណារក្ស/បុគ្គលិកបណ្ណាល័យ នឹងបញ្ឈប់ការប្រើប្រាស់ភ្លាម។

## ២. វិន័យ និងក្រមសីលធម៌

### ២.១ វិន័យ

**ក. ឯកសណ្ឋាន**

ការស្លៀកពាក់ បង្ហាញនូវកិរិយាថ្លៃថ្នូររបស់បុគ្គល និងអត្តសញ្ញាណរបស់វិទ្យាស្ថាន។ ដើម្បីរក្សាបាននូវកិរិយា និងអត្តសញ្ញាណដូចបានរៀបរាប់នៅក្នុងអំឡុងពេលសិក្សា វិទ្យាស្ថានតម្រូវឱ្យនិស្សិត ស្លៀកពាក់ឯកសណ្ឋានតាមការកំណត់ ដូចមានចែងក្នុងគោលការណ៍ឯកសណ្ឋាននិស្សិត វិទ្យាស្ថាន លើកលែងតែនិស្សិតដែលសិក្សាវេនយប់។

**ខ. ប័ណ្ណសម្គាល់ខ្លួន**

និស្សិតត្រូវពាក់ប័ណ្ណសម្គាល់ខ្លួនជាប់ជាប្រចាំទាំងក្នុងថ្នាក់រៀន និងក្នុងទីបរិវេណវិទ្យាស្ថាន។

### ២.២ ក្រមសីលធម៌

**ក. ការប្រព្រឹត្ត**

- គ្រប់ពេលវេលា និស្សិតត្រូវប្រព្រឹត្តការសមគួរចំពោះគណៈគ្រប់គ្រងបុគ្គលិកវិទ្យាស្ថាន និងនិស្សិតផងទាំងពួង ដោយអនុលោមតាមក្រមសីលធម៌និស្សិតវិទ្យាស្ថាន
- និស្សិតត្រូវចូលរួមរៀនសូត្រឱ្យបានទៀងទាត់ និងទាន់ពេលវេលាតាមកម្មវិធីសិក្សា ហើយត្រូវសហប្រតិបត្តិការឱ្យបានល្អប្រពៃជាមួយគណៈគ្រប់គ្រងបុគ្គលិក វិទ្យាស្ថានក្នុងការធ្វើសម្រង់វត្តមាននិស្សិត នៅពេលមានតម្រូវការ និងត្រូវដាក់កិច្ចការដែលបានដាក់ឱ្យធ្វើជូនវិទ្យាស្ថាន ឱ្យបានទាន់ពេលវេលាកំណត់
- និស្សិតមិនត្រូវស្ថិតនៅក្រោមឥទ្ធិពលនៃសុរាមេរ័យ និងសារធាតុញៀនដែលជាឧបសគ្គដល់ការសិក្សាការប្រព្រឹត្តល្អ និងសុវត្ថិភាពរបស់និស្សិត និងអ្នកដទៃទៀតឡើយ នៅពេលមកសិក្សា។

**ខ. ក្នុងថ្នាក់រៀន**

- និស្សិតត្រូវគោរពពេលវេលា និងកាលវិភាគរបស់វិទ្យាស្ថានឱ្យបានម៉ឺងម៉ាត់។ និស្សិតត្រូវយកចិត្តទុកដាក់រៀនសូត្រ រក្សាសណ្តាប់ធ្នាប់ របៀបរៀបរយ និងមិនធ្វើអ្វីដែលនាំឱ្យរំខានដល់មិត្តភក្តិរួមថ្នាក់ជាមួយ
- ពេលគ្រូ ឬភ្ញៀវអញ្ជើញចូលក្នុងថ្នាក់រៀន និស្សិតត្រូវរក្សាភាពស្ងៀមស្ងាត់ និងសម្តែងនូវអាកប្បកិរិយាថ្លៃថ្នូរ
- ពេលគ្រូអវត្តមាន ឬមកយឺតរយៈពេលលើសពី១៥នាទី និស្សិតត្រូវរក្សាភាពស្ងៀមស្ងាត់ ហើយប្រធានថ្នាក់ ឬតំណាងនិស្សិតត្រូវមកទំនាក់ទំនង និងទទួលព័ត៌មានពីការិយាល័យសិក្សា និងកិច្ចការនិស្សិត
- ពេលចេញលេង និស្សិតត្រូវប្រកាន់អាកប្បកិរិយាថ្លៃថ្នូរ រក្សាសណ្តាប់ធ្នាប់ របៀបរៀបរយ ពោលគឺ មិនត្រូវប្រលែងគ្នា ស្រែកឡូឡា ឬឈ្លោះប្រកែកគ្នាឡើយ
- ពេលចេញក្រៅថ្នាក់ ឬចេញទៅផ្ទះមុនម៉ោង ដោយមានធុរៈចាំបាច់ ឬមានជំងឺផ្ទាល់ខ្លួន និស្សិតត្រូវសុំអនុញ្ញាតពីគ្រូដែលកំពុងបង្រៀន
- និស្សិតមិនត្រូវនាំមិត្តភក្តិពីក្រៅមកចូលក្នុងថ្នាក់រៀនខ្លួនឡើយ
- ហាមប្រើប្រាស់ទូរស័ព្ទ ឬវិទ្យុទាក់ទងក្នុងពេលកំពុងសិក្សា
- ចំណីអាហារ និងភេសជ្ជៈ អាចអនុញ្ញាតឱ្យទទួលទានបាន តែនៅក្នុងកន្លែងមួយចំនួនដែលវិទ្យាស្ថានបានកំណត់តែប៉ុណ្ណោះ។ មិនអនុញ្ញាតឱ្យទទួលទានចំណីអាហារ និងភេសជ្ជៈ នៅក្នុងបន្ទប់រៀន បណ្ណាល័យ បន្ទប់ពិសោធន៍ ឬបន្ទប់កុំព្យូទ័រឡើយ។

**គ. ក្នុងបរិវេណ វិទ្យាស្ថាន ពាណិជ្ជសាស្ត្រ អេស៊ីលីដា**

**និស្សិតមិនត្រូវ ៖**

- ជក់បារី សេពគ្រឿងស្រវឹង និងប្រើប្រាស់ ឬជួញដូរគ្រឿងញៀនឡើយ
- រៀបចំបង្កើត និង/ឬចូលរួមលេងល្បែងស៊ីសងគ្រប់ប្រភេទ ឬប្រព្រឹត្តអំពើពាលា ដែលខុសប្រពៃណីជាតិ
- ធ្វើការជួញដូរ ឬធ្វើសេវាកម្មគ្រប់បែបយ៉ាង
- ធ្វើសកម្មភាពណាមួយដែលនាំឱ្យប៉ះពាល់ដល់កិត្តិយស និងផលប្រយោជន៍របស់វិទ្យាស្ថាន និងសង្គមជាតិ
- ស្រែកឡូឡា ឬប្រើពាក្យអាសអាភាស អាសគ្រាម និងមានអាកប្បកិរិយាមិនសមរម្យ ដែលប្រាសចាក អំពីទំនៀមទំលាប់ខ្មែរ
- បង្កើត ដឹកនាំ និង/ឬចូលរួមសកម្មភាពណាមួយ ដូចជាការប្រឆាំង ការរាំងស្ទះ ការអុកឡុក ការធ្វើឱ្យ ខូចសណ្តាប់ធ្នាប់កិច្ចប្រជុំ ឬសន្និបាតជាផ្លូវការស្របច្បាប់ណាមួយដែលរៀបចំឡើងនៅក្នុងវិទ្យាស្ថាន ឬធ្វើសកម្មភាពណាមួយ ដែលជាការល្មើសទៅនឹងច្បាប់ បទបញ្ជា កិច្ចព្រមព្រៀង ធ្វើឱ្យប៉ះពាល់ដល់បេសកកម្ម អប់រំរបស់វិទ្យាស្ថានឡើយ
- ធ្វើឱ្យបាត់បង់សោភ័ណភាព និងធ្វើឱ្យខូចបរិស្ថានដូចជាៈ សរសេរគូសវាសលើជញ្ជាំង លើតុ ទ្វារ បង្អួចនៃបន្ទប់រៀន ចោលសំរាម ឬស្ករកៅស៊ូ និងខាកស្តោះលើជណ្តើរ លើកម្រាលឥដ្ឋ។ល។

**រាល់បាតុភាពអសកម្ម ត្រូវរាយការណ៍មកការិយាល័យបុគ្គលិក និងរដ្ឋបាល ឬជំនួយការភ្នាក់ងារបម្រើអតិថិជន ជាបន្ទាន់ដូចជា ៖**

- មានអគ្គិភ័យ
- និស្សិតមានជំងឺដែលត្រូវសង្គ្រោះជាបន្ទាន់
- និស្សិតឈ្លោះប្រកែកគ្នា
- មានអំពើចោរកម្ម
- មានសមាសភាព ឬមុខសញ្ញាមិនល្អដែលគួរឱ្យសង្ស័យ។ល។

## ៣. ដំណើរការ និងនីតិវិធីសម្រាប់ដោះស្រាយទំនាស់

**បណ្តឹងជំទាស់ (Appeal)** សំដៅដល់ការស្នើសុំឱ្យពិនិត្យឡើងវិញជាផ្លូវការនូវរាល់ការសម្រេចចិត្តរបស់វិទ្យាស្ថាន ឬបុគ្គលិកវិទ្យាស្ថាន ទៅលើដំណើរការសិក្សារបស់និស្សិត លទ្ធផលនៃការវាយតម្លៃ ការផ្តល់រង្វាន់ ឬសកម្មភាពទាំងឡាយណា ដែលប្រាសចាកគោលការណ៍ និងនីតិវិធី របស់វិទ្យាស្ថាន។

### ៣.១ សិទ្ធិនៃការប្តឹងជំទាស់

មានតែនិស្សិតរបស់វិទ្យាស្ថាន ពាណិជ្ជសាស្ត្រ អេស៊ីលីដា ប៉ុណ្ណោះដែលមានសិទ្ធិប្តឹងជំទាស់ទៅលើ ដំណើរការសិក្សា លទ្ធផលនៃការវាយតម្លៃ ការផ្តល់រង្វាន់ ឬសកម្មភាពទាំងឡាយណា ដែលប្រាសចាកគោលការណ៍ និងនីតិវិធី របស់វិទ្យាស្ថាន។

### ៣.២ ប្រភេទនៃបណ្តឹងជំទាស់

វិទ្យាស្ថាន បានបែងចែកបណ្តឹងជំទាស់ជាពីរប្រភេទ ដូចខាងក្រោម៖

**ក. បណ្តឹងសិក្សា (Academic Appeal)**

បណ្តឹងសិក្សា គឺជាបណ្តឹងដែលទាក់ទងនឹងការស្នើសុំឱ្យត្រួតពិនិត្យឡើងវិញនូវការសម្រេចចិត្តទាំងឡាយណាដែលពាក់ព័ន្ធនឹងដំណើរការសិក្សារបស់និស្សិត ឬការផ្តល់រង្វាន់សិក្សាផ្សេងៗ។ ករណីដែលនិស្សិតអាចដាក់ពាក្យបណ្តឹងសិក្សាមានដូចជា៖

- ការសម្រេចចិត្តដែលនាំឱ្យមានការរាំងស្ទះដល់ការសិក្សា។ ឧទាហរណ៍: ការមិនអនុញ្ញាតឱ្យចុះឈ្មោះចូលសិក្សាបន្ត
- ការសម្រេចចិត្តដែលរំខានដល់ការសិក្សារបស់និស្សិត។ ឧទាហរណ៍: ការមិនផ្តល់សិទ្ធិក្នុងការប្រលងឡើងវិញលើមុខវិជ្ជាដែលធ្លាក់ខុសពីនីតិវិធីកំណត់
- ភាពមិនប្រក្រតីក្នុងការដាក់ពិន្ទុ ឬវាយតម្លៃក្នុងអំឡុងពេលសិក្សា (on-going assessment) និងពេលប្រលង (examination)
- លម្អៀងក្នុងការផ្តល់រង្វាន់សិក្សា (Academic Award)
- សកម្មភាពរបស់គ្រូហ្វឹកហ្វឺនដែលប្រាសចាកនឹងគោលការណ៍ នីតិវិធី និងក្រមសីលធម៌របស់គ្រូហ្វឹកហ្វឺន។ ឧទាហរណ៍: គ្រូហ្វឹកហ្វឺនមិនលើកទឹកចិត្តការរៀនសូត្ររបស់និស្សិតមានដូចជា: រើសអើងក្នុងការឆ្លើយសំណួរ ការហាមឃាត់មិនឱ្យមានចម្ងល់ មិនឱ្យបញ្ចេញមតិ ឬមិនទទួលស្គាល់គំនិតចូលរួមរបស់និស្សិត ។ល។

**ខ. បណ្តឹងទូទៅ (Non-Academic Appeal)**

ក្រៅពីករណីរៀបរាប់ក្នុង (ចំណុច**ក**) និស្សិតមានសិទ្ធិប្តឹងជំទាស់ទៅនឹងការដាក់ទោសពិន័យផ្សេងៗ ពីវិទ្យាស្ថាន ឬពីបុគ្គលិកវិទ្យាស្ថាន លើការប្រតិបត្តិវិន័យ និងក្រមសីលធម៌ ដែលបានកំណត់ដោយ វិទ្យាស្ថាន ករណីដែលនិស្សិតយល់ឃើញថា កំពុងទទួលបាននូវភាពមិនស្មើគ្នាជាមួយនិស្សិតដូចគ្នា ទទួលរងនូវការដាក់ទោសពិន័យមិនសមហេតុផល ប្រាសចាកពីគោលការណ៍ ឬមិនមានចែងក្នុងគោលការណ៍។

## ៣.៣ មូលដ្ឋាននៃបណ្តឹងជំទាស់

ក្នុងករណីដែលនិស្សិតយល់ឃើញថា ខ្លួនកំពុងទទួលបាននូវភាពមិនប្រក្រតីក្នុងករណីសិក្សា ឬករណីទូទៅ និស្សិតគ្រប់រូបមានសិទ្ធិប្តឹងមកវិទ្យាស្ថានទៅតាមប្រភេទបណ្តឹងដែលបានកំណត់ក្នុងចំណុច៣.២។ ប៉ុន្តែរាល់បណ្តឹងទាំងអស់តម្រូវឱ្យមានមូលដ្ឋានច្បាស់លាស់ ដូចបញ្ជាក់ខាងក្រោម៖

**ក. បណ្តឹងមានសុពលភាព (Valid Ground)**

បណ្តឹងសិក្សា ឬបណ្តឹងទូទៅ ដែលវិទ្យាស្ថានចាត់ទុកថាជាបណ្តឹងមានសុពលភាព គឺបណ្តឹងដែល មានមូលដ្ឋាន ឬភស្តុតាងច្បាស់លាស់ដែលបង្ហាញពីផលប៉ះពាល់អវិជ្ជមានមកលើលទ្ធផលសិក្សា ឬផ្លូវចិត្តរបស់និស្សិតប្រាសចាកពីគោលការណ៍កំណត់ ឬមិនមានចែងក្នុងគោលការណ៍របស់វិទ្យាស្ថាន។

**ខ. បណ្តឹងគ្មានសុពលភាព (Invalid Ground)**

បណ្តឹងសិក្សា ឬបណ្តឹងទូទៅដែលវិទ្យាស្ថានចាត់ទុកថាគ្មានសុពលភាព គឺបណ្តឹងដែលគ្មានភស្តុតាង ឬមូលដ្ឋានច្បាស់លាស់ ដែលបង្ហាញពីផលប៉ះពាល់អវិជ្ជមានមកលើលទ្ធផលសិក្សា ឬផ្លូវចិត្តរបស់ និស្សិត ប្រាសចាកពីគោលការណ៍កំណត់ ឬមិនមានចែងក្នុងគោលការណ៍របស់វិទ្យាស្ថាន។

### ៣.៤ ពេលវេលានៃការដាក់ពាក្យបណ្តឹង

**ក. បណ្តឹងសិក្សា**

ករណីនិស្សិតមានបំណងប្តឹងជំទាស់នឹងលទ្ធផលសិក្សា ឬលទ្ធផលប្រលង និស្សិតមានពេលវេលា រយៈពេល ៥ ថ្ងៃ (នៃថ្ងៃធ្វើការ) សម្រាប់ដាក់ពាក្យបណ្តឹងមកវិទ្យាស្ថាន ក្រោយថ្ងៃចេញលទ្ធផលប្រលង។

**ខ. បណ្តឹងទូទៅ**

និស្សិតមានសិទ្ធិប្តឹងជំទាស់ទៅនឹងការដាក់ទោសពិន័យ ដែលលម្អៀងប្រាសចាក ឬមិនមានចែងក្នុងគោលការណ៍ក្រមសីលធម៌ វិន័យរបស់វិទ្យាស្ថាននៅរៀងរាល់ម៉ោងធ្វើការ។

## ៤. កំហុសនិស្សិត និងការដាក់ទោសពិន័យ

វិទ្យាស្ថានធ្វើការបណ្តុះបណ្តាល ដោយផ្តោតសំខាន់ទៅលើគុណភាព ក្រមសីលធម៌ និងអត្រាទទួលការងារខ្ពស់។ ដើម្បីស្របទៅនឹងគោលដៅនេះ និស្សិតរបស់វិទ្យាស្ថានតម្រូវឱ្យមានទំនួលខុសត្រូវខ្ពស់ក្នុងការសិក្សា ដោយប្រកាន់ខ្ជាប់នូវភាពស្មោះត្រង់លើកិច្ចការសិក្សា និងការប្រតិបត្តិខ្លួនឱ្យបានល្អ។ ការលួចចម្លង ឬការប្រើប្រាស់មធ្យោបាយផ្សេងៗដែលមិនមានការទទួលស្គាល់ពីវិទ្យាស្ថាន ក្នុងន័យកេងចំណេញដល់លទ្ធផលសិក្សារបស់ខ្លួន ដោយមិនស្មើភាពគ្នាជាមួយនិស្សិតដទៃ គឺជាសកម្មភាពហាមឃាត់ដាច់ខាត និងចាត់ទុក ថាជាការល្មើសច្បាប់ និងប្រព្រឹត្តកំហុស។ និស្សិតនឹងទទួលការពិន័យទៅតាមកំហុសដែលខ្លួនបានប្រព្រឹត្ត ប្រាសចាកនឹងនីតិវិធី ដែលបានកំណត់ដោយវិទ្យាស្ថាន។

### ៤.១ ប្រភេទកំហុស

វិទ្យាស្ថានបានកំណត់ប្រភេទកំហុសនិស្សិតជាពីរប្រភេទ ដូចខាងក្រោម៖

**ក. កំហុសទូទៅ**

គឺជាការប្រព្រឹត្តនូវសកម្មភាពហាមឃាត់ទាំងឡាយណាដែលប្រាសចាកពីវិន័យ ធ្វើឱ្យប៉ះពាល់ដល់សេចក្តីថ្លៃថ្នូររបស់សាមីនិស្សិត និស្សិតដទៃទៀត ក៏ដូចជាបុគ្គលិកវិទ្យាស្ថាន និងការបំផ្លាញនូវកេរ្តិ៍ឈ្មោះរបស់វិទ្យាស្ថាន។

**ខ. កំហុសសិក្សា**

ជាការប្រព្រឹត្ត ឬការជួយអ្នកដទៃប្រព្រឹត្តនូវសកម្មភាពទាំងឡាយណាដែលប្រាសចាកពីភាពស្មោះត្រង់ ដើម្បីទទួលបាននូវលទ្ធផលសិក្សាល្អ លំអៀង ប៉ះពាល់ដល់ផលប្រយោជន៍របស់និស្សិតដទៃទៀត។ កំហុសសិក្សាមានដូចជា ការលួចចម្លង យកស្នាដៃរបស់អ្នកដទៃធ្វើជារបស់ខ្លួន ក្លែងបន្លំ ឬផ្លាស់ប្តូរឯកសារពាក់ព័ន្ធនឹងការសិក្សា។

### ៤.២ ស្ថានទម្ងន់ទោស

វិទ្យាស្ថានបានកំណត់ស្ថានទម្ងន់ទោសជាបីកម្រិត ដូចខាងក្រោម៖

**ក. កម្រិតស្រាល**

គឺជាការប្រព្រឹត្តនូវសកម្មភាពហាមឃាត់លើកទី១ ដោយអចេតនា ឬដោយសារការមិនយល់ច្បាស់ ឬការយល់ខុសពីនីតិវិធីដែលបានកំណត់របស់វិទ្យាស្ថាន ដែលទង្វើនោះមិនមានការប៉ះពាល់ធ្ងន់ធ្ងរដល់ ផលប្រយោជន៍ ឬកេរ្តិ៍ឈ្មោះរបស់វិទ្យាស្ថាន។

**ខ. កម្រិតមធ្យម**

គឺជាការប្រព្រឹត្តនូវសកម្មភាពហាមឃាត់ទាំងឡាយណា ដែលកើតឡើងជាលើកទី២ ឬដដែលៗ ទោះដោយចេតនាក្តី ឬអចេតនាក្តី។

### គ. កម្រិតធ្ងន់

- រាល់ចេតនាប្រព្រឹត្តនូវសកម្មភាពហាមឃាត់ ដែលប៉ះពាល់ធ្ងន់ធ្ងរដល់សណ្តាប់ធ្នាប់ សេចក្តីថ្លៃថ្នូរ និង ផលប្រយោជន៍របស់និស្សិត ក៏ដូចជាបុគ្គលិកវិទ្យាស្ថាន។
- គ្រប់កំហុសសិក្សា ត្រូវបានចាត់ទុកថា ជាកំហុសកម្រិតធ្ងន់។

## ៤.៣ ការដាក់ទោសពិន័យ

### ក. កំហុសទូទៅ

- **កម្រិតស្រាល**
  - ការព្រមានផ្ទាល់មាត់
    កំហុសកម្រិតស្រាល និស្សិតអាចនឹងត្រូវបានជូនដំណឹងដោយផ្ទាល់មាត់ អំពីការប្រតិបត្តិខ្លួន ផ្ទុយទៅនឹង គោលការណ៍ ឬនីតិវិធីដែលត្រូវបានហាមឃាត់ ឬ
  - ការព្រមានជាលាយលក្ខណ៍អក្សរ
    និស្សិតអាចនឹងត្រូវបានវិទ្យាស្ថានជ្រើសរើសយកការពិន័យជាលាយលក្ខណ៍អក្សរទៅតាមកំហុសកើតឡើង ជាក់ស្តែង ដែលមិនមានផលប៉ះពាល់ដល់ផលប្រយោជន៍ ឬហានិភ័យកេរ្តិ៍ឈ្មោះ របស់វិទ្យាស្ថាន។
- **កម្រិតមធ្យម**
  ករណីដែលពិនិត្យឃើញថា និស្សិតបានប្រព្រឹត្តកំហុសផ្ទុយទៅនឹងគោលការណ៍ ឬនីតិវិធីដែល បាន កំណត់ដោយវិទ្យាស្ថានក្នុងកម្រិតមធ្យម និស្សិតរូបនោះនឹងត្រូវបានវិទ្យាស្ថានពិចារណាឱ្យស្ថិតក្នុងស្ថានភាព ព្យួរទោសមួយរយៈពេលតាមការកំណត់របស់វិទ្យាស្ថាន ក្នុងអំឡុងពេលព្យួរទោស ប្រសិនបើនិស្សិតកែ លំអខ្លួនឡើងវិញ ការពិន័យនឹងត្រូវបានលុបចោល។ ផ្ទុយទៅវិញករណីនិស្សិត មិនព្រមកែខ្លួន ថែមទាំង ប្រព្រឹត្តនូវទង្វើដដែលនោះជាថ្មីម្តងទៀត ឬទង្វើហាមឃាត់ដទៃផ្សេងទៀត វិទ្យាស្ថាននឹងកំណត់ឱ្យនិស្សិតរូប នោះព្យួរការសិក្សា ឬធ្ងន់ជាងនេះត្រូវបណ្តេញចេញពីការសិក្សា។
- **កម្រិតធ្ងន់**
  - ករណីរកឃើញថា និស្សិតបានប្រព្រឹត្តកំហុសក្នុងកម្រិតធ្ងន់ វិទ្យាស្ថាននឹងតម្រូវឱ្យនិស្សិតព្យួរ ការសិក្សា ជាកំហិត រយៈពេលអប្បបរមា ១ឆមាស រហូតដល់ ៤ឆមាស
  - រាល់ការលើកលែងការផុតកំណត់ ឬការបន្ថែមទោសក្នុងអំឡុងពេលព្យួរការសិក្សា ការិយាល័យសិក្សា និងកិច្ចការនិស្សិត មានសិទ្ធិសម្រេច ករណីពិនិត្យឃើញថា និស្សិតបានបំពេញគ្រប់ លក្ខខណ្ឌតម្រូវចប់ សព្វគ្រប់ ឬបានប្រព្រឹត្តល្មើសបន្ថែមផ្សេងទៀត។
  - និស្សិតដែលទទួលទោសព្យួរការសិក្សា នឹងបាត់បង់សិទ្ធិគ្រប់បែបយ៉ាងជាមួយវិទ្យាស្ថាន សូម្បីសិទ្ធិក្នុង ការចេញចូលក្នុងបរិវេណវិទ្យាស្ថាន លើកលែងតែទទួលបានការអនុញ្ញាត។
  - ការិយាល័យសិក្សា និងកិច្ចការនិស្សិត នឹងធ្វើការកត់ត្រាការពិន័យនោះទុកជាកំណត់ត្រានៃការសិក្សា របស់និស្សិតរូបនោះ។

### ខ. កំហុសសិក្សា

ករណីវិទ្យាស្ថានរកឃើញថា និស្សិតបានប្រព្រឹត្តកំហុសសិក្សា វិទ្យាស្ថាននឹងធ្វើការដាក់ទោសពិន័យ ដូចខាង ក្រោម៖

- បដិសេធមិនទទួលយកកិច្ចការនោះ ហើយមិនអនុញ្ញាតឱ្យនិស្សិតស្នើសុំធ្វើកិច្ចការនោះជាថ្មីម្តងទៀតឡើយ

- និស្សិតនឹងទទួលបានពិន្ទុសូន្យទៅលើ Assignment ការប្រលង ឬ Project នោះ ថែមទាំងធ្វើការកត់ត្រារក្សាទុកក្នុងសំណុំឯកសាររបស់និស្សិតរូបនោះទៀតផង
- ព្យួរការសិក្សាពីវិទ្យាស្ថានរយៈពេលមិនលើស ១ឆ្នាំ និងកត់ត្រាចូលក្នុងព្រឹត្តិបត្រពិន្ទុ (Transcript) ក្នុងអំឡុងពេលព្យួរការសិក្សា ថែមទាំងធ្វើការកត់ត្រាទុកក្នុងសំណុំឯកសាររបស់និស្សិតរូបនោះ ទៀតផង
- បណ្តេញចេញពីការសិក្សា ព្រមទាំងកត់ត្រាចូលក្នុងព្រឹត្តិបត្រពិន្ទុ (Transcript) និងធ្វើការកត់ត្រាទុកក្នុងសំណុំឯកសាររបស់និស្សិតរូបនោះទៀតផង
- ក្នុងករណីវិទ្យាស្ថានរកឃើញបទល្មើសសិក្សា ឬសាមីនិស្សិតបានធ្វើការសារភាពក៏ដោយ ការប្រព្រឹត្តល្មើសនោះ អាចនឹងត្រូវបានបំផ្លាញដល់លទ្ធផលសិក្សារបស់និស្សិតរូបនោះ ក្នុងការទទួលបានសញ្ញាបត្របញ្ចប់ការសិក្សារបស់ពួកគេ។

**ចំណុចពិសេស**

ករណីប្រព្រឹត្តល្មើសទៅនឹងលក្ខខណ្ឌ និងបទបញ្ជានៅពេលប្រលង វិទ្យាស្ថាននឹងធ្វើការពិន័យ ដូចខាងក្រោម៖

- ប្រព្រឹត្តលើកទី១ : ដកពិន្ទុ ៥០% លើមុខវិជ្ជាដែលកំពុងប្រលង
- ប្រព្រឹត្តលើកទី២ : បណ្តេញចេញពីការប្រលង និងទទួលបានពិន្ទុសូន្យ។



សកម្មភាពសិស្សចុះឈ្មោះចូលសិក្សានៅវិទ្យាស្ថាន ពាណិជ្ជសាស្ត្រ អេស៊ីលីដា

# កិច្ចការសិក្សា

វិទ្យាស្ថាន ពាណិជ្ជសាស្ត្រ អេស៊ីលីដា រៀបចំកម្មវិធីសិក្សាតាមប្រព័ន្ធឆមាស (Semester Block) មានពីរឆមាសក្នុងមួយឆ្នាំសិក្សា ដែលមានទាំងកម្មវិធីសិក្សា (In class) និងកម្មវិធីសិក្សា (Online)។

រចនាសម្ព័ន្ធនៃកម្មវិធីសិក្សាចែកចេញជាពីរក្រុមធំៗ គឺ៖

- ក្រុមទី១ : គឺជាការអប់រំទូទៅ (ថ្នាក់ឆ្នាំសិក្សាមូលដ្ឋាន)
- ក្រុមទី២ : គឺជាការអប់រំជំនាញ (មុខវិជ្ជាជំនាញ)

**មុខវិជ្ជាជំនាញ** សង្កត់ធ្ងន់ទៅលើចំណេះដឹង ការយល់ដឹង និងការអនុវត្តជាក់ស្តែង។ មុខវិជ្ជាជំនាញរាប់បញ្ចូលទាំងមុខវិជ្ជាគ្រឹះ មុខវិជ្ជាស្នូល និងមុខវិជ្ជាជ្រើសរើស។

- **មុខវិជ្ជាគ្រឹះ** គឺជាមុខវិជ្ជាសម្រាប់កសាង ឬបំពាក់បំប៉ននូវចំណេះដឹងជាមូលដ្ឋានជូនដល់និស្សិតមុន នឹងសិក្សាមុខវិជ្ជាស្នូល ។
- **មុខវិជ្ជាស្នូល** គឺជាមុខវិជ្ជាដែលទាក់ទងនឹងវិស័យ/ជំនាញសិក្សារបស់និស្សិត។ និស្សិតតម្រូវឱ្យសិក្សាមុខវិជ្ជាស្នូលច្រើនជាង៥០ភាគរយ ធៀបនឹងមុខវិជ្ជាដែលមានក្នុងកម្មវិធីសិក្សាទាំងមូល។
- **មុខវិជ្ជាជ្រើសរើស** គឺជាមុខវិជ្ជាដែលនិស្សិតអាចជ្រើសរើសសិក្សាឱ្យស្របនឹងជំនាញរបស់ពួកគេ។

## ១. លក្ខខណ្ឌនៃការបញ្ចប់ការសិក្សា

### ១.១ ការសិក្សា

វិទ្យាស្ថាន ពាណិជ្ជសាស្ត្រ អេស៊ីលីដា បានផ្តល់សេវាកម្មអប់រំ បណ្តុះបណ្តាល ជូនដល់និស្សិត ថ្នាក់បរិញ្ញាបត្ររង និងបរិញ្ញាបត្រ មុខជំនាញហិរញ្ញវត្ថុ និងធនាគារ ពាណិជ្ជកម្មអន្តរជាតិ គ្រប់គ្រងហានិភ័យ និងធានារ៉ាប់រង គ្រប់គ្រងបណ្តាញផ្គត់ផ្គង់ និងចលនទ្របត្ថម្ភ បច្ចេកវិទ្យាព័ត៌មានធុរកិច្ច និងបច្ចេកវិទ្យាហិរញ្ញវត្ថុ ដែលកម្មវិធីសិក្សានីមួយៗ ត្រូវ បានពិព័ណ៌នាលម្អិត ដូចខាងក្រោម៖

**ក. ថ្នាក់បរិញ្ញាបត្ររង**

កម្មវិធីសិក្សាថ្នាក់បរិញ្ញាបត្ររងត្រូវបានរៀបចំ និងបង្កើតឡើង តាមលំនាំកម្មវិធីសិក្សារបស់ប្រទេស សិង្ហបុរី (Teach less learn more) និងស្របតាមតម្រូវការទីផ្សារការងារក្នុងវិស័យហិរញ្ញវត្ថុ និងធនាគារ គ្រប់គ្រងអាហារ័ណ-នីហារ័ណ ធានារ៉ាប់រង និងចលនទ្របត្ថម្ភ ទាំងក្នុងប្រទេស តំបន់ និងសកលលោក សម្រាប់សិស្សានុសិស្សដែលបានប្រឡងធ្លាក់ និង/ឬ ជាប់សញ្ញាបត្រមធ្យមសិក្សាទុតិយភូមិ ដោយមានរយៈពេលសិក្សា **២ឆ្នាំ** ឬ**៤ឆមាស** សរុបចំនួន **៦១ក្រេឌីត** ។ ការបង្រៀនតាមកម្មវិធីសិក្សានេះ បានផ្តោតសំខាន់លើទ្រឹស្តី ផ្សារភ្ជាប់នឹងការអនុវត្ត ការងារជាក់ស្តែងនូវកិច្ចការជំនាញនានា ទាក់ទងនឹងការងារនៅធនាគារ (ឥណទាន, ទីផ្សារ, គណនេយ្យ, បេឡា និង/ឬផ្សេងៗ) ដោយផ្តោតសំខាន់លើបញ្ហា (Problem-based), ការអង្កេត (Inquiry-based), គម្រោង (Project-based), ការស្រាវជ្រាវខ្លីៗ (Mini-research), ការធ្វើបទបង្ហាញ (Presentation) និង ការអនុវត្តការងារជាក់ស្តែង (Field Practice) តាមមុខវិជ្ជាទាក់ទងនឹងកិច្ចការធនាគារនៅធនាគារ អេស៊ីលីដា ភីអិលស៊ី ដើម្បីឱ្យនិស្សិតទាំងអស់បានយល់ដឹងកាន់តែច្បាស់ ទាំងទ្រឹស្តី និងការអនុវត្តការងារជាក់ស្តែង ដោយប្រើប្រាស់ភាសាអង់គ្លេសជាគោល ដែលជាផ្នែកមួយនៃកម្មវិធីសិក្សា ដើម្បីបំពាក់បំប៉នបន្ថែមជូនដល់និស្សិតទាំងអស់នូវចំណេះដឹងភាសាអង់គ្លេស សម្រាប់ការងារ, មុខរបរ និងការសិក្សាបន្តនាពេលអនាគត។

**ខ. ថ្នាក់បរិញ្ញាបត្រ**

កម្មវិធីសិក្សាថ្នាក់បរិញ្ញាបត្រត្រូវបានរៀបចំ និងបង្កើតឡើងតាមលំនាំកម្មវិធីសិក្សារបស់ប្រទេសសិង្ហបុរី (Teach less learn more) និងស្របតាមតម្រូវការទីផ្សារការងារ ក្នុងវិស័យហិរញ្ញវត្ថុ និងធនាគារ ពាណិជ្ជកម្មអន្តរជាតិ

គ្រប់គ្រងហានិភ័យ និងធានារ៉ាប់រង គ្រប់គ្រងបណ្ដាញផ្គត់ផ្គង់ និងចលនទូបត្ថម្ភ បច្ចេកវិទ្យាព័ត៌មានធុរកិច្ច និង បច្ចេកវិទ្យាហិរញ្ញវត្ថុ ទាំងក្នុងប្រទេស តំបន់ និងសកលលោក ដោយមានរយៈពេលសិក្សា**៤ឆ្នាំ** ឬ**៨ឆមាស** សរុបចំនួន **១២២ក្រេឌីត** ។ ការបង្រៀនតាមកម្មវិធីសិក្សានេះបានផ្តោតសំខាន់លើទ្រឹស្តី ផ្សារភ្ជាប់នឹងការអនុវត្តការងារជាក់ស្តែងនូវកិច្ចការជំនាញនានាទាក់ទងនឹងការងារនៅធនាគារ (ឥណទាន, ទីផ្សារ, គណនេយ្យ, បេឡា និង/ឬផ្សេងៗ) ដោយផ្តោតសំខាន់លើបញ្ហា (Problem-based), ការអង្កេត (Inquiry-based), គម្រោង (Project-based), ការស្រាវជ្រាវខ្លីៗ (Mini-research), ការធ្វើបទបង្ហាញ (Presentation) និងអនុវត្តការងារជាក់ស្តែង (Apprenticeship) តាមមុខវិជ្ជាសិក្សាទាក់ទងនឹងកិច្ចការធនាគារ នៅធនាគារ អេស៊ីលីដា ភីអិលស៊ី ដើម្បីឱ្យនិស្សិតទាំងអស់បានយល់ដឹងកាន់តែច្បាស់ ទាំងទ្រឹស្តី និងការអនុវត្ត ការងារជាក់ស្តែង ដោយប្រើប្រាស់ភាសាអង់គ្លេសជាគោល ដែលជាផ្នែកមួយនៃកម្មវិធីសិក្សា ដើម្បី បំពាក់បំប៉នបន្ថែមជូនដល់និស្សិតទាំងអស់នូវចំណេះដឹងភាសាអង់គ្លេសសម្រាប់ការងារ, មុខរបរ និង ការសិក្សាបន្តនាពេលអនាគត និងតម្រូវឱ្យនិស្សិតសរសេរសារណា (Thesis) ដែលជាទុនបន្ថែម សម្រាប់និស្សិតក្នុងការសិក្សាបន្តថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់ នៅគ្រឹះស្ថានឧត្តមសិក្សានានា។

### គ. ថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់

កម្មវិធីសិក្សាថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់ ត្រូវបានរៀបចំនិងបង្កើតឡើងតាមលំនាំកម្មវិធីសិក្សារបស់ប្រទេសសិង្ហបូរី (Teach less learn more) និងស្របតាមតម្រូវការទីផ្សារការងារ ក្នុងវិស័យហិរញ្ញវត្ថុ និងធនាគារ បូករួមទាំងផ្នែកហិរញ្ញវត្ថុ និងការគ្រប់គ្រងជាលក្ខណៈអន្តរជាតិ ទាំងក្នុងប្រទេស តំបន់ និងសកលលោក ដោយមានរយៈពេល២ឆ្នាំ ឬ៤ឆមាស ដែលមានសរុបចំនួន៥៤ ក្រេឌីត។

## ១.២ លក្ខខណ្ឌសិក្សា

វិទ្យាស្ថាន ពាណិជ្ជសាស្ត្រ អេស៊ីលីដា រៀបចំកម្មវិធីសិក្សាតាមប្រព័ន្ធឆមាស (Semester Block) ដែលមានពីរឆមាសក្នុងមួយឆ្នាំសិក្សា។

### ក. ថ្នាក់បរិញ្ញាបត្ររង

- យោងតាមកម្មវិធីសិក្សា វិទ្យាស្ថានតម្រូវឱ្យនិស្សិតសិក្សា ៥មុខវិជ្ជាក្នុងមួយឆមាស ដោយមិនអនុញ្ញាត ឱ្យជ្រើសរើសយកមុខវិជ្ជាណាមួយមកសិក្សាមុន ឬក្រោយនោះទេ
- ការិយាល័យសិក្សា និងកិច្ចការនិស្សិត នឹងចេញលិខិតបញ្ជាក់ការសិក្សា និង/ព្រឹត្តិបត្រពន្ទុដល់សាមី និស្សិតចំនួន ១ច្បាប់ (ក្នុងករណីនិស្សិតស្នើសុំ)
- កម្រិតថ្នាក់បរិញ្ញាបត្ររងរបស់វិទ្យាស្ថាន មានរយៈពេលអតិបរមា **៣ឆ្នាំ**។

### ខ. ថ្នាក់បរិញ្ញាបត្រ

- យោងតាមកម្មវិធីសិក្សា វិទ្យាស្ថានតម្រូវឱ្យនិស្សិតសិក្សា ៥មុខវិជ្ជាក្នុងមួយឆមាស ដោយមិនអនុញ្ញាត ឱ្យជ្រើសរើសយកមុខវិជ្ជាណាមួយមកសិក្សាមុន ឬក្រោយនោះទេ។
- ការិយាល័យសិក្សា និងកិច្ចការនិស្សិត នឹងចេញលិខិតបញ្ជាក់ថ្នាក់ឆ្នាំសិក្សាមូលដ្ឋានដល់សាមីនិស្សិត។
- កម្រិតថ្នាក់បរិញ្ញាបត្ររបស់វិទ្យាស្ថាន មានរយៈពេលអតិបរមា **៦ឆ្នាំ**។

### គ. ថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់

- យោងតាមកម្មវិធីសិក្សា វិទ្យាស្ថានតម្រូវឱ្យនិស្សិតសិក្សា ៥មុខវិជ្ជាក្នុងមួយឆមាស ដោយមិនអនុញ្ញាត ឱ្យជ្រើសរើសយកមុខវិជ្ជាណាមួយមកសិក្សាមុន ឬក្រោយនោះទេ។
- ការិយាល័យសិក្សា និងកិច្ចការនិស្សិត នឹងចេញលិខិតបញ្ជាក់ថ្នាក់ឆ្នាំសិក្សាមូលដ្ឋានដល់សាមី និស្សិត។
- កម្រិតថ្នាក់បរិញ្ញាបត្ររបស់វិទ្យាស្ថាន មានរយៈពេលអតិបរមា **៣ឆ្នាំ**។

## ១.៣ ការកំណត់មធ្យមភាគនៃពិន្ទុនិទ្ទេសសរុប

### ក. បរិញ្ញាបត្ររង និងបរិញ្ញាបត្រ

ដើម្បីពង្រឹង និងបង្កើនគុណភាពសិក្សារបស់និស្សិត វិទ្យាស្ថានបានកំណត់មធ្យមភាគនៃពិន្ទុនិទ្ទេសសរុប (Grade Point Average-GPA) ដែលកំណត់ថាជាប់ គឺចាប់ពី **២,០០** ឡើងទៅ ក្នុងឆមាសនីមួយៗ។ ចំពោះពិន្ទុនិទ្ទេសនៃមុខវិជ្ជាជំនាញនីមួយៗដែលកំណត់ថាជាប់ គឺចាប់ពី**២,០០** ឡើងទៅ។

### ខ. បរិញ្ញាបត្រជាន់ខ្ពស់

ដើម្បីពង្រឹង និងបង្កើនគុណភាពសិក្សារបស់និស្សិត វិទ្យាស្ថានបានកំណត់មធ្យមភាគនៃពិន្ទុនិទ្ទេសសរុប (Grade Point Average-GPA) ដែលកំណត់ថាជាប់ គឺចាប់ពី **៣,០០** ឡើងទៅ ក្នុងឆមាសនីមួយៗ។ ចំពោះពិន្ទុនិទ្ទេសនៃមុខវិជ្ជាជំនាញនីមួយៗដែលកំណត់ថាជាប់ គឺចាប់ពី **៣,០០** ឡើងទៅ។

# ២. បទដ្ឋាន និងគោលការណ៍នៃការសិក្សា

## ២.១ ដំណើរការនៃការសិក្សា

វិទ្យាស្ថានកំណត់យកការបើកកម្មវិធីសិក្សា២ដងក្នុងមួយឆ្នាំ និងរៀបចំកម្មវិធីសិក្សាដែលមានលម្អិតពី មុខវិជ្ជាសិក្សា និងចំនួនក្រេឌីតដូចមានក្នុងកម្មវិធីសិក្សា។

### ក. ថ្នាក់ប្រចាំសប្តាហ៍

វិទ្យាស្ថានតម្រូវឱ្យនិស្សិតសិក្សា១មុខវិជ្ជា ក្នុងមួយថ្ងៃ ដោយមួយមុខវិជ្ជាមានរយៈពេល៣ម៉ោង។ និស្សិតត្រូវសិក្សា៥ថ្ងៃ ក្នុងមួយសប្តាហ៍ ពីថ្ងៃចន្ទ ដល់ថ្ងៃសុក្រ។

### ខ. ថ្នាក់ចុងសប្តាហ៍

វិទ្យាស្ថានតម្រូវឱ្យនិស្សិតសិក្សា ៥មុខវិជ្ជា ក្នុងមួយសប្តាហ៍ គឺថ្ងៃសៅរ៍ និងថ្ងៃអាទិត្យ ដោយមួយ មុខវិជ្ជាមានរយៈពេល៣ម៉ោង។

### គ. វេនសិក្សា

វិទ្យាស្ថានបានរៀបចំបែងចែកវេនសិក្សាដូចខាងក្រោម៖

- **ថ្នាក់ប្រចាំសប្តាហ៍**
  - វេនព្រឹក : ចាប់ពីម៉ោង ០៧:៣០នាទី ដល់ម៉ោង ១០:៣០នាទី
  - វេនរសៀល : ចាប់ពីម៉ោង ១៣:០០នាទី ដល់ម៉ោង ១៦:០០នាទី
  - វេនយប់ : ចាប់ពីម៉ោង ១៧:៣០នាទី ដល់ម៉ោង ២០:៣០នាទី
- **ថ្នាក់ចុងសប្តាហ៍**
  - ថ្ងៃសៅរ៍ : ពេលព្រឹក : ចាប់ពីម៉ោង ០៧:៣០នាទី ដល់ម៉ោង ១២:០០នាទី និង<br>ពេលរសៀល : ចាប់ពីម៉ោង ១៣:០០នាទី ដល់ម៉ោង ១៧:៣០នាទី
  - ថ្ងៃអាទិត្យ : ពេលព្រឹក : ចាប់ពីម៉ោង ០៧:៣០នាទី ដល់ម៉ោង ១២:០០នាទី និង<br>ពេលរសៀល : ចាប់ពីម៉ោង ១៣:០០នាទី ដល់ម៉ោង ១៤:៣០នាទី

### ២.២ ការកំណត់ចំនួននិស្សិតក្នុងមួយថ្នាក់

ដើម្បីឱ្យការសិក្សារបស់និស្សិតទទួលបានប្រសិទ្ធភាពខ្ពស់ វិទ្យាស្ថានបានកំណត់ចំនួនអតិបរមាសម្រាប់ទទួលនិស្សិតក្នុងមួយបន្ទប់ចំនួនចន្លោះពី ២០-២៥ នាក់ (ទៅតាមទំហំបន្ទប់សម្រាប់ ៣វេនសិក្សា)។ ក្នុងបន្ទប់សិក្សានីមួយៗ វិទ្យាស្ថានបានបំពាក់ឧបករណ៍ និងសម្ភារសិក្សា សម្រាប់បម្រើដល់ការសិក្សា និងការបង្រៀនរបស់គ្រូ និងនិស្សិតបានគ្រប់គ្រាន់ និងប្រកបដោយលក្ខណៈទំនើប។

### ២.៣ ការថែរក្សានិស្សិត

ការថែរក្សានិស្សិតវិទ្យាស្ថាន គឺជាការបង្កើននូវកិត្យានុភាពរបស់គណៈអភិបាលវិទ្យាស្ថាន ក្នុងការព្យាយាមធ្វើឱ្យប្រសើរឡើងនូវអត្រាបញ្ចប់ការសិក្សារបស់និស្សិត ការកាត់បន្ថយការបោះបង់ការសិក្សា ឬ អត្រាការផ្ទេរការសិក្សាទៅគ្រឹះស្ថានដទៃផ្សេងទៀត។

វិទ្យាស្ថានបានរៀបចំផែនការសកម្មភាព ក្នុងការថែរក្សានិស្សិតដូចមានរៀបរាប់ខាងក្រោម៖

**ក. ការផ្សព្វផ្សាយ**

ដើម្បីថែរក្សានិស្សិតឱ្យនៅតែមានទំនុកចិត្តជាមួយវិទ្យាស្ថាន និងនៅតែបន្តប្រើប្រាស់សេវាអប់រំរបស់វិទ្យាស្ថាន ការផ្សព្វផ្សាយត្រូវមានលក្ខណៈស្មោះត្រង់ មិនបោកបញ្ឆោត ភូតកុហក។

**ខ. ផ្តល់ការគាំទ្រលើចំណេះជំនាញ និងស្មារតី**

សកម្មភាពដើម្បីផ្តល់ការគាំទ្រ ដល់ការសិក្សារបស់និស្សិតមានដូចជា៖

- រៀបចំឱ្យមានការបំប៉នការសិក្សាដល់និស្សិតដែលមិនសូវពូកែ ដោយប្រើមធ្យោបាយគ្រូម្នាក់ សិស្សម្នាក់ (Tutoring) ឬរៀបចំឱ្យមានការជួយជម្រុញពីនិស្សិត (Peer Mentoring) ដើម្បីផ្តល់ការប្រឹក្សាដល់និស្សិតដូចគ្នា ក្នុងករណីដែលនិស្សិតមិនមានបំណងជ្រើសរើសយកការប្រឹក្សាជាមួយគ្រូ។
- វិទ្យាស្ថានរៀបចំបង្កើតជាវគ្គសិក្សា ឬវគ្គសិក្ខាសាលាផ្សេងៗ ដោយធ្វើការអញ្ជើញវាគ្មិនដែលមានបទពិសោធន៍មកផ្តល់ជាគំនិតដល់និស្សិត ដើម្បីអភិវឌ្ឍន៍ជំនាញ ក្នុងការសិក្សារបស់ពួកគាត់ឱ្យកាន់តែប្រសើរឡើង ឬអាចបញ្ជូនពួកគាត់ឱ្យទៅចូលរួមកម្មវិធីសិក្ខាសាលា ឬការប្រកួតប្រជែងផ្សេងៗ ជាមួយស្ថាប័នខាងក្រៅ។
- ការប្រឹក្សាយោបល់ទាក់ទងនឹងការសិក្សា ក៏ជាមធ្យាបាយក្នុងការជួយជម្រុញឱ្យនិស្សិតមានទឹកចិត្ត បន្តការសិក្សារបស់ខ្លួនផងដែរ។ ករណីនិស្សិតមានតម្រូវការក្នុងការប្រឹក្សាយោបល់ផ្សេងៗទាក់ទង នឹងការសិក្សា ឬបញ្ហាផ្ទាល់ខ្លួន ដែលជាមូលហេតុនាំឱ្យរាំងស្ទះដល់លទ្ធផលសិក្សារបស់ខ្លួន វិទ្យាស្ថានបើកទូលាយក្នុងការផ្តល់នូវធនធានសម្រាប់ផ្តល់ការប្រឹក្សាជូនដល់និស្សិតគ្រប់ពេលវេលា។

**គ. តាមដានការសិក្សារបស់និស្សិតជាប់ជាប្រចាំ**

ដើម្បីមានភាពងាយស្រួលក្នុងការគាំទ្រនិស្សិតឱ្យទទួលបានជោគជ័យ វិទ្យាស្ថានធ្វើការតាមដានការសិក្សា របស់និស្សិតជាប់ជានិច្ច ដើម្បីផ្តល់ជំនួយឱ្យបានទាន់ពេលវេលា។

**ឃ. ការវាយតម្លៃប្រកបដោយគុណភាព**

ប្រព័ន្ធនៃការវាយតម្លៃលើលទ្ធផលនៃការសិក្សារបស់និស្សិត ត្រូវមាន ភាពសុក្រិត តម្លាភាព និងយុត្តិធម៌។ វិទ្យាស្ថានក៏បានរៀបចំឱ្យមានប្រព័ន្ធតាមដានលទ្ធផលនៃការសិក្សារបស់និស្សិតជាប់ជាប្រចាំ ដើម្បីផ្តល់សញ្ញាទាន់ពេលវេលា ក្នុងករណីនិស្សិតទទួលបានលទ្ធផលអវិជ្ជមាន ដែលឈានដល់ការបរាជ័យដល់ការសិក្សារបស់និស្សិត។

**ង. ការពង្រឹងសមត្ថភាពរបស់គ្រូបង្រៀន**

គ្រូបង្រៀន គឺជាធនធានដ៏សំខាន់សម្រាប់ជួយឱ្យនិស្សិតទទួលបាននូវភាពជោគជ័យលើការសិក្សា។ និស្សិតពេញចិត្តសិក្សាបន្ត ឬបោះបង់ចោលការសិក្សា ក៏ជាចំណែកមួយដែលទទួលឥទ្ធិពលពីគ្រូបង្រៀនផងដែរ។ ដើម្បី

ចៀសវាងបញ្ហាទាំងអស់នេះ វិទ្យាស្ថានបានយកចិត្តទុកដាក់បំពាក់បំប៉នសមត្ថភាពរបស់គ្រូបង្រៀនឱ្យកាន់តែប្រសើរឡើង ដើម្បីគាំទ្រដល់ការសិក្សារបស់និស្សិត ដូចជាផ្តល់នូវការឧបត្ថម្ភការសិក្សាដល់គ្រូបង្រៀន បញ្ជូនឱ្យចូលរួមក្នុងវគ្គបណ្តុះបណ្តាលវិក្រិតការផ្សេងៗ ដើម្បីឱ្យពួកគាត់មាន ឱកាសក្នុងការពង្រឹង និងពង្រីកចំណេះជំនាញ របស់ពួកគាត់ឱ្យទាន់សម័យ។

## ២.៤ ការសុំអនុញ្ញាតច្បាប់

### ក. ច្បាប់ត្រូវបានលើកលែង

វិទ្យាស្ថាន លើកលែងឱ្យនិស្សិតឈប់សម្រាកដោយមិនរាប់បញ្ចូលក្នុងច្បាប់ឈប់សម្រាករបស់និស្សិតក្នុងករណីដូចខាងក្រោម៖

- មានជំងឺផ្ទាល់ខ្លួន ឬ
- មានធុរៈផ្ទាល់ខ្លួន (រៀបអាពាហ៍ពិពាហ៍) ឬ
- មានធុរៈគ្រួសារ ឬ
- ចូលរួមប្រកួតកីឡា ឬកម្មវិធីសិល្បៈសម្រាប់វិទ្យាស្ថាន (ចំពោះតែនិស្សិតដែលជាសមាជិកក្រុមកីឡា ឬសិល្បករ-ការិនី និងត្រូវភ្ជាប់មកជាមួយនូវលិខិតបញ្ជាក់ឱ្យបានច្បាស់លាស់)។

### ខ. អវត្តមានមានច្បាប់ និងគ្មានច្បាប់

ក្រៅពីករណីដូចក្នុង **ចំណុច៣.៤.ក** និស្សិតត្រូវបានអនុញ្ញាតឱ្យស្នើសុំច្បាប់ឈប់សម្រាក ដោយមិនមានកាត់ពិន្ទុបានចំនួន ៦ដង ក្នុងមួយមុខវិជ្ជា នៃឆមាសនីមួយៗ (មួយដងស្មើ ១ម៉ោង៣០នាទី) ទាំងមានច្បាប់ និងគ្មានច្បាប់។

### គ. សមត្ថកិច្ចក្នុងការអនុមតិច្បាប់

និស្សិតអាចទំនាក់ទំនងទៅគ្រូទទួលបន្ទុកមុខវិជ្ជានីមួយៗ សម្រាប់ការសុំច្បាប់ក្រៅពីករណីដូចមានចែង ក្នុង **ចំណុច៣.៤.ក**។

## ២.៥ ការព្យួរការសិក្សា

វិទ្យាស្ថាន អនុញ្ញាតឱ្យនិស្សិតស្នើសុំព្យួរការសិក្សាមុនការសិក្សាចាប់ផ្តើម ដោយសារមូលហេតុបញ្ហាសុខភាព ឬគ្រោះថ្នាក់ចៃដន្យ ដែលមិនអាចបន្តការសិក្សាបានដោយមានលិខិតបញ្ជាក់ពីគ្រូពេទ្យជំនាញ ឬនិស្សិតមានបេសកកម្មការងាររយៈពេលវែងចាប់ពី៤សប្តាហ៍ឡើងទៅ ដោយមានលិខិតបញ្ជាបេសកកម្មពីស្ថាប័ន ដែលនិស្សិតបម្រើការងារ ឬមានធុរៈផ្ទាល់ខ្លួន។

និស្សិតត្រូវធ្វើសំណើសុំជាលាយលក្ខណ៍អក្សរមកការិយាល័យសិក្សា និងកិច្ចការនិស្សិត ដើម្បីស្នើសុំការអនុមតិព្យួរការសិក្សា។ ករណីនិស្សិតមានបំណងត្រឡប់មកសិក្សាវិញ ត្រូវមកទំនាក់ទំនងជាមួយ ការិយាល័យសិក្សា និងកិច្ចការនិស្សិត ដោយភ្ជាប់មកជាមួយនូវពាក្យស្នើសុំព្យួរការសិក្សា ដែលបានអនុមតិរួច មុនវគ្គសិក្សាថ្មីចាប់ផ្តើម ៥ថ្ងៃ (នៃថ្ងៃធ្វើការ)។

វិទ្យាស្ថានអនុញ្ញាតឱ្យនិស្សិតព្យួរការសិក្សារយៈពេលអតិបរមាត្រឹម ២ឆមាសប៉ុណ្ណោះ។

## ២.៦ ការធ្វើកម្មសិក្សា

**កម្មសិក្សា** គឺជាកម្មវិធីហ្វឹកហ្វឺន ដែលតម្រូវឱ្យនិស្សិតចុះទៅធ្វើការសិក្សាស្រាវជ្រាវ ឬអនុវត្តការងារ ជាក់ស្តែងស្របទៅនឹងជំនាញដែលបានសិក្សា នៅធនាគារ អេស៊ីលីដា ឬស្ថាប័នណាមួយតាមការពេញចិត្ត របស់និស្សិតដើម្បីទទួលបាននូវបទពិសោធន៍ការងារជាក់ស្តែង។

**ក. សិទ្ធិក្នុងការធ្វើកម្មសិក្សា**

និស្សិតដែលមិនមានពេលវេលាគ្រប់គ្រាន់ក្នុងការចុះហាត់ការ តាមពេលវេលាកំណត់របស់វិទ្យាស្ថាន ដោយសារជាប់រវល់ធ្វើការងារ (មានលិខិតបញ្ជាក់ការងារពីស្ថាប័នសាមី) និស្សិតរូបនោះ មានសិទ្ធិស្នើសុំធ្វើកម្មសិក្សា។ និស្សិតត្រូវធ្វើសំណើសុំជាលាយលក្ខណ៍អក្សរមកការិយាល័យសិក្សា និងកិច្ចការនិស្សិត ឱ្យបានរយៈពេល ១ខែ មុនកាលបរិច្ឆេទធ្វើកម្មសិក្សា។

**ខ. មុខវិជ្ជាជំនាញសម្រាប់ការធ្វើកម្មសិក្សា**

និស្សិតតម្រូវឱ្យសិក្សាលើមុខវិជ្ជាជំនាញដូចខាងក្រោម ដើម្បីជាមូលដ្ឋានគ្រឹះក្នុងការធ្វើកម្មសិក្សា៖

- **កម្រិតបរិញ្ញាបត្ររង**
  - ឆ្នាំទី២ ឆមាសទី២ : ជំនាញទីផ្សារ/ឥណទាន/ប្រតិបត្តិការ
- **កម្រិតបរិញ្ញាបត្រ**
  - ឆ្នាំទី៣ ឆមាសទី២ : ជំនាញទីផ្សារ/ឥណទាន/ប្រតិបត្តិការ

**គ. មុខវិជ្ជាជំនាញជម្រើសសម្រាប់ការធ្វើកម្មសិក្សា**

- **កម្រិតបរិញ្ញាបត្ររង** ត្រូវចុះហាត់ការនៅឆ្នាំទី២ ឆមាសទី២
- **កម្រិតបរិញ្ញាបត្រ** ត្រូវចុះហាត់ការនៅឆ្នាំទី៤ ឆមាសទី១

**ឃ. ការធ្វើកម្មសិក្សា**

- និស្សិតធ្វើការសិក្សាស្រាវជ្រាវ ប្រមូលចងក្រងឯកសារ តាមរយៈការអាន ឬកត់ត្រាតាមសៀវភៅគោលការណ៍ នីតិវិធី សេចក្តីណែនាំ និងឯកសារផ្សេងៗរបស់ធនាគារ អេស៊ីលីដា ភីអិលស៊ី ឬ បុត្រសម្ព័ន្ធក្នុងប្រទេស ឬ ស្ថាប័នដែលខ្លួនបម្រើការងារជាមួយ។ (ទាក់ទងនឹងជំនាញដែលខ្លួនសិក្សា)និស្សិតមិនត្រូវបានអនុញ្ញាតឱ្យយកឯកសារដែលបានរៀបរាប់ខាងលើ ចេញពីបរិវេណធនាគារ អេស៊ីលីដា ភីអិលស៊ី ឬបុត្រសម្ព័ន្ធ ក្នុងប្រទេស ឬធ្វើការថតចម្លងបានឡើយ លើកលែងតែឯកសារសម្រាប់ ផ្សព្វផ្សាយជាសាធារណៈប៉ុណ្ណោះ
- និស្សិតដែលបម្រើការងារជាមួយស្ថាប័នធនាគារ និងហិរញ្ញវត្ថុ វិទ្យាស្ថានអនុញ្ញាតឱ្យធ្វើកម្មសិក្សានៅទីកន្លែងបំពេញការងារផ្ទាល់របស់សាមីនិស្សិត ដើម្បីសិក្សាស្រាវជ្រាវ ស្វែងរកឯកសារ ដែលទាក់ទងនឹងប្រធានបទស្នើសុំ ដើម្បីចងក្រងរបាយការណ៍សម្រាប់ធ្វើបទបង្ហាញ។

**ករណីលើកលែង**

និស្សិតដែលបម្រើការងារជាមួយស្ថាប័នមិនពាក់ព័ន្ធជាមួយវិស័យធនាគារ និងហិរញ្ញវត្ថុ និងមិនមានលទ្ធភាព ធ្វើកម្មសិក្សា វិទ្យាស្ថានតម្រូវឱ្យសិក្សាមុខវិជ្ជាជំនាញបន្ថែមផ្សេងទៀត សម្រាប់ទទួលក្រេឌីតជំនួស។

## ២.៧ ការបោះបង់ចោលសិក្សា

វគ្គសិក្សាថ្មីចាប់ផ្តើម វិទ្យាស្ថាននឹងចាត់ទុកថា និស្សិតបានបោះបង់ចោលការសិក្សាក្នុងករណី និស្សិត (ចាស់ និងថ្មី) មិនមានវត្តមានចូលសិក្សារយៈពេល១៥ថ្ងៃ (នៃថ្ងៃធ្វើការ) ជាប់គ្នា ដោយគ្មានការជូនដំណឹង។

## ២.៨ ការវាយតម្លៃការសិក្សារបស់និស្សិត និងការដាក់ពិន្ទុ

**ក. ការវាយតម្លៃការសិក្សារបស់និស្សិត**

ដើម្បីទទួលបានជោគជ័យក្នុងការសិក្សា វិទ្យាស្ថានបានរៀបចំឱ្យមានការវាយតម្លៃប្រចាំឆមាសនីមួយៗ និងផ្តល់ពិន្ទុវាយតម្លៃដូចខាងក្រោម៖

### ខ. ការវិនិច្ឆ័យលើលទ្ធផលនៃការសិក្សា

| ប្រភេទ | វិធីសាស្ត្រដែលអាចជ្រើសរើសយកមកប្រើប្រាស់ | | ពិន្ទុ |
|---|---|---|---|
| អំឡុងពេល | ប្រចាំថ្ងៃនិងប្រចាំខែ | ស្វ័យវាយតម្លៃ<br>ការវាយតម្លៃរបស់គ្រូបង្រៀន<br>សំណួរ<br>ប្រឡង<br>កិច្ចការ (ប្រចាំថ្ងៃ និងប្រចាំខែ)<br>......។ល។ | ៤០% |
| | ពាក់កណ្តាលឆមាស | ការប្រឡងសរសេរនៅក្នុងថ្នាក់<br>កិច្ចការស្រាវជ្រាវ (ត្រួតពិនិត្យ និងសម្របសម្រួលនិស្សិត)<br>......។ល។ | ២០% |
| បញ្ចប់ | បញ្ចប់ឆមាស | ការប្រឡងសរសេរនៅក្នុងថ្នាក់<br>កិច្ចការស្រាវជ្រាវ (ត្រួតពិនិត្យ និងសម្របសម្រួលនិស្សិត)<br>......។ល។ | ៣០% |
| | | ពិន្ទុវត្តមាន | ១០% |
| | | **សរុប** | ១០០% |

### គ. ការកំណត់ពិន្ទុនិទ្ទេសសរុប

ដើម្បីពង្រឹង និងបង្កើនគុណភាពសិក្សារបស់និស្សិត វិទ្យាស្ថានបានកំណត់មធ្យមភាគនៃពិន្ទុនិទ្ទេសសរុប (Grade Point Average-GPA) ដែលកំណត់ថាជាប់ គឺចាប់ពី **២,០០** ឡើងទៅ ក្នុងឆមាសនីមួយៗ។ ចំពោះពិន្ទុនិទ្ទេសនៃមុខវិជ្ជាជំនាញនីមួយៗដែលកំណត់ថាជាប់ គឺចាប់ពី**២,០០** ឡើងទៅ។

**របៀបគណនា**

$$\text{GPA} = \frac{\sum(PxC)}{\sum C}$$

P : ផលគុណនៃពិន្ទុនិទ្ទេសដែលទទួលបាន

C : តម្លៃក្រេឌីតដែលត្រូវយកនៃមុខវិជ្ជានីមួយៗ

### ឃ. ការតវ៉ាលើការដាក់ពិន្ទុ

ករណីនិស្សិតមានបំណងប្តឹងជំទាស់នឹងលទ្ធផលសិក្សា ឬលទ្ធផលប្រលង និស្សិតមានពេលវេលាចំនួន ៥ថ្ងៃ (នៃថ្ងៃធ្វើការ) សម្រាប់ដាក់ពាក្យបណ្តឹងមកវិទ្យាស្ថាន ក្រោយថ្ងៃចេញលទ្ធផលប្រលង។

## ២.៩ ការប្រលង

### ក. វិន័យក្នុងពេលប្រលង

**និស្សិតត្រូវគោរពតាមវិន័យនៃការប្រលងដូចខាងក្រោម ៖**

- មកប្រលងឱ្យទាន់ពេលវេលា ។ ករណីមានធុរៈចាំបាច់ធ្វើឱ្យខកខានការប្រលង និស្សិតត្រូវជូនដំណឹង ដល់គ្រូទទួលបន្ទុកថ្នាក់ ឬការិយាល័យសិក្សា និងកិច្ចការនិស្សិត ដើម្បីស្នើសុំអនុញ្ញាតច្បាប់ឱ្យបានមុនកាលបរិច្ឆេទប្រលង
- បំពេញក្បាលសន្លឹកកិច្ចការឱ្យបានគ្រប់ចំណុច តាមការណែនាំរបស់គ្រូទទួលបន្ទុកថ្នាក់ ករណីនិស្សិត មិនបំពេញក្បាលសន្លឹកកិច្ចការនោះនឹងត្រូវដកពិន្ទុ
- ចុះហត្ថលេខាលើបញ្ជីវត្តមានប្រលង

- ប្រើប្រាស់ទឹកប៊ិកតែមួយពណ៌ ករណីផ្ទុយត្រូវមានការអនុញ្ញាតពីគ្រូទទួលបន្ទុកថ្នាក់
- រក្សាភាពស្ងៀមស្ងាត់ អង្គុយឱ្យបានសមរម្យ
- គោរព និងអនុវត្តតាមការណែនាំរបស់គ្រូទទួលបន្ទុកថ្នាក់
- នៅពេលចប់ម៉ោង ត្រូវប្រគល់សន្លឹកកិច្ចការទៅឱ្យគ្រូទទួលបន្ទុកថ្នាក់ ទោះជាសន្លឹកកិច្ចការនោះ គ្មានសរសេរចម្លើយក៏ដោយ ។

**និស្សិតមិនត្រូវ ៖**

- ងាកសួរអ្នកជិតខាង ជជែក លួចមើលអ្នកដទៃក្នុងពេលប្រលង
- ចេញក្រៅបន្ទប់ក្នុងពេលប្រលង (លើកលែងតែមានការអនុញ្ញាតពីគ្រូទទួលបន្ទុកថ្នាក់)
- យកសំណៅឯកសារផ្សេងៗ ចូលក្នុងបន្ទប់ប្រលង លើកលែងតែមានចែងក្នុងវិញ្ញាសាប្រលង
- យកឧបករណ៍ សម្ភារ ឬឯកសារផ្សេងៗ ដែលត្រូវហាមឃាត់ សម្រាប់ជំនួយដល់ការប្រលងចូលក្នុងបន្ទប់ប្រលង
- ផ្តល់ព័ត៌មានទាក់ទងនឹងការប្រលងទៅនិស្សិតដទៃ
- កែចម្លើយលើសន្លឹកកិច្ចការប្រលង ដែលបានប្រគល់ឱ្យគ្រូរួចហើយ
- យកវិញ្ញាសាប្រលងចេញពីបន្ទប់ប្រលងដោយគ្មានការអនុញ្ញាត។

**និស្សិតមិនត្រូវបានអនុញ្ញាតឱ្យចូលប្រលងក្នុងករណីដូចខាងក្រោម៖**

- មកយឺតលើស៣០នាទី
- គ្មានប័ណ្ណសម្គាល់ខ្លួន ឬប័ណ្ណភ្ញៀវ (Visitor Card) ដែលអនុញ្ញាតឱ្យប្រើប្រាស់ជំនួសបានដោយការិយាល័យសិក្សា និងកិច្ចការនិស្សិត
- មិនទាន់បានបង់ប្រាក់ថ្លៃសិក្សា (និស្សិតចាស់)
- មិនពាក់ឯកសណ្ឋានតាមការកំណត់របស់វិទ្យាស្ថាន (សម្រាប់ព្រឹក ឬរសៀល)

**ខ. អវត្តមានក្នុងពេលប្រលង**

និស្សិតដែលអវត្តមានក្នុងពេលប្រលងដោយមិនមានការជូនដំណឹង វិទ្យាស្ថាននឹងចាត់ទុកថានិស្សិតបាន បោះបង់ចោលការប្រលង និងទទួលបានលទ្ធផលធ្លាក់លើមុខវិជ្ជានោះដោយស្វ័យប្រវត្តិ ។ វិទ្យាស្ថាន នឹងតម្រូវឱ្យនិស្សិតរូបនោះ សិក្សាត្រួតថ្នាក់លើមុខវិជ្ជាដែលមិនចូលប្រលងនោះ ដោយមិនអនុញ្ញាតឱ្យធ្វើការប្រលងសងឡើយ។

**គ. ការស្នើសុំលើកពេលប្រលង**

- វិទ្យាស្ថាន អនុញ្ញាតឱ្យនិស្សិតស្នើសុំលើកពេលប្រលងក្នុងករណីដូចខាងក្រោម៖
  - មានជម្ងឺ (ភ្ជាប់មកជាមួយនូវលិខិតបញ្ជាក់ច្បាស់លាស់ពីគ្រូពេទ្យជំនាញ)
  - មានធុរៈផ្ទាល់ខ្លួន (រៀបអាពាហ៍ពិពាហ៍)
  - មានធុរៈគ្រួសារ (ឪពុកម្តាយមានជំងឺ/ស្លាប់)
- និស្សិតត្រូវជូនដំណឹងមកការិយាល័យសិក្សា និងកិច្ចការនិស្សិត ដើម្បីស្នើសុំលើកពេលប្រលងដោយ បញ្ជាក់ឱ្យបានច្បាស់លាស់ពីមូលហេតុជាក់ស្តែងយ៉ាងយូរបំផុត ១ថ្ងៃមុនថ្ងៃប្រលង។ ករណីបន្ទាន់ និស្សិតត្រូវជូនដំណឹងតាមរយៈបណ្តាំផ្ញើតាមមិត្តភក្តិ ឬតាមទូរស័ព្ទមកគ្រូបង្រៀន និងធ្វើសំណើសុំតាមនីតិវិធី ក្រោយពេលត្រឡប់មកវិញដោយមានភស្តុតាងបញ្ជាក់។

## ២.១០ ការសិក្សាឡើងវិញ

វិទ្យាស្ថាន តម្រូវឱ្យនិស្សិតបង់ថ្លៃសិក្សាឡើងវិញ លើមុខវិជ្ជាដែលមិនទទួលជោគជ័យតាមនីតិវិធីនៃការ បង់ថ្លៃសិក្សាដែលរៀបចំដោយការិយាល័យផែនការ និងហិរញ្ញវត្ថុ។ ការសិក្សាឡើងវិញលើមុខវិជ្ជាដែល មិនទទួលជោគជ័យ ត្រូវបានកំណត់តាមលក្ខខណ្ឌដូចខាងក្រោម៖

- និស្សិតទទួលបានលទ្ធផលធ្លាក់ចាប់ពី ៣មុខវិជ្ជាឡើងទៅ
- និស្សិតទទួលបានលទ្ធផលធ្លាក់លើការប្រលងសងលើមុខវិជ្ជាដែលមិនទទួលជោគជ័យ។ វិទ្យាស្ថានអនុញ្ញាតឱ្យនិស្សិតបង់ថ្លៃសិក្សាឡើងវិញលើមុខវិជ្ជាទាំងនោះ រហូតដល់ត្រឹមឆមាសទី៦។

## ២.១១ ការផ្លាស់ប្តូរកម្មវិធីសិក្សា ឬវេនសិក្សា

និស្សិតមានសិទ្ធិស្នើសុំផ្លាស់ប្តូរកម្មវិធីសិក្សាពីថ្នាក់ប្រចាំសប្តាហ៍ ទៅថ្នាក់ចុងសប្តាហ៍ ឬស្នើសុំផ្លាស់ប្តូរវេនសិក្សាបាន ដោយធ្វើការស្នើសុំមកការិយាល័យសិក្សា និងកិច្ចការនិស្សិត ឱ្យបានយូរបំផុត ១០ថ្ងៃ (នៃថ្ងៃធ្វើការ) មុនកាលបរិច្ឆេទឆមាសថ្មីចាប់ផ្តើម។

## ២.១២ ការកែលម្អកម្មវិធីសិក្សា និងមុខវិជ្ជា

វិទ្យាស្ថាន ពាណិជ្ជសាស្ត្រ អេស៊ីលីដា នឹងវាយតម្លៃដើម្បីកែលម្អកម្មវិធីសិក្សា និងមុខវិជ្ជានីមួយៗដែល បានដាក់ឱ្យប្រើប្រាស់ជាផ្លូវការចំនួនមួយវគ្គនៃកម្មវិធីសិក្សានីមួយៗ (សម្រាប់ថ្នាក់បរិញ្ញាបត្ររង ២ឆ្នាំ និងថ្នាក់បរិញ្ញាបត្រ ៤ឆ្នាំ) និងតាមការតម្រូវជាក់ស្តែងរបស់ថ្នាក់មានសមត្ថកិច្ច ដើម្បីកែសម្រួល ឬ អភិវឌ្ឍន៍ឱ្យទាន់សម័យ និងស្របតាមតម្រូវការទីផ្សារការងារ។



សកម្មភាពក្នុងថ្នាក់សិក្សា

## កម្មវិធីសិក្សា

### ១. ការអប់រំបណ្តុះបណ្តាលបច្ចេកទេស និងវិជ្ជាជីវៈ

### ១.១ ថ្នាក់បរិញ្ញាបត្ររងឯកទេស

### ក. ថ្នាក់បរិញ្ញាបត្ររងឯកទេស ហិរញ្ញវត្ថុ និងធនាគារ

ប្រភេទ : ការអប់រំបណ្តុះបណ្តាលបច្ចេកទេស និងវិជ្ជាជីវៈ

ដេប៉ាតឺម៉ង់ : គ្រប់គ្រងពាណិជ្ជកម្ម

ឯកទេស : ហិរញ្ញវត្ថុ និងធនាគារ

កម្រិត : ៥ (បរិញ្ញាបត្ររង)

### ក₁ មុខវិជ្ជានៃកម្មវិធីសិក្សានីមួយៗ

| មុខវិជ្ជាអប់រំទូទៅ | មុខវិជ្ជាគ្រឹះ | មុខវិជ្ជាស្នូល |
|---|---|---|
| Core English I;<br>Core English II;<br>Core English III;<br>Critical Thinking;<br>Ethics and Values for Professionals; and<br>The Art of Communication. | Financial Accounting I;<br>Financial Accounting II;<br>Financial Management I;<br>Fundamentals of Quantitative Analysis;<br>Introduction to Business;<br>Managerial Accounting I;<br>Mathematics for Business and Economics;<br>Principles of Economics;<br>Principles of Marketing; and<br>Statistics for Business and Economics. | Apprenticeship - In Class Presentation;<br>Banking Products and Services;<br>Bank Skill Courses (Skills of Bank Credit Officer, Skills of Bank Marketing Officer, and Skills of Bank Operation). |

### ក₂. ការកំណត់ចំនួនក្រេឌីតនៃកម្មវិធីសិក្សា

ការសិក្សាថ្នាក់បរិញ្ញាបត្ររងឯកទេស ហិរញ្ញវត្ថុ និងធនាគារ មានរយៈពេលអប្បបរមា២ឆ្នាំ និងអតិបរមា៣ឆ្នាំ និងមានក្រេឌីតសរុបចំនួន៦១ក្រេឌីត។

### ក₃. លំដាប់លំដោយនៃមុខវិជ្ជាក្នុងកម្មវិធីសិក្សា

- ឆ្នាំទី១

| ឆមាសទី១ | | | | | ឆមាសទី២ | | | | |
|---|---|---|---|---|---|---|---|---|---|
| ល.រ. | កូដមុខវិជ្ជា | ឈ្មោះមុខវិជ្ជា | ក្រេឌីត (L-P-F) | មុខវិជ្ជាតម្រូវសិក្សាមុន | ល.រ. | កូដមុខវិជ្ជា | ឈ្មោះមុខវិជ្ជា | ក្រេឌីត (L-P-F) | មុខវិជ្ជាតម្រូវសិក្សាមុន |
| 1 | ACC 105 | Financial Accounting I | 3 (2-1-0) | - | 1 | ACC 106 | Financial Accounting II | 3 (2-1-0) | ACC 105 |
| 2 | BUS 102 | Introduction to Business | 3 (3-0-0) | - | 2 | ECO 105 | Principles of Economics | 3 (2-1-0) | - |
| 3 | ENG 101 | Core English I | 3 (2-1-0) | ENG 001 or Waive | 3 | ENG 102 | Core English II | 3 (2-1-0) | ENG 101 |
| 4 | MAT 105 | Mathematics for Finance and Banking | 3 (2-1-0) | MAT 001 or Waive | 4 | PHI 105 | Critical Thinking | 3 (3-0-0) | - |
| 5 | PHI 104 | Ethics and Values for Professionals | 3 (3-0-0) | - | 5 | STA 106 | Statistics for Business and Economics | 3 (2-1-0) | MAT 105 |
| | | សរុប | 15 | | | | សរុប | 15 | |

### ឆ្នាំទី២

| ឆមាសទី១ | | | | | ឆមាសទី២ | | | | |
|---|---|---|---|---|---|---|---|---|---|
| ល.រ. | កូដមុខវិជ្ជា | ឈ្មោះមុខវិជ្ជា | ក្រេឌីត (L-P-F) | មុខវិជ្ជាតម្រូវសិក្សាមុន | ល.រ. | កូដមុខវិជ្ជា | ឈ្មោះមុខវិជ្ជា | ក្រេឌីត (L-P-F) | មុខវិជ្ជាតម្រូវសិក្សាមុន |
| 1 | ACC 207 | Managerial Accounting I | 3 (2-1-0) | ACC 106 | 1 | AOC 201 | The Art of Communication | 3 (3-0-0) | - |
| 2 | ENG 203 | Core English III | 3 (2-1-0) | ENG 102 | 2 | BSC 207 | Bank Skill Courses (1) | 6 (4-2-0) | - |
| 3 | FIN 206 | Financial Management I | 3 (2-1-0) | ACC 106, STA 106 | 3 | FIN 204 | Banking Products and Services | 3 (2-1-0) | - |
| 4 | MKT 201 | Principles of Marketing | 3 (3-0-0) | BUS 102 | 4 | APP 208 | Apprenticeship + In Class Presentation (2) | 4 (1.3-0-2.7) | BSC 207 |
| 5 | STA 207 | Fundamentals of Quantitative Analysis | 3 (2-1-0) | STA 106 | | | | | |
| | | សរុប | 15 | | | | សរុប | 16 | |

<u>សម្គាល់:</u>

*(១) និស្សិតទាំងអស់ត្រូវជ្រើសរើសជំនាញ១ក្នុងចំណោមជំនាញធនាគារទាំង៣ (Skills of Bank Operation, Skills of Bank Credit Officer, ឬ Skills of Bank Marketing Officer) ដើម្បីសិក្សា;*

*(២) និស្សិតទាំងអស់ត្រូវចុះហាត់ការ និងធ្វើបទបង្ហាញនៅក្នុងថ្នាក់សម្រាប់ជំនាញធនាគារដែលបានជ្រើសរើស;*

*L = Lecture, ១ក្រេឌីត = ១៥ម៉ោង;*

*P = Practice, ១ក្រេឌីត = ៣០ម៉ោង;*

*F = Fieldwork, ១ក្រេឌីត = ៤៥ម៉ោង។*

## ខ. ថ្នាក់បរិញ្ញាបត្ររងឯកទេស គ្រប់គ្រងអាហារ័ណ-នីហារ័ណ

**ប្រភេទ : ការអប់រំបណ្តុះបណ្តាលបច្ចេកទេស និងវិជ្ជាជីវៈ**

**ដេប៉ាតឺម៉ង់ : គ្រប់គ្រងពាណិជ្ជកម្ម**

**ឯកទេស : គ្រប់គ្រងអាហារ័ណ-នីហារ័ណ**

**កម្រិត : ៥ (បរិញ្ញាបត្ររង)**

### ខ១ មុខវិជ្ជានៃកម្មវិធីសិក្សានីមួយៗ

| មុខវិជ្ជាអប់រំទូទៅ | មុខវិជ្ជាគ្រឹះ | មុខវិជ្ជាស្នូល |
|---|---|---|
| Core English I;<br>Core English II;<br>Core English III;<br>English for Business I;<br>Ethics and Values for Professionals; and<br>The Art of Communication; | Financial Accounting I;<br>Financial Accounting II;<br>Financial Management I;<br>Introduction to Business;<br>Mathematics for Finance and Banking;<br>Microeconomics;<br>Principles of Economics;<br>Principles of Marketing;<br>Principles of Purchasing; and<br>Statistics for Business and Economics | Apprenticeship/Internship for EIM;<br>E-Commerce;<br>Export-Import Operations; and<br>Introduction to Export-Import |

### ខ២. ការកំណត់ចំនួនក្រេឌីតនៃកម្មវិធីសិក្សា

ការសិក្សាថ្នាក់បរិញ្ញាបត្ររងឯកទេស គ្រប់គ្រងអាហារ័ណ-នីហារ័ណ មានរយៈពេលអប្បបរមា២ឆ្នាំ និងអតិបរមា៣ឆ្នាំ និងមានក្រេឌីតសរុបចំនួន៦១ក្រេឌីត។

## ខ៣. លំដាប់លំដោយនៃមុខវិជ្ជាក្នុងកម្មវិធីសិក្សា

### ឆ្នាំទី១

| ឆមាសទី១ | | | | | ឆមាសទី២ | | | | |
|---|---|---|---|---|---|---|---|---|---|
| ល.រ. | កូដមុខវិជ្ជា | ឈ្មោះមុខវិជ្ជា | ក្រេឌីត (L-P-F) | មុខវិជ្ជាតម្រូវសិក្សាមុន | ល.រ. | កូដមុខវិជ្ជា | ឈ្មោះមុខវិជ្ជា | ក្រេឌីត (L-P-F) | មុខវិជ្ជាតម្រូវសិក្សាមុន |
| 1 | ACC 105 | Financial Accounting I | 3 ( 2-1-0) | - | 1 | ACC 106 | Financial Accounting II | 3 ( 2-1-0) | ACC 105 |
| 2 | BUS 104 | Introduction to Business | 3 ( 3-0-0) | - | 2 | ECO 105 | Principles of Economics | 3 ( 2-1-0) | MAT 105 |
| 3 | ENG 101 | Core English I | 3 ( 2-1-0) | ENG 001 or Waive | 3 | EIM 113 | Introduction to Export-Import | 3 ( 2-1-0) | BUS 104 |
| 4 | MAT 105 | Mathematics for Finance and Banking | 3 ( 2-1-0) | MAT 001 or Waive | 4 | ENG 102 | Core English II | 3 ( 2-1-0) | ENG 101 |
| 5 | PHI 104 | Ethics and Values for Professionals | 3 ( 3-0-0) | - | 5 | STA 106 | Statistics for Business and Economics | 3 ( 2-1-0) | MAT 105 |
| | | សរុប | 15 | | | | សរុប | 15 | |

### ឆ្នាំទី២

| ឆមាសទី១ | | | | | ឆមាសទី២ | | | | |
|---|---|---|---|---|---|---|---|---|---|
| ល.រ. | កូដមុខវិជ្ជា | ឈ្មោះមុខវិជ្ជា | ក្រេឌីត (L-P-F) | មុខវិជ្ជាតម្រូវសិក្សាមុន | ល.រ. | កូដមុខវិជ្ជា | ឈ្មោះមុខវិជ្ជា | ក្រេឌីត (L-P-F) | មុខវិជ្ជាតម្រូវសិក្សាមុន |
| 1 | AOC 201 | The Art of Communication | 3 ( 3-0-0) | - | 1 | APE 205 | Apprenticeship/Internship for EIM(1) | 4 ( 1.3-0-2.7) | EIM 209 |
| 2 | ECO 203 | Microeconomics | 3 ( 2-1-0) | ECO 105 | 2 | EIM 209 | E-Commerce | 3 ( 2-1-0) | BUS 104 |
| 3 | ENG 203 | Core English III | 3 ( 2-1-0) | ENG 102 | 3 | ENG 207 | English for Business I | 3 ( 2-1-0) | - |
| 4 | EIM 208 | Export-Import Operations | 3 ( 2-1-0) | EIM 207 | 4 | MKT 201 | Principles of Marketing | 3 ( 3-0-0) | - |
| 5 | FIN 206 | Financial Management I | 3 ( 2-1-0) | ACC 106, STA 106 | 5 | MKT 202 | Principles of Purchasing | 3 ( 2-1-0) | - |
| | | សរុប | 15 | | | | សរុប | 16 | |

<u>សម្គាល់:</u>

*L = ការសិក្សាក្នុងថ្នាក់ (Lecture), ១ក្រេឌីត = ១៥ម៉ោង។*
*P = ការសិក្សាប្រតិបត្តិ (Practice), ១ក្រេឌីត = ៣០ម៉ោង។*
*F = ការអនុវត្តជាក់ស្តែង (Fieldwork), ១ក្រេឌីត = ៤៥ម៉ោង។*
*APE = និស្សិតទាំងអស់ត្រូវចុះហាត់ការ និងធ្វើបទបង្ហាញនៅក្នុងថ្នាក់ សម្រាប់ជំនាញគ្រប់គ្រងអាហារ័ណ-នីហរ័ណ១ក្រេឌីត = ៤៥ម៉ោង)។*

## គ. ថ្នាក់បរិញ្ញាបត្ររងឯកទេស ធានារ៉ាប់រង

ប្រភេទ : **ការអប់រំបណ្តុះបណ្តាលបច្ចេកទេស និងវិជ្ជាជីវៈ**
ដេប៉ាតឺម៉ង់ : **គ្រប់គ្រងពាណិជ្ជកម្ម**
ឯកទេស : **ធានារ៉ាប់រង**
កម្រិត : **៥ (បរិញ្ញាបត្ររង)**

## គ១ មុខវិជ្ជានៃកម្មវិធីសិក្សានីមួយៗ

| មុខវិជ្ជាអប់រំទូទៅ | មុខវិជ្ជាគ្រឹះ | មុខវិជ្ជាស្នូល |
|---|---|---|
| Core English I;<br>Core English II;<br>Core English III;<br>English for Business I; and<br>The Art of Communication. | Consumer Behavior;<br>Ethics and Values for Professionals;<br>Financial Accounting I;<br>Financial Accounting II;<br>Financial Management I;<br>Introduction to Business;<br>Mathematics for Finance and Banking;<br>Microeconomics;<br>Principles of Economics; and<br>Statistics for Business and Economics. | Apprenticeship/Internship for Insurance;<br>Insurance Operations;<br>Introduction to Actuarial; Mathematics;<br>Principles of General Insurance; and<br>Principles of Life Insurance. |

### គ២. ការកំណត់ចំនួនក្រេឌីតនៃកម្មវិធីសិក្សា

ការសិក្សាថ្នាក់បរិញ្ញាបត្ររងឯកទេស ធានារ៉ាប់រងនេះ មានរយៈពេលអប្បបរមា២ឆ្នាំ និងអតិបរមា៣ឆ្នាំ និងមានក្រេឌីតសរុបចំនួន៦១ក្រេឌីត។

### គ៣. លំដាប់លំដោយនៃមុខវិជ្ជាក្នុងកម្មវិធីសិក្សា

#### ឆ្នាំទី១

| ឆមាសទី១ | | | | | ឆមាសទី២ | | | | |
|---|---|---|---|---|---|---|---|---|---|
| ល.រ. | កូដមុខវិជ្ជា | ឈ្មោះមុខវិជ្ជា | ក្រេឌីត (L-P-F) | មុខវិជ្ជាតម្រូវសិក្សាមុន | ល.រ. | កូដមុខវិជ្ជា | ឈ្មោះមុខវិជ្ជា | ក្រេឌីត (L-P-F) | មុខវិជ្ជាតម្រូវសិក្សាមុន |
| 1 | ACC 105 | Financial Accounting I | 3 ( 2-1-0) | - | 1 | ACC 106 | Financial Accounting II | 3 ( 2-1-0) | ACC 105 |
| 2 | BUS 104 | Introduction to Business | 3 ( 3-0-0) | - | 2 | ECO 105 | Principles of Economics | 3 ( 2-1-0) | MAT 105 |
| 3 | ENG 101 | Core English I | 3 ( 2-1-0) | ENG 001 or Waive | 3 | ENG 102 | Core English II | 3 ( 2-1-0) | ENG 101 |
| 4 | MAT 105 | Mathematics for Finance and Banking | 3 ( 2-1-0) | MAT 001 or Waive | 4 | INS 105 | Principles of General Insurance | 3 (2-1-0) | - |
| 5 | PHI 104 | Ethics and Values for Professionals | 3 ( 3-0-0) | - | 5 | STA 106 | Statistics for Business and Economics | 3 ( 2-1-0) | MAT 105 |
| | | សរុប | 15 | | | | សរុប | 15 | |

#### ឆ្នាំទី២

| ឆមាសទី១ | | | | | ឆមាសទី២ | | | | |
|---|---|---|---|---|---|---|---|---|---|
| ល.រ. | កូដមុខវិជ្ជា | ឈ្មោះមុខវិជ្ជា | ក្រេឌីត (L-P-F) | មុខវិជ្ជាតម្រូវសិក្សាមុន | ល.រ. | កូដមុខវិជ្ជា | ឈ្មោះមុខវិជ្ជា | ក្រេឌីត (L-P-F) | មុខវិជ្ជាតម្រូវសិក្សាមុន |
| 1 | AOC 201 | The Art of Communication | 3 ( 3-0-0) | - | 1 | API 205 | Apprenticeship/Internship for Insurance[1] | 4 ( 1.3-0-2.7) | INS 207 - INS 208 |
| 2 | ECO 203 | Microeconomics | 3 ( 2-1-0) | ECO 105 | 2 | ENG 207 | English for Business I | 3 ( 2-1-0) | - |
| 3 | ENG 203 | Core English III | 3 ( 2-1-0) | ENG 102 | 3 | INS 207 | Introduction to Actuarial Mathematics | 3 (2-1-0) | INS 205-INS 206 |
| 4 | FIN 206 | Financial Management I | 3 ( 2-1-0) | ACC 106, STA 106 | 4 | INS 208 | Insurance Operations | 3 (2-1-0) | INS 205-INS 206 |
| 5 | INS 206 | Principles of Life Insurance | 3 (2-1-0) | - | 5 | MKT 210 | Consumer Behavior | 3 ( 3-0-0) | - |
| | | សរុប | 15 | | | | សរុប | 16 | |

<u>សម្គាល់:</u>

*L = ការសិក្សាក្នុងថ្នាក់ (Lecture), ១ក្រេឌីត = ១៥ម៉ោង;*
*P = ការសិក្សាប្រតិបត្តិ (Practice), ១ក្រេឌីត = ៣០ម៉ោង;*
*F = ការអនុវត្តជាក់ស្តែង (Fieldwork), ១ក្រេឌីត = ៤៥ម៉ោង។*
*API = និស្សិតទាំងអស់ត្រូវចុះហាត់ការ និងធ្វើបទបង្ហាញនៅក្នុងថ្នាក់សម្រាប់ជំនាញធានារ៉ាប់រង (១ក្រេឌីត = ៤៥ម៉ោង)។*

## ឃ. ថ្នាក់បរិញ្ញាបត្ររងឯកទេស ចលនទូបត្ថម្ភ

**ប្រភេទ** : **ការអប់រំបណ្តុះបណ្តាលបច្ចេកទេស និងវិជ្ជាជីវៈ**
**ដេប៉ាតឺម៉ង់** : **គ្រប់គ្រងពាណិជ្ជកម្ម**
**ឯកទេស** : **ចលនទូបត្ថម្ភ**
**កម្រិត** : **៥ (បរិញ្ញាបត្ររង)**

## ឃ១. មុខវិជ្ជានៃកម្មវិធីសិក្សានីមួយៗ

| មុខវិជ្ជាអប់រំទូទៅ | មុខវិជ្ជាគ្រឹះ | មុខវិជ្ជាស្នូល |
|---|---|---|
| Core English I;<br>Core English II;<br>Core English III;<br>English for Business I<br>Ethics and Values for Professionals; and<br>The Art of Communication. | Financial Accounting I;<br>Financial Accounting II,<br>Financial Management I;<br>Introduction to Business;<br>Mathematics for Finance and Banking;<br>Microeconomics;<br>Principles of Economics;<br>Principles of Marketing; and<br>Statistics for Business and Economics. | Apprenticeship/Internship for Logistics;<br>Distribution Management;<br>Introduction to Logistics;<br>Inventory Management; and<br>Warehouse Management. |

## ឃ២. ការកំណត់ចំនួនក្រេឌីតនៃកម្មវិធីសិក្សា

ការសិក្សាថ្នាក់បរិញ្ញាបត្ររងឯកទេស ចលនូបត្ថម្ភនេះ មានរយៈពេលអប្បបរមា២ឆ្នាំ និងអតិបរមា៣ឆ្នាំ និងមានក្រេឌីតសរុបចំនួន៦១ក្រេឌីត។

## ឃ៣. លំដាប់លំដោយនៃមុខវិជ្ជាក្នុងកម្មវិធីសិក្សា

- **ឆ្នាំទី១**

| ឆមាសទី១ | | | | | ឆមាសទី២ | | | | |
|---|---|---|---|---|---|---|---|---|---|
| ល.រ. | កូដមុខវិជ្ជា | ឈ្មោះមុខវិជ្ជា | ក្រេឌីត (L-P-F) | មុខវិជ្ជាតម្រូវសិក្សាមុន | ល.រ. | កូដមុខវិជ្ជា | ឈ្មោះមុខវិជ្ជា | ក្រេឌីត (L-P-F) | មុខវិជ្ជាតម្រូវសិក្សាមុន |
| 1 | ACC 105 | Financial Accounting I | 3 ( 2-1-0) | - | 1 | ACC 106 | Financial Accounting II | 3 ( 2-1-0) | ACC 105 |
| 2 | BUS 104 | Introduction to Business | 3 ( 3-0-0) | - | 2 | ECO 105 | Principles of Economics | 3 ( 2-1-0) | MAT 105 |
| 3 | ENG 101 | Core English I | 3 ( 2-1-0) | ENG 001 or Waive | 3 | ENG 102 | Core English II | 3 ( 2-1-0) | ENG 101 |
| 4 | MAT 105 | Mathematics for Finance and Banking | 3 ( 2-1-0) | MAT 001 or Waive | 4 | LOG 105 | Introduction to Logistics | 3 ( 3-0-0) | BUS 104 |
| 5 | PHI 104 | Ethics and Values for Professionals | 3 ( 3-0-0) | - | 5 | STA 106 | Statistics for Business and Economics | 3 ( 2-1-0) | MAT 105 |
| | | សរុប | 15 | | | | សរុប | 15 | |

- **ឆ្នាំទី២**

| ឆមាសទី១ | | | | | ឆមាសទី២ | | | | |
|---|---|---|---|---|---|---|---|---|---|
| ល.រ. | កូដមុខវិជ្ជា | ឈ្មោះមុខវិជ្ជា | ក្រេឌីត (L-P-F) | មុខវិជ្ជាតម្រូវសិក្សាមុន | ល.រ. | កូដមុខវិជ្ជា | ឈ្មោះមុខវិជ្ជា | ក្រេឌីត (L-P-F) | មុខវិជ្ជាតម្រូវសិក្សាមុន |
| 1 | AOC 201 | The Art of Communication | 3 ( 3-0-0) | - | 1 | APL 205 | Apprenticeship/Internship for Logistics(1) | 4 ( 1.3-0-2.7) | LOG 208 - LOG 209 |
| 2 | ECO 203 | Microeconomics | 3 ( 2-1-0) | ECO 105 | 2 | ENG 207 | English for Business I | 3 ( 2-1-0) | - |
| 3 | ENG 203 | Core English III | 3 ( 2-1-0) | ENG 102 | 3 | LOG 208 | Distribution Management | 3 ( 2-1-0) | LOG 207 |
| 4 | FIN 206 | Financial Management I | 3 ( 2-1-0) | ACC 106, STA 106 | 4 | LOG 209 | Inventory Management | 3 ( 2-1-0) | LOG 207 |
| 5 | LOG 207 | Warehouse Management | 3 ( 2-1-0) | LOG 105 | 5 | MKT 201 | Principles of Marketing | 3 ( 3-0-0) | - |
| | | សរុប | 15 | | | | សរុប | 16 | |

<u>សម្គាល់</u>:

*L = ការសិក្សាក្នុងថ្នាក់ (Lecture), ១ក្រេឌីត = ១៥ម៉ោង។*
*P = ការសិក្សាប្រតិបត្តិ (Practice), ១ក្រេឌីត = ៣០ម៉ោង។*
*F = ការអនុវត្តជាក់ស្តែង (Fieldwork), ១ក្រេឌីត = ៤៥ម៉ោង។*
*APL = និស្សិតទាំងអស់ត្រូវចុះហាត់ការ និងធ្វើបទបង្ហាញនៅក្នុងថ្នាក់សម្រាប់ជំនាញចលនូបត្ថម្ភ (១ក្រេឌីត = ៤៥ម៉ោង)។*

## ង. ថ្នាក់បរិញ្ញាបត្ររងឯកទេស គណនេយ្យ

ប្រភេទ : ការអប់រំបណ្តុះបណ្តាលបច្ចេកទេស និងវិជ្ជាជីវៈ
ដេប៉ាតឺម៉ង់ : គ្រប់គ្រងពាណិជ្ជកម្ម
ឯកទេស : គណនេយ្យ
កម្រិត : ៥ (បរិញ្ញាបត្ររង)

### ង១. មុខវិជ្ជានៃកម្មវិធីសិក្សានីមួយៗ

| មុខវិជ្ជាអប់រំទូទៅ | មុខវិជ្ជាគ្រឹះ | មុខវិជ្ជាស្នូល |
|---|---|---|
| - Core English I;<br>- Core English II; and<br>- Ethics and Values for Professionals | - Cambodian Business and Company Law; and<br>- Introduction to Business | - Applied Bookkeeping, Control, and Accounting;<br>- Applied Cambodian Business and Company Law;<br>- Applied Cambodian Taxation and Practices;<br>- Applied Financial Statement Preparation<br>- Applied Introduction to Business;<br>- Applied Introduction to Costing;<br>- Applied Managerial Accounting;<br>- Bookkeeping, Control, and Accounting;<br>- Cambodian Taxation and Practices;<br>- Financial Statement Preparation;<br>- Introduction to Costing;<br>- IT Skills and Software;<br>- Lab for IT Skills and Software;<br>- Managerial Accounting; and<br>- Work Experience or Internship |

### ង២. ការកំណត់ចំនួនក្រេឌីតនៃកម្មវិធីសិក្សា

ការសិក្សាថ្នាក់បរិញ្ញាបត្ររងឯកទេស គណនេយ្យនេះ មានរយៈពេលអប្បបរមា២ឆ្នាំ និងអតិបរមា៣ឆ្នាំ និងមានក្រេឌីតសរុបចំនួន៦១ក្រេឌីត។

### ង៣. លំដាប់លំដោយនៃមុខវិជ្ជាក្នុងកម្មវិធីសិក្សា

- ឆ្នាំទី១

| ឆមាសទី១ | | | | | ឆមាសទី២ | | | | |
|---|---|---|---|---|---|---|---|---|---|
| ល.រ. | កូដមុខវិជ្ជា | ឈ្មោះមុខវិជ្ជា | ក្រេឌីត (L-P-F) | មុខវិជ្ជាតម្រូវសិក្សាមុន | ល.រ. | កូដមុខវិជ្ជា | ឈ្មោះមុខវិជ្ជា | ក្រេឌីត (L-P-F) | មុខវិជ្ជាតម្រូវសិក្សាមុន |
| 1 | ACC 101 | Bookkeeping, Control, and Accounting | 3 (3-0-0) | - | 1 | ACC 102 | Introduction to Costing | 3 (3-0-0) | ACC 101, PRA 101 |
| 2 | COM 102 | IT Skills and Software | 3 (3-0-0) | - | 2 | BUS 102 | Introduction to Business | 3 (3-0-0) | - |
| 3 | PHI 104 | Ethics and Values for Professionals | 3 (3-0-0) | - | 3 | ENG 101 | Core English I | 3 (2-1-0) | ENG 001 or Waive |
| 4 | PRA 101 | Applied Bookkeeping, Control, and Accounting | 3 (0-3-0) | - | 4 | PRA 103 | Applied Introduction to Costing | 3 (0-3-0) | - |
| 5 | PRA 102 | Lab for IT Skills and Software | 3 (0-3-0) | - | 5 | PRA 104 | Applied Introduction to Business | 3 (0-3-0) | - |
| | | សរុប | 15 | | | | សរុប | 15 | |

### ឆ្នាំទី២

| ឆមាសទី១ | | | | | ឆមាសទី២ | | | | |
|---|---|---|---|---|---|---|---|---|---|
| ល.រ. | កូដមុខវិជ្ជា | ឈ្មោះមុខវិជ្ជា | ក្រេឌីត (L-P-F) | មុខវិជ្ជាតម្រូវសិក្សាមុន | ល.រ. | កូដមុខវិជ្ជា | ឈ្មោះមុខវិជ្ជា | ក្រេឌីត (L-P-F) | មុខវិជ្ជាតម្រូវសិក្សាមុន |
| 1 | ACC 204 | Managerial Accounting | 3 (3-0-0) | ACC 102, PRA 103 | 1 | APP 203 | Work Experience Or Internship (1) | 4 (0-0-4) | ACC 204, FIN 202 |
| 2 | ENG 202 | Core English II | 3 (2-1-0) | ENG 101 | 2 | LAW 203 | Cambodian Business and Company Law | 3 (3-0-0) | BUS 102 |
| 3 | FIN 202 | Financial Statement Preparation | 3 (3-0-0) | ACC 102, PRA 103 | 3 | PRA 207 | Applied Cambodian Taxation and Practices | 3 (0-3-0) | - |
| 4 | PRA 205 | Applied Managerial Accounting | 3 (0-3-0) | - | 4 | PRA 208 | Applied Cambodian Business and Company Law | 3 (0-3-0) | - |
| 5 | PRA 206 | Applied Financial Statement Preparation | 3 (0-3-0) | - | 5 | TAX 204 | Cambodian Taxation and Practices | 3 (3-0-0) | - |
| | | សរុប | 15 | | | | សរុប | 16 | |

<u>សម្គាល់</u>:

*L = ការសិក្សាក្នុងថ្នាក់ (Lecture), ១ក្រេឌីត = ១៥ម៉ោង។*
*P = ការសិក្សាប្រតិបត្តិ (Practice), ១ក្រេឌីត = ៣០ម៉ោង។*
*F = ការអនុវត្តជាក់ស្តែង (Fieldwork), ១ក្រេឌីត = ៤៥ម៉ោង។*

## ច. ថ្នាក់បរិញ្ញាបត្ររងឯកទេស ភាសាអង់គ្លេស

**ប្រភេទ** : **ការអប់រំបណ្តុះបណ្តាលបច្ចេកទេស និងវិជ្ជាជីវៈ**
**ដេប៉ាតឺម៉ង់** : **ភាសាបរទេស**
**ឯកទេស** : **ភាសាអង់គ្លេស**
**កម្រិត** : **៥ (បរិញ្ញាបត្ររង)**

## ច១. មុខវិជ្ជានៃកម្មវិធីសិក្សានីមួយៗ

| មុខវិជ្ជាអប់រំទូទៅ | មុខវិជ្ជាគ្រឹះ | មុខវិជ្ជាស្នូល |
|---|---|---|
| • Microsoft Office Essential Skills;<br>• Khmer Studies;<br>• Ethics & Values for Professionals;<br>• Introduction to Statistics;<br>• Introduction to Psychology; and<br>• Introduction to Cambodian Law | • Academic Writing I;<br>• Academic Writing II;<br>• Critical Reading and Writing I;<br>• Critical Reading and Writing II;<br>• Global Studies I;<br>• Global Studies II;<br>• Core English I;<br>• Core English II;<br>• Core English III;<br>• Core English IV;<br>• Listening & Speaking Skills;<br>• Literature Studies I;<br>• Literature Studies II; and<br>• Public Speaking | N/A |

## ច២. ការកំណត់ចំនួនក្រេឌីតនៃកម្មវិធីសិក្សា

